**សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ទំនាក់ទំនង
# និងគោលនយោបាយការទូត

(បញ្ហាប្រឈម និងដំណោះស្រាយ)

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩

រៀបរាងដោយ

និស្សិតឈ្មោះ៖ **ចាន់ ស្រីល័ក្ខ**

**ចូវ ម៉ាន់អុី**

ណែនាំដោយសាស្ត្រាចារ្យ

**លី មួយ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំពិតជាមានសេចក្ដីរីករាយ និងមានមោទនភាពចំពោះក្រុមយើងខ្ញុំដែលបានទទួលនូវឱកាសក្នុងនិមិត្តស្នាដៃដ៏តូចមួយនេះ។ ដូច្នេះ ឆ្លៀតឱកាសដ៏ថ្លៃថ្លានេះ យើងខ្ញុំសូមសម្ដែងនូវការគោរព និងថ្លែងអំណរគុណជ្រាលជ្រៅចំពោះវត្តមាន នៃបុគ្គលទាំងឡាយដែលបានជួយជំរុញឱ្យ កិច្ច ការស្រាវជ្រាវមួយនេះទទួលបានជាផ្លែផ្កា។

ជាបឋម យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅចំពោះក្រុមគ្រួសារ ជាពិសេសលោកឪពុកអ្នកម្ដាយរបស់យើងខ្ញុំដែលបានផ្ដល់កំណើត ផ្ដល់សេចក្ដី ស្រលាញ់ ផ្ដល់ការយកចិត្តទុកដាក់ ផ្ដល់ដំបូន្មាន ផ្ដល់ការប្រៀនប្រដៅ និងបានចិញ្ចឹមបីបាច់ថែរក្សាយើងខ្ញុំតាំងពីតូចរហូតមក ព្រមទាំងខិតខំទាំងកាយ ទាំងចិត្ត ស្មារតី ផ្ដល់ជាសម្ភារៈ មធ្យោបាយគ្រប់យ៉ាង និងកំលាំងចិត្តដល់យើងខ្ញុំ ឲ្យបានក្រេបជញ្ជក់នូវចំណេះដឹងអស់រយៈពេលជាងដប់ឆ្នាំ រហូតដល់បន្តការ សិក្សាឧត្តមសិក្សា ព្រមទាំងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ ប្រកបដោយភាពជោគជ័យដ៏ល្អផូរផង់។

បន្ទាប់មកទៀត យើងខ្ញុំក៏សូមសម្ដែងនូវការគោរព និងថ្លែងអំណរគុណ យ៉ាងជ្រាវជ្រៅផងដែរចំពោះឯកឧត្ដមសាកលវិទ្យាធិការ និងសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ជាពិសេស យើងខ្ញុំសូមថ្លៃអំណរគុណជាអនេកប្បការជូនចំពោះ សាស្ត្រាចារ្យ **លី មួយ** ដែលបានខិតខំបង្ហាត់បង្រៀន ព្រមទាំងបានជួយពន្យល់ណែនាំ ផ្ដល់យោបល់ និងតម្រង់ទិស យើងខ្ញុំក្នុងការសរសេរសារណាមួយនេះឡើង។ យើងខ្ញុំ ក៏មិនអាចបំភ្លេចបានដែរ ចំពោះគុណបំណាច់របស់លោក លោកស្រី សាស្ត្រាចារ្យ មន្ត្រីរាជការទាំងអស់នៃសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្ទេរនូវចំណេះវិជ្ជាជាច្រើនមកអោយយើងខ្ញុំ ក្នុងរយៈពេល៤ឆ្នាំនេះ។ ក្នុងនោះផងដែរ យើងខ្ញុំក៏សូមអរគុណចំពោះសិស្ស និស្សិតដែលជាសិស្សច្បង ដែលបានជួយជាយោបល់ ចំណេះដឹង និងបទពិសោធន៍មួយចំនួនដែលដែលពួកគាត់បានឆ្លងកាត់កន្លងមក។

ជាចុងក្រោយ លើអ្វីដែលបានរៀបរាប់ដ៏ខ្លីខាងលើ គឺជាគុណបំណាច់ដ៏មិន អាចកាត់ថ្លៃបានក្នុងជីវិតនេះ យើងខ្ញុំមិនអាចបំភ្លេចបានឡើយ ហើយយើងខ្ញុំដឹង ថាបើគ្មានវត្តមានរបស់អស់លោក លោកស្រីទេ ស្នាដៃមួយនេះក៏មិនអាចលេច ចេញជារូបរាងបានដែរ។ ដូច្នេះ យើងខ្ញុំសូមលើកម្រាមដៃដប់ ដើម្បីថ្លែង អំណរគុណ និងសូមបួងសួងអោយអស់លោក លោកស្រីជួបតែសេចក្ដីសុខ សុភមង្គល សុខភាពល្អ ព្រមទាំងមានអាយុវែង និងជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

យើងខ្ញុំបានចំណាយពេលវេលាដ៏មានតម្លៃយ៉ាងសន្ធឹកសន្ធាប់ក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ ក្នុងការសិក្សាស្រាវជ្រាវផ្នែកនីតិសាស្ត្រ ហើយជាមួយគ្នានោះ យើងបានក្របជញ្ចក់ចំណេះដឹងដ៏ច្រើនក្រាស់ក្រែលផងដែរ ក្រោមការពន្យល់ណែនាំអំពីសំណាក់សាស្ត្រាចារ្យទាំងអស់ និងការខិតខំសិក្សា ស្រាវជ្រាវ ដោយខ្លួនឯងផ្ទាល់។ ពិតណាស់ ក្រោមឱកាសដ៏វិសេសវិសាលដើម្បីសម្រេច នូវស្នាដៃមួយនេះឡើយ យើងខ្ញុំក៏ខិតខំប្រមូលចំណេះដឹងទាំងនោះ និងធ្វើការសិក្សាស្រាវជ្រាវលើឯកសារមួយចំនួនទៀត។ ជាចុងក្រោយ យើងខ្ញុំក៏បាន សម្រេចលើប្រធានបទមួយក្នុងចំណោមប្រធានបទជាច្រើន ដើម្បីយកមកសិក្សា ស្រាវជ្រាវឲ្យកាន់តែស៊ីជម្រៅ និងធ្វើការចងក្រងអត្ថបទសារណាបញ្ចប់ការ សិក្សាមួយនេះឡើង។ ជាក់ស្តែង អត្ថបទនេះមានចំណងជើងថា "ទំនាក់ទំនងគោលនយោបាយការបរទេសរបស់កម្ពុជាក្នុងសតវត្សទី២១" ដែលប្រធានបទនេះបានយកចិត្តទុកដាក់លើការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា ក្នុងការទំនាក់ទំនង និងការតាក់តែងគោលនយោបាយកម្ពុជាអោយមានការរីកចម្រើន ដើម្បីចូលរួមចំណែកក្នុងការពន្លឿនដំណើរការរបស់អាស៊ានសម្រេច បាននូវគោលនយោបាយល្អ ដែលបានជួយពង្រឹងទំនាក់ទំនងអោយបានកាន់តែល្អ។ បន្ថែមលើនេះមូលហេតុចំបងដែលជម្រុញឲ្យសម្រេចលើកយកបញ្ហានេះ មកស្រាវជ្រាវគឺដើម្បីស្វែងយល់ពីដំណើរការ និងរបៀប នៃការរៀបចំគោលនយោបាយការបរទេស ព្រមទាំងបញ្ហាប្រឈមផ្សេងៗនៃដំណើរការគោលនយោបាយ ក៏ដូចជាដំណើរការឆ្ពោះទៅបានសម្រេចគោលនយោបាយនោះ។ ថាតើដំណើរការនៃគោលនយោបាយការបរទេសប្រឈមនិងបញ្ហាអ្វីខ្លះ? តើកម្ពុជាត្រូវក្សា ឬត្រូវធ្វើការកែសម្រួលសកម្មភាពច្បាប់ពាក់ព័ន្ធដែលមានស្រាប់ឬយ៉ាងណា? តើកម្ពុជាបានចូលរួមក្នុងសកម្មភាពគោលនយោបាយការបរទេសអ្វីខ្លះ? ម្យ៉ាងទៀត ក្នុងដំណើរការគោលនយោបាយការបរទេស តើកម្ពុជាត្រូវយកចិត្ត ទុកដាក់លបញ្ហាអ្វីខ្លះ និងត្រូវមានលិខិតបទដ្ឋានគតិយុត្តអ្វីខ្លះ ដែលត្រូវយកមក ប្រើនិងត្រូវបង្កើតថ្មី ដើម្បីធានាបាននូវការអភិវឌ្ឍន៍ជាចិរភាពរបស់ប្រទេសជាតិ? មួយវិញទៀត ដើម្បីស្របទៅនិងការឆ្ពោះទៅរកសមាហរកម្មក្នុង និងក្រៅប្រទេស ក្នុងពេលបច្ចុប្បន្ន កិច្ចការស្រាវជ្រាវនេះគឺមិនត្រឹមតែសម្រាប់ ការយល់ដឹងផ្ទាល់ខ្លួនតែប៉ុណ្ណោះទេ តែថែមទាំងជាប្រយោជន៍ដល់អ្នកសិក្សាទាំងឡាយទុកជាឯកសាតជំនួយស្មារតីក្នុងការស្រាវជ្រាវ និងសម្រាប់ជាស្មារតី ដោះស្រាយបញ្ហាដែលពាក់ព័ន្ធដទៃទៀតជាក់ជាមិនខាន។ ជាទីបញ្ចប់ យើងខ្ញុំជឿជាក់ថា អត្ថបទតូចមួយនេះពិតជាមានកំហុសឆ្គងដោយអចេតនាមួយ ចំនួនតូចដែលទាមទារនូវការអធ្យាស្រ័យពីសំណាក់អ្នកអាន និង

អ្នកសិក្សាទាំងអស់ផងដែរ។ ដូច្នេះ យើងខ្ញុំសូមអភ័យទោស និងសូមថ្លែងអំណរគុណទុក ជាមុននូវការយោគយល់អធ្យាស្រ័យទៅលើភាពមិនប្រក្រតីនោះ។

# មាតិកា


សេចក្ដីផ្ដើម ទំព័រ

ជំពូកទី១៖ ច្បាប់ និងទិដ្ឋភាពទូទៅនៃគោលនយោបាយការទូត ........ ១

១.១ ច្បាប់ជាតិនិងអន្តរជាតិ. ........ ១

១.១.១. ច្បាប់ជាតិ ........ ២

១.១.២. ច្បាប់អន្តរជាតិ ........ ៣

១.២. ប្រវត្តិនៃនយោបាយការទូតកម្ពុជាជាមួយប្រទេសជិតខាង........ ៤

១.៣. ទំនាក់ទំនងរវាងកម្ពុជានិងចិន ........ ៤

១.៤. ទំនាក់ទំនងរវាងកម្ពុជានិងវៀតណាម ........ ៨

១.៥. ទំនាក់ទំនងរវាងកម្ពុជានិងអាល្លឺម៉ង់ ........ ៩

ជំពូកទី២៖ ការអភិវឌ្ឍន៍វិស័យការទូត ........ ១៣

២.១. វិសាលភាពទំនាក់ទំនងការទូត ........ ១៣

២.១.១. ទំនាក់ទំនងការទូតកម្ពុជានិងប្រទេសជិតខាង ........ ១៣

២.១.២. កិច្ចសហប្រតិបត្តិការទ្វេភាគី ........ ១៣

២.១.៣. កិច្ចសហប្រតិបត្តិការនៅតំបន់ទ្វេភាគីនៅតំបន់អាស៊ី ........ ១៤

២.១.៤. កិច្ចសហប្រតិបត្តិការក្នុងតំបន់ ........ ២១

២.១.៥. កិច្ចសហប្រតិបត្តិការណ៍ជាមួយនិងអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិ ........ ២២

២.២. វិសាលភាពទំនាក់ទំនងពហុភាគី ........ ២៣

២.២.១. អង្គការសហប្រជាជាតិ ........ ២៣

២.២.២. អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ........ ២៤

ក. នៅអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ........ ២៥

ខ. ស្ថាប័នអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ........ ២៦

គ. ព្រះរាជាណាចក្រកម្ពុជានិងអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ........ ២៦

ឃ. កិច្ចប្រជុំ ........ ២៧

២.២.៣. កិច្ចសហប្រតិបត្តិការមេគង្គ ........ ២៧

ក. ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ ........ ២៧

ខ. ពត៌មានសង្ខេបស្តីពីការងារកិច្ចសហប្រតិបត្តិការមេគង្គ ................................ ២៧

គ. ការពាក់ព័ន្ធរបស់កម្ពុជានិងអត្ថប្រយោជន៍កិច្ចសហប្រតិបត្តិការមេគង្គសំរាប់កម្ពុជា ........................................................................................................................ ៣០

២.៣. ការចូលរួមយ៉ាងសកម្មរបស់កម្ពុជាក្នុងឆាកអន្តរជាតិ................................ ៣០

**ជំពូកទី៣៖ បញ្ហាប្រឈម និងដំណោះស្រាយគោលនយោបាយការទូត.......... ៣៨**

៣.១. បញ្ហាប្រឈមទូទៅ.............................................................................. ៣៨

៣.១.១. ការអនុវត្តច្បាប់.......................................................................... ៣៨

៣.១.២. កត្តាធនធានមនុស្ស .................................................................. ៤០

៣.១.៣. កត្តាធនធាននិស្សិត.................................................................... ៤១

៣.១.៤. កត្តាហិរញ្ញវត្ថុ.......................................................................... ៤១

៣.២. ដំណោះស្រាយនិងពង្រឹងវិស័យការទូត .......................................... ៤២

៣.២.១. កត្តាធនធានមនុស្ស .................................................................. ៤២

៣.២.២. កត្តាហរិញ្ញវត្ថុ.......................................................................... ៤៣

៣.២.៣. ពង្រឹងនិងពង្រីកវិសាលភាពការទូតទ្វេភាគីនិងពហុភាគី.................... ៤៣

៣.២.៤. ពង្រឹងអនុភាពនៃការអនុវត្តច្បាប់ជាតិ.............................................. ៤៤

**សេចក្តីសន្និដ្ឋាន**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

ផ្ដើមចេញពីចំនុចសូន្យ ក្រោយរបបយង់ឃ្នង "កម្ពុជាប្រជាធិបតេយ្យ" រយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ដែលប្រជាពលរដ្ឋខ្មែរគ្រប់រូបមិនអាចបំភ្លេចបាន កម្ពុជាបានអភិវឌ្ឍខ្លួនម្ដងបន្តិចទៅរកការអភិវឌ្ឍន៍ដែលគួរអោយកត់សម្គាល់។ ជាក់ស្ដែង ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់បានធ្វើការរៀបចំសណ្ដាប់ធ្នាប់ របៀបរៀបរយនិងសន្តិសុខ នៅលើផ្ទៃប្រទេសទាំងមូលប្រកបដោយស្ថេរភាព ព្រមទាំងស្រុះស្រួលគ្នា ដើម្បីបង្កើតរាជរដ្ឋាភិបាលមួយដែលមានការទទួល ស្គាល់និងទទួលបានសេចក្ដីទុកចិត្តពីសំណាក់ប្រជាពលរដ្ឋ បណ្ដាប្រទេសជា មិត្ត និងអង្គការជាតិ និងអង្គការអន្តរជាតិគ្រប់ទិសទី។ ជាបន្តបន្ទាប់កម្ពុជា បានចាប់ផ្ដើមមានទំនាក់ទំនងយ៉ាងជិតស្និតក្នុងចំណោមប្រទេសរបស់ខ្លួន។ ដោយធ្វើការអភិវឌ្ឍន៍លើគ្រប់វិស័យទាំងអស់នៅក្នុងប្រទេស និងទំនាក់ទំនង អន្តរជាតិថ្នាក់ក្នុង និងក្រៅតំបន់ ក្រោយការបោះឆ្នោតជាសកលកក្រោមការ រៀបចំរបស់រដ្ឋាភិបាល សន្តិសុខរបស់អង្គការសហប្រជាជាតិ (UNTAC)។ មួយវិញទៀត រាជរដ្ឋាភិបាលកម្ពុជាពីមួយអាណត្តិទៅមួយអាណត្តិតែងតែយក ចិត្តទុកដាក់លើកគោលនយោបាយការបរទេស អភិវឌ្ឍប្រទេសយ៉ាងម៉ត់ហ្មត់ ជាពិសេសការបរទេសដែលគោលនយោបាយមួយក្នុងចំណោមគោលនយោបាយដែលមិនអាចខ្វះបានក្នុងបរិបទនៃការអភិវឌ្ឍន៍។

ក្នុងន័យនេះផងដែរ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាកន្លង មកតែងតែមានទស្សនៈវិស័យនៅក្នុងការអភិវឌ្ឍន៍ដោយផ្សារភ្ជាប់ជាមួយសមាហរកម្មពិភពលោក និងក្នុងតំបន់។ ជាក់ស្ដែង កន្លងមកកម្ពុជាបានសម្រេចនូវ សមិទ្ធផលលើគោលនយោបាយការបរទេសមួយចំនួនជាបន្តបន្ទាប់ ក្នុងការចូល ជាសមាជិកនៃអង្គការនៃអង្គាការជាតិ និងអង្គការអន្តរជាតិ ដូចជាអង្គការសហប្រជាជាតិដែលជាអង្គការ (UN) ដែលជាអង្គការអន្តរជាតិដ៏ធំបំផុតជា ពិសេសគឺការទទួលសមិទ្ធផលជាផ្លូវការ នៃសហគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ ជាតិតំបន់ក៏បានយកចិត្តទុកដាក់លើមូលដ្ឋាននៃការអភិវឌ្ឍន៍ដែលឆ្លុះបញ្ចាំងតាមរយៈ ការពង្រឹងទំនាក់ទំនងគោលនយោបាយដ៏ល្អប្រសើរ និងជំរុញប្រទេសជា សមាជិកក្នុងការលើកកម្ពស់ស្មារតី ដើម្បីរៀបចំគោលនយោបាយការបរទេសរបស់ខ្លួនអោយកាន់តែស៊ីជម្រៅ។ ប្រទេសកម្ពុជា ជាសមាជិកមួយក៏បានរៀបចំ តាក់តែងគោលនយោបាយខ្លះរបស់ខ្លួនប្រកបដោយតម្លាភាព ដែលជាការចូល រួមចំណែកមួយដ៏សំខាន់ ដើម្បីពន្លឿនសកម្មភាពអាស៊ានក្នុងដំណើរទៅសម្រេច អោយបាននូវគោលនយោបាយដ៏ល្អមួយ។ ហេតុនេះហើយបានជាមានប្រធាន បទស្ដីពី **"ទំនាក់ទំនង និងគោលនយោបាយការទូតរបស់កម្ពុជា ស.តទី**

២១" បានចាប់បដិសន្ធិឡើងក្នុងអត្ថបទស្រាវជ្រាវមួយនេះ ដើម្បីឆ្លុះបញ្ចាំងពីការវិវត្តន៍របស់កម្ពុជាក្នុងវិស័យការទូត។

យ៉ាងណាមិញ ប្រធានបទនេះនិងជួយជំរុញការយកចិត្តទុកដាក់ពី សំណាក់ប្រជាពលរដ្ឋគ្រប់រូប គ្រប់ស្រទាប់វណ្ណៈ លើបញ្ហាជាតិក៏ដូចជា ទំនាក់តំនងអន្តរជាតិអោយកាន់តែស៊ីជម្រៅ។ ជាងនេះទៅទៀត ប្រធានបទនេះនិងជួយកើនរំលឹកប្រជាពលរដ្ឋកម្ពុជាគ្រប់រូបអោយមានការប្រុង ប្រយ័ត្នរាល់ហានិភ័យដែលអាចនិងកើតមានក្នុង នងក្រៅប្រទេស។

អត្ថបទស្រាវជ្រាវនេះ ផ្តោតសំខាន់ទៅលើគោលនយោបាយការបរ ទេសរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងដំណើរឆ្ពោះទៅការចូលរួមសម្រេចគោល ដៅយុទ្ធសាស្រ្តមួយក្នុងអាស៊ាន។ មួយវិញទៀត ប្រធានបទនេះយកចិត្តទុកដាក់ ទៅលើទំនាក់ទំនងអន្តរជាតិ ឬគោលនយោបាយការបរទេសដែលជាចំណេះដឹង មួយដែលជំរុញអោយមានការអភិវឌ្ឍន៍នាប្រទេសជិតខាង និងក៏ជាការបោះចំហា ខ្លួននៅចំកណ្តាលតំបន់ទន្លេមេគង្គ និងអាស៊ីអាគ្នេយ៍ ដោយសារតែកម្ពុជាមាន សក្តានុពលដ៏សម្បើម ដើម្បីក្លាយខ្លួនជារដ្ឋស្ពានមេត្រីនៅក្នុងតំបន់ និងពង្រឹងតួនាទីភាពជាអ្នកដឹកនាំរបស់ខ្លួននៅក្នុងអាស៊ាន ក៏ដូចជានៅក្នុង ស្ថាប័នដទៃផ្សេងទៀតនៅក្នុងអនុតំបន់។ ដូច្នេះហើយ ការស្រាវជ្រាវនេះ និងធ្វើ ការផ្តោតលើចំណោទបញ្ហាមួយចំនួនដូចខាងក្រោម ៖

- តើអ្វីទៅជា គោលនយោបាយការបរទេសរបស់កម្ពុជា?
- តើកម្ពុជាបានចូលរួមក្នុងសកម្មភាពអ្វីខ្លះ ក្នុងគោលនយោបាយការទូត?
- តើទំនាក់ទំនងនៃគោលនយោបាយការទូត របស់កម្ពុជាបានជួបប្រទះទៅ និងបញ្ហាប្រឈមអ្វីខ្លះ ហើយតើនិងមានដំណោះស្រាយណាខ្លះ ដើម្បី តតាំងជាមួយផលប៉ះពាល់ទាំងនោះ?

នៅក្នុងបន្ទាត់ស្របនៃចំណោទបញ្ហាខាងលើ កិច្ចការស្រាវជ្រាវនេះ មានគោលបំណងចំបងសំដៅលើភាពរីកចម្រើននៃគោលនយោបាយការបរទេសរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងទិសដៅសម្រេចលើការអភិវឌ្ឍន៍ចិរភាព របស់ជាតិ ក៏ដូចជាអន្តរជាតិ ជាពិសេសការចូលរួមអភិវឌ្ឍន៍ក្នុងថ្នាក់តំបន់ជាមួយ ប្រទេសដៃគូរនៃសមាជិកអាស៊ានទាំង ១០។ តួយ៉ាង ការរៀបចំគោលនយោ បាយការបរទេសអោយមានតម្លាភាព ដើម្បីប្រឈមនិងការមកដល់នៃដំណាក់ កាលរំពឹង ទុកជាជំហានដំបូងរបស់កម្ពុជា។ ដើម្បីឆ្លុះបញ្ចាំងពីគោលបំណង ចំបងខាងលើនៃការស្រាវជ្រាវនេះ អ្នកនិពន្ធធ្វើការបកស្រាយលើគោលបនយោ បាយការបរទេសនៃវិស័យការទូត ក្នុងបរិបទការបរទេស ព្រមទាំងលើកយក ឱកាស និងការប្រឈមនៃគោលនយោបាយនេះ។

ដើម្បីអោយកាន់តែពិស្តារមួយកម្រិតទៀត ការសិក្សាស្រាវជ្រាវនេះ កំណត់ដែនវិសាលភាពរបស់ខ្លួន ដោយគ្របដណ្តប់លើប្រសិទ្ធិភាពនៃតាក់តែង រៀបចំគោលនយោបាយការបរទេសរបស់កម្ពុជាដោយជ្រើសរើសយកការបក ស្រាយនៅក្នុងដែនកំណត់នៃវិស័យអាទិភាពនៃការអភិវឌ្ឍន៍ជាតិ។ ជាងនេះទៅទៀត ការសិក្សាស្រាវជ្រាវនេះធ្វើការផ្តោតទៅលើការទំនាក់ទំនងនិងគោលនយោបាយ ដើម្បីត្រៀមខ្លួនសម្រាប់ដំណាក់កាលរំពឹងទុកជាបឋមនៃ ការរីកចំរើន។

យ៉ាងណាមិញ ការសិក្សាស្រាវជ្រាវនេះនិងនូវប្រយោជន៍ ចំណេះដឹង ដល់អ្នកសិក្សាអោយកាន់តែយល់ច្បាស់ពីការអភិវឌ្ឍន៍ទំនាក់ទំនង និងគោល នយោបាយការបរទេសរបស់កម្ពុជា ជាពិសេសយុទ្ធសាស្ត្រសំខាន់លើការ អភិវឌ្ឍន៍។

# ជំពូកទី ១

# ច្បាប់

# និងទិដ្ឋភាពទូទៅនៃគោល

# នយោបាយការទូត

# ជំពូកទី១ ៖ ច្បាប់ និងទិដ្ឋភាពទូទៅនៃគោលនយោបាយការទូត

## ១.១. ច្បាប់ជាតិ និងច្បាប់អន្តរជាតិ

ប្រទេសមួយសង្គមមួយ ប្រសិនបើប្រទេសមួយត្រូវការអភិវឌ្ឍន៍ទៅមុខ វាត្រូវតែមានការគ្រប់គ្រងទៅដោយក្បួនច្បាប់ ដើម្បីជៀសវាងនូវភាពគ្មានសណ្តាប់ធ្នាប់។ ក្នុងនោះដំណើរការក្នុង ការទំនាក់ទំនងរដ្ឋ និងរដ្ឋក្នុងអន្តរជាតិ ក៏មិនអាចដំណើរការទៅបានល្អទេ បើសិនជាគ្មានការព្រមព្រៀង ឬក៏ការគោរពសិទ្ធិរវាងគូរភាគីទាំងសងខាង។ យ៉ាងណាមិញ ប្រទេសកម្ពុជាក៏ដូច្នោះផងដែរ ដូចនេះហើយប្រទេសកម្ពុជា ក្នុងការអភិវឌ្ឍន៍គោលនោយបាយការបរទេស របស់ខ្លួន បានរៀបចំឡើងស្របទៅតាមក្បួនខ្នាតដែលទទួលស្គាល់ជាអន្តរជាតិ ។

### ១.១.១. ច្បាប់ជាតិ

នៅក្នុងព្រះរាជាណាចក្រកម្ពុជាក៏មានច្បាប់ និងអនុក្រឹត្យដែលបង្កើតឡើងក្នុងគោលបំណងការពារ និងរក្សាគោលនយោបាយការបរទេសរបស់ខ្លួនអោយមានស្ថេរភាពផងដែរ ហើយទាំងនោះ មានដូចជា៖

- មាត្រា៥៣ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា [1]

  ព្រះរាជាណាចក្រកម្ពុជា ប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹត្យអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ។ ព្រះរាជាណាចក្រកម្ពុជា រួមរស់សន្តិសហវិជ្ជមានជាមួយប្រទេសជិតខាងនិងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក។ ព្រះរាជាណាចក្រកម្ពុជា មិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ រឺដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក។ ព្រះរាជាណាចក្រកម្ពុជា មិនចងសម្ព័ន្ធយោធា រឺចូលក្នុងកិច្ចព្រមព្រៀងយោធាណាមួយដែលមិនស្របនឹងអព្យាក្រឹត្យភាពរបស់ខ្លួនឡើយ។

  ព្រះរាជាណាចក្រកម្ពុជា មិនអនុញ្ញាតអោយមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតអោយមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ។ ព្រះរាជាណាចក្រកម្ពុជា រក្សាសិទ្ធិទទួលយកជំនួយបរទេសជាសំភារៈយោធា អាវុធ គ្រាប់រំសេវ ការហ្វឹកហ្វឺនកងកំលាំងប្រដាប់

1 មាត្រា៥៣នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

អាវុធ និងជំនួយផ្សេងៗទៀត ដើម្បីការពារខ្លួន និងធានាសណ្ដាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស។

- អនុក្រឹត្យលេខ ៦៩ អនក្រ.បក ស្ដីពីការបង្កើតស្ថានអគ្គកុងស៊ុលកម្ពុជានៅបរទេស
- អនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតគណៈកម្មការជាតិទទួលបន្ទុកការងារជំនួយយោធាពីបរទេស

  គណៈកម្មការមួយហៅថា គណៈកម្មការជាតិ ទទួលបន្ទុកការងារជំនួយយោធាពីបរទេស ដើម្បីជួយដល់រាជរដ្ឋាភិបាល ក្នុងការបង្កើតកិច្ចសហប្រតិបត្តិការ និងការទាក់ទងសុំជំនួយយោធាពីបរទេសបានត្រូវបង្កើតដែលមានសមាសភាពនៃគណៈកម្មាការជាតិនេះ មានភារកិច្ចដូចខាងក្រោម៖

  - ចាត់ចែងទាក់ទងជាមួយប្រទេសនានា ក្នុងន័យបង្កើនកិច្ចសហប្រតិបត្តិការលើវិស័យយោធា និងទាក់ទងសុំជំនួយយោធាពីបរទេស
  - ពិនិត្យពិភាក្សា និងកែសម្រួល ឲ្យបានសមស្របតាមសភាពការជាក់ស្ដែង នូវគម្រោងស្នើសុំជំនួយយោធាពីបរទេសដែលបានលើកឡើងដោយក្រសួងការពារជាតិ
  - ពិនិត្យតាមដាន និងបង្កលក្ខណៈងាយស្រួលឲ្យក្រសួងការពារជាតិបានទទួល និងប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពនូវជំនួយយោធាពីបរទេស
  - កសាងរបៀបរបបធ្វើការងារផ្ទាល់ខ្លួន ដើម្បីចាត់ចែងការងារឲ្យមានប្រសិទ្ធភាព ដើម្បីជាជំនួយកិច្ចការដល់គណៈកម្មការជាតិនេះ លេខាធិការដ្ឋានមួយ ត្រូវបានបង្កើតឡើងដោយយកនាយកដ្ឋានទាក់ទងអន្តរជាតិ នៃក្រសួងការពារជាតិ ធ្វើជាទីស្នាក់ការដើម្បីបំពេញការងារក្នុងពេលចាំបាច់។[2]

- សេចក្ដីសម្រេចលេខ ១២ សសរ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិកែទម្រង់គ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ៖ មាត្រា ៨ ជនបរទេស មិនត្រូវបានអនុញ្ញាតិឲ្យកាន់កាប់ ឬ ប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទនៅព្រះរាជាណាចក្រកម្ពុជា។[3]

---

[2] អនុក្រឹត្យ០៩អនក្រ.បក ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតគណៈកម្មការជាតិទទួលបន្ទុកការងារជំនួយយោធាពីបរទេស

[3] មាត្រា៨ នៃសេចក្ដីសម្រេចលេខ ១២សសរ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិកែទម្រង់គ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

តាមសំណើសុំជាផ្លូវការ រាជរដ្ឋាភិបាលអាចផ្តល់ជាការលើកលែងចំពោះអង្គរក្សបរទេសៈ អង្គរក្សរបស់ព្រះមហាក្សត្រ ឬ ព្រះមហាក្សត្រិយានី ប្រធានាធិបតី ប្រមុខរដ្ឋ នាយករដ្ឋមន្ត្រី ឥស្សរជនជាន់ខ្ពស់ដែលយាងរឺអញ្ជើញមកទស្សនកិច្ចកម្ពុជា។

- សេចក្តីសម្រេចលេខ ១៣សសរ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួល កិច្ចការបញ្ជូនកម្លាំងចូលរួមបេសកកម្មរក្សាសន្តិសុខ របស់អង្គការសហប្រជាជាតិ

ប្រការ ៣ ៖ គណៈកម្មាធិការជាតិ មានបេសកកម្ម តួនាទី និងភារកិច្ចដូចខាងក្រោមៈ

- សម្របសម្រួលកិច្ចការទាំងឡាយដែលពាក់ព័ន្ធ និងការត្រៀមរៀបចំកម្លាំងចូលរួមបេសកកម្មរក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិជាមួយក្រសួង និងស្ថាប័នផ្សេងៗ។

- ទំនាក់ទំនង អ.ស.ប ក្នុងការរៀបចំឯកសារលិខិតបទដ្ឋាននានា សម្រាប់បញ្ជូនចូលរួមបំពេញ បេសកកម្ម អ.ស.ប រួមមានកំលាំងបោសសំអាតមីនយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ នាយទាហាន សង្កេតការណ៍ បុគ្គលិកធ្វើការក្នុងក្របខ័ណ្ឌ អ.ស.ប និងការងារផ្សេងៗទៀត តាមតម្រូវការ អ.ស.ប និងតាមលទ្ធភាពកម្ពុជា។

- លើកយោបល់ និងសំណើផ្ទាល់ជូនរដ្ឋាភិបាលជ្រាប ពិនិត្យ និងសំរេចលើរាល់កិច្ចការពាក់ព័ន្ធ នឹងការត្រៀមកំលាំងទៅចូលរួមបេសកកម្មរក្សាសន្តិសុខរបស់ អ.ស.ប។

- លើកគំរោងថវិការសំរាប់បំពាក់ឧបករណ៍នានា និងបំរើការងារហ្វឹកហ្វឺន ជូនកងកម្លាំងគ្រប់ប្រភេទដែលនិងចូលរួមបេសកកម្មរបស់ អ.ស.ប។[4]

## ១.១.២. ច្បាប់អន្តរជាតិ

ចំពោះ ច្បាប់អន្តរជាតិវិញ ព្រះរាជាណាចក្រកម្ពុជា ចូលរួមយ៉ាងសកម្មដើម្បីលើកស្ទួយវិស័យគោលនយោបាយការបរទេសដែលមានដូចជាៈ

- ធម្មនុញ្ញអាស៊ាន ដែលមានគោលបំណងថែរក្សា និងលើកកម្ពស់សន្តិភាព សន្តិសុខ និងស្ថេរភាព និងពង្រឹងថែមទៀតនូវតម្លៃឆ្ពោះទៅរកសន្តិភាពក្នុងតំបន់។ លើកកម្ពស់ភាពរឹងមាំនៃតំបន់ តាមរយៈការជុំរុញឲ្យកាន់តែខ្លាំងថែមទៀត នូវកិច្ចសហប្រតិបត្តិការផ្នែកនយោបាយ សន្តិសុខ សេដ្ឋកិច្ច និងសង្គម វប្បធម៌។ រក្សាតំបន់អាស៊ីអាគ្នេយ៍ ជាតំបន់គ្មានអាវុធនុយក្លេអ៊ែរ និងគ្មានអាវុធប្រល័យលោកផ្សេងៗទៀត។ ធានាថាប្រជាជននិងរដ្ឋសមាជិកអាស៊ានរស់

[4] ប្រការ៣ នៃសេចក្តីសម្រេចលេខ ១៣ សសរ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួល កិច្ចការបញ្ជូនកម្លាំងចូលរួមបេសកកម្មរក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ

នៅប្រកបដោយសន្តិភាពជាមួយពិភពលោកទាំងមូល ក្នុងបរិយាកាសយុត្តិធម៌ ប្រជាធិបតេយ្យ និងភាពសុខដុមរមនា។ បង្កើតទីផ្សាររួមមួយនិងមូលដ្ឋានផលិតកម្មរួម ដែលមានស្ថេរភាពវិបុលភាព មានការប្រកួតប្រជែងខ្ពស់ និងសមាហរណកម្មសេដ្ឋកិច្ចជាមួយនឹងការសម្របសម្រួលដ៏មានប្រសិទ្ធភាព សម្រាប់ពាណិជ្ជកម្ម និងការវិនិយោគដែលក្នុងនោះមានលំហូរដោយសេរីនូវទំនិញ សេវាកម្ម និងវិនិយោគសម្រួលចលនាពាណិជ្ជករ អ្នកមានវិជ្ជាជីវៈ អ្នកមានទេពកោសល្យ និងពលករ និងលំហូរដោយម្ចាស់ការនៃទុន។ កាត់បន្ថយភាពក្រីក្រ និងបង្រួមគម្លាតនៃការអភិវឌ្ឍនៅក្នុងតំបន់អាស៊ាន តាមរយៈការជួយគ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការ។ ពង្រឹងលទ្ធិប្រជាធិបតេយ្យលើកកម្ពស់អភិបាលកិច្ចល្អនិងនីតិរដ្ឋការពារ និងលើកកម្ពស់សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដោយយកចិត្តទុកដាក់ចំពោះសិទ្ធិ និងការទទួលខុសត្រូវរបស់រដ្ឋសមាជិកអាស៊ាន។[5]

- ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នចូលជាភាគីនៃអនុសញ្ញា ក្រុងវៀន ស្តីពីទំនាក់ទំនងការទូត (Vienna Convention on Diplomatic Relations 1961) នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៦៥។ ដោយជឿជាក់ថា អនុសញ្ញាអន្តរជាតិនេះ នឹង នាំអោយមានការប្រាស្រ័យទាក់ទងការទូត ព្រមទាំងមានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិការទូត និងរួមជាវិភាគទានដល់ការអភិវឌ្ឍន៍ទំនាក់ទំនងមិត្តភាពរវាងរដ្ឋ និងរដ្ឋ ដោយមិនគិតពីភាពខុសគ្នាអំពីប្រព័ន្ធរដ្ឋធម្មនុញ្ញ និងសង្គម។ គោលបំណងនៃ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ទាំងនេះពុំមែនផ្តល់ឲ្យ ដើម្បីជាអត្ថប្រយោជន៍ដល់បុគ្គលទេ ប៉ុន្តែគឺ ដើម្បីធានាបាននូវការបំពេញ ដោយមានប្រសិទភាព នូវមុខងាររបស់បេសកកម្មការទូត ក្នុងឋានៈជាតំណាង របស់រដ្ឋ។[6]

### ១.២. ប្រវត្តិនៃគោលនយោបាយការទូតកម្ពុជាជាមួយប្រទេសជិតខាង

នៅក្នុងមាត្រា៥៣ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រទេសកម្ពុជា រួមរស់សន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និង ប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក ដែលជា ការបង្ហាញអោយឃើញថា ប្រទេសកម្ពុជា មិនមែនទើបតែមានទំនាក់ទំនងជាមួយប្រទេសជិតខាងក្នុងពេលបច្ចុប្បន្ននេះទេ។

### ១.៣. ទំនាក់ទំនងរបស់កម្ពុជានិងចិន

ប្រទេសកម្ពុជា និងចិនជាប្រទេសជិតខាងល្អដែលមានប្រវត្តិទំនាក់ទំនងជាប្រពៃណី និងជាមេត្រីភាពតាំងពីយូរយារណាស់មកហើយ។ រហូតមកដល់ពេលនេះការផ្លាស់ប្តូរទំនាក់ទំនងទ្វេភាគី

[5] ធម្មនុញ្ញអាស៊ាន ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០០៨

[6] អនុសញ្ញា ក្រុងវៀន ស្តីពី ទំនាក់ទំនងការទូត (Vienna Convention on Diplomatic Relations 1961)

នេះ មានរយៈពេលជាង២០០០ឆ្នាំ ដោយបានបន្តនូវប្រវត្តិរឿងរ៉ាវជាគំរូល្អៗជាច្រើន ក្នុងប្រវត្តិសាស្ត្រ ដែលត្រូវបានកូនចៅជំនាន់ក្រោយអនុវត្តបន្តពីមួយជំនាន់ទៅមួយជំនាន់ទៀត។ នៅខែមេសា ឆ្នាំ ១៩៥៥ ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ** និងលោក **ចូវ អ៊ីនឡាយ** នាយករដ្ឋមន្ត្រីចិន បានជួបគ្នានៅក្នុងសន្និសីទអាស៊ីអាហ្វ្រិកនៅទីក្រុងបានឌុង ដែលប្រការនេះបានក្លាយទៅជាទីចាប់ផ្តើមថ្មីនៃទំនាក់ទំនងមេត្រីភាពរវាងប្រទេសចិននិងកម្ពុជា។ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ១៩៥៨ ប្រទេសកម្ពុជា និងចិនបានចាប់ផ្តើមមានទំនាក់ទំនងការទូតជាផ្លូវការ។ ចាប់តាំងពីមានចំណងទាក់ទងការទូតរយៈពេលជាងពាក់កណ្តាលសតវត្សរ៍កន្លងមកនេះ មិត្តភាពជាប្រពៃណីរវាងប្រទេសកម្ពុជា និងចិនដែលត្រូវសាងដោយថ្នាក់ដឹកនាំជំនាន់មុន និងថ្នាក់ថ្មមថៃរក្សាយ៉ាងយកចិត្តទុកដាក់ដោយថ្នាក់ដឹកនាំជំនាន់ក្រោយៗរបស់ប្រទេសកម្ពុជា និងចិនត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយឥតឈប់ឈរ។ ភាគីទាំងពីរមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយគ្នាលើគ្រប់វិស័យដូចជា ផ្នែកនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម វប្បធម៌មនុស្សជាតិ ព្រមទាំងកិច្ចការក្នុងតំបន់ និងអន្តរជាតិដោយទទួលបាននូវសមិទ្ធិផលយ៉ាងច្រើនទៀតផង។ ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ** ជាមិត្តភក្តិចាស់របស់ប្រជាជនចិន។ ថ្នាក់ដឹកនាំជំនាន់មុនៗរបស់ប្រទេសចិន សុទ្ធតែបានរឹតចំណងមិត្តភាពយ៉ាងជ្រាលជ្រៅជាមួយនឹងព្រះករុណា ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ** ដោយបានរួមវិភាគទានដែលមិនអាចបំភ្លេចបាន ក្នុងការបណ្តុះបណ្តាលបុព្វហេតុមិត្តភាពរវាងប្រទេសកម្ពុជា និងចិន។ ជាច្រើនទសវត្សរ៍កន្លងមកនេះ ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ** បានប្រកាន់ខ្ជាប់នូវគោលនយោបាយរាប់អានជាមួយប្រទេសចិនព្រមទាំងបានស្នាក់នៅក្នុងប្រទេសចិន អស់រយៈពេលជាយូរទៀតផង។ គួរឲ្យសោកស្តាយបំផុត គឺនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ទ្រង់បានយាងចូលទីវង្គតនៅក្រុងប៉េកាំង ប្រទេសចិន។ នាពេលនោះថ្នាក់ដឹកនាំប្រទេសសចិន បានរៀបចំពិធីរំលែកទុក្ខចំពោះការយាងចូលទិវង្គតរបស់ព្រះអង្គដោយឡែកនៅក្រុងប៉េកាំង ព្រមទាំងរៀបចំចាត់បញ្ជូនយន្តហោះពិសេសដើម្បីអមដំណើរព្រះមជ្ឈូសាររបស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ** យាងត្រឡប់ទៅកាន់រាជធានីភ្នំពេញវិញ។ នៅខែកុម្ភៈ ឆ្នាំ២០១៣ លោក ចា ឈាងលីន ប្រធានសភាប្រឹក្សានយោបាយប្រជាជនទូទាំងប្រទេសចិន ក៏បានអញ្ជើញទៅចូលរួមក្នុងព្រះរាជពិធីបូជាសពព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តមសីហនុ**នៅព្រះរាជាណាចក្រកម្ពុជាផងដែរ។

ប្រទេសកម្ពុជា ជាដៃគូរសហប្រតិបត្តិការដ៏សំខាន់របស់ប្រទេសចិន។ ថ្នាក់ដឹកនាំជាន់ខ្ពស់រវាងប្រទេសទាំងពីរតែងតែមានទំនាក់ទំនងគ្នាទៅវិញទៅមកជាញឹកញាប់។ នៅខែធ្នូ ឆ្នាំ២០១០ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញមកបំពេញទស្សនកិច្ច

នៅប្រទេសចិន ហើយប្រទេសទាំងពីរបានបង្កើនទំនាក់ទំនងភាពជាដៃគូសហប្រតិបត្តិការជាយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ។ ការប្រាស្រ័យទាក់ទងគ្នា ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការក្នុងកិច្ចការអន្តរជាតិ និងក្នុងតំបន់រវាងប្រទេសទាំងពីរកាន់តែមានភាពជិតស្និទ្ធពីមួយថ្ងៃទៅមួយថ្ងៃ។ ដោយឈរលើមតិឯកភាពរួមផ្នែកនយោបាយកម្រិតខ្ពស់ ភាគីទាំងពីរមានការយោគយល់គ្នា គោរពគ្នា និងផ្តល់ការគាំទ្រដល់គ្នាទៅវិញទៅមក រួមគ្នាគាំពារស្ថានការនៃទំនាក់ទំនងរវាងចិន និងអាស៊ាន ព្រមទាំងសុខសន្តិភាពនិងស្ថិរភាពក្នុងតំបន់ផងដែរ។

រហូតមកដល់ពេលបច្ចុប្បន្ន ប្រទេសទាំងពីរ កម្ពុជា និងចិន ទទួលបាននូវសមិទ្ធិផលជាផ្លែផ្កាយ៉ាងច្រើនសម្បូរបែប។ ប្រទេសចិនជាដៃគូពាណិជ្ជកម្មធំទីមួយ និងជាប្រទេសប្រភពនៃទុនបរទេសធំបំផុតរបស់ប្រទេសកម្ពុជា។ ឆ្នាំ២០១៥ ទំហំពាណិជ្ជកម្មទ្វេភាគីមានដល់ទៅ៤.៣២០ លានដុល្លារអាមេរិក។ នៅឆមាសទី១ ឆ្នាំ ២០១៦ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងចិន មានដល់ទៅ ២.៣៤០ លានដុល្លារអាមេរិក កើនឡើង ១០,២% បើប្រៀបធៀបនឹងដំណាក់កាលដូចគ្នានៅឆ្នាំទៅមិញ។ ប្រទេសទាំងពីរមានជំនឿចិត្តថា និងសម្រេចគោលដៅដែលមានទំហំពាណិជ្ជកម្មទ្វេភាគីចំនួន ៥.០០០ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៧។ គិតរហូតដល់ខែមិថុនា ឆ្នាំ២០១៦ ប្រាក់វិនិយោគទុនដោយផ្ទាល់របស់ប្រទេសចិននៅកម្ពុជាសរុបលើសពី ១២.០០០ លានដុល្លារអាមេរិក។

ការផ្លាស់ប្តូរខាងវប្បធម៌មនុស្សជាតិរវាងប្រទេសទាំងពីរត្រូវ ពង្រីកដោយឥតឈប់ឈរ។ ចាប់ពីខែមករា ដល់ខែកក្កដា ឆ្នាំ២០១៦ ចំនួនភ្ញៀវទេសចរណ៍ចិនដែលធ្វើទេសចរណ៍នៅកម្ពុជាមានដល់ទៅ ៤៤,៤៩ម៉ឺននាក់ ដែលកើនឡើង ១២,៤% បើប្រៀបធៀបនឹងដំណាក់កាលដូចគ្នានៅឆ្នាំទៅមិញ។ ជារៀងរាល់ថ្ងៃមានជើងយន្តហោះចំនួន៣៥ ធ្វើការហោះហើរទៅមករវាងប្រទេសចិន និងកម្ពុជា ហើយក្នុងនោះមានទីក្រុងរបស់ប្រទេសចិនជាង១០ ដែលមានជើងហោះហើរមកកាន់កម្ពុជាដោយផ្ទាល់។ ជាមួយគ្នានេះដែរ ទ្រង់ទ្រាយនៃការចាត់បញ្ជូនផ្លាស់ប្តូរនិស្សិតឲ្យបន្តការសិក្សា និងការបណ្តុះបណ្តាលធនធានមនុស្សរវាងប្រទេសទាំងពីរត្រូវបានពង្រីកដោយឥតឈប់ឈរ។ ស្របពេលជាមួយគ្នានេះ វិទ្យុអន្តរជាតិចិនបានបង្កើតវិទ្យុមិត្តភាពកម្ពុជា-ចិនដែលជាវិទ្យុFM ប្រចាំនៅរាជធានីភ្នំពេញ និងខេត្តសៀមរាបជាបន្តបន្ទាប់ ដែលបានបង្កើតជាស្ពានសម្រាប់ការយោគយល់គ្នារវាងប្រជាជននៃប្រទេសទាំងពីរ។ កន្លងមក កម្មវិធីផ្សាយរបស់វិទ្យុមិត្តភាពកម្ពុជា-ចិន បានទទួលការស្វាគមន៍និងស្រឡាញ់ចូលចិត្តយ៉ាងខ្លាំងពីប្រិយមិត្តអ្នកស្តាប់ខ្មែរ។ មិនថាស្ថិតនៅក្នុងកាលៈទេសៈណា ភាគីចិនតែងតែផ្តោតការយកចិត្តទុកដាក់ទៅលើទំនាក់ទំនងជាមួយប្រទេសកម្ពុជាដោយផ្តល់ការជ្រោមជ្រែងគាំទ្រដល់ប្រទេសកម្ពុជាក្នុងការដើរតាមមាគ៌ាអភិវឌ្ឍន៍ ដោយសមស្របនឹងស្ថានភាពរបស់ប្រទេសខ្លួន។ ជាពិសេសផ្តល់ការគាំទ្រដល់ប្រទេសកម្ពុជាក្នុងការរក្សាស្ថិរភាព និងពន្លឿន

ការអភិវឌ្ឍ ធ្វើឲ្យកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរវាងប្រទេសកម្ពុជា និងចិនឲ្យកាន់តែមានភាពស៊ីជម្រៅដោយមិនងាករេ។ ព្រមជាមួយគ្នានេះ សហគ្រាសចិនបានជួយកសាងស្ពាន និងផ្លូវថ្នល់នៅប្រទេសកម្ពុជា ដោយបានរួមវិភាគទានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកែលម្អជីវភាពរស់នៅរបស់ប្រជាជន នៃប្រទេសកម្ពុជាផងដែរ។ ដោយសារកសិកម្មកម្ពុជានៅមានភាពទន់ខ្សោយបន្តិច ប្រទេសចិនបានផ្តល់ការជួយឧបត្ថម្ភគ្រប់បែបយ៉ាងលើវិស័យកសិកម្មដល់កម្ពុជា ដែលក្នុងនោះរួមមានទាំងបច្ចេកទេសដាំដំណាំ ប្រព័ន្ធធារាសាស្ត្រ និងការនាំចេញអង្ករជាដើមដោយបានផ្តល់នូវការជួយជ្រោមជ្រែងយ៉ាងជាក់ស្តែងដល់កសិករកម្ពុជា។ ដោយឡែកភាគីកម្ពុជា ក៏បានផ្តោតសំខាន់ដល់ការអភិវឌ្ឍទំនាក់ទំនងជាមួយប្រទេសចិនផងដែរ ដោយបានផ្តល់ការគាំទ្រយ៉ាងម៉ឺងម៉ាត់ដល់ភាគីចិនក្នុងបញ្ហាធំៗនិងសំខាន់ៗ ដែលប្រទេសចិនយកចិត្តទុកដាក់បំផុតដូចជា បញ្ហាសមុទ្រចិនខាងត្បូង និងបញ្ហាតៃវ៉ាន់ជាដើម។ កាលពីថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ ព្រះករុណាព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា បានយាងចូលរួមក្នុងមហាសន្និបាតរំលឹកខួបទី៧០ឆ្នាំនៃការទទួលជ័យជម្នះក្នុងសង្គ្រាមប្រឆាំងនឹងជប៉ុនរបស់ប្រជាជនចិន និងសង្គ្រាមប្រឆាំងនឹងហ្វាស៊ីសពិភពលោក។ ប្រទេសកម្ពុជា បានគាំទ្រនូវគំនិតផ្តួចផ្តើមអំពីយុទ្ធសាស្ត្រ "ខ្សែក្រវាត់មួយ និងផ្លូវមួយ" និងចូលរួមយ៉ាងសកម្មជាមួយធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ីដែលលើកឡើងដោយប្រទេសចិន។ ជាពិសេសសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា ក៏បានអញ្ជើញចូលរួមក្នុងពិព័រណ៍ពាណិជ្ជកម្ម ចិន-អាស៊ានជារៀងរាល់ឆ្នាំ និងវេទិកាអាស៊ីប៊ូអាវផងដែរ។ កាលពីខែមីនា ឆ្នាំ២០១៦កន្លងទៅនេះ សម្តេចតេជោ បានអញ្ជើញចូលរួមក្នុងសន្និសិទថ្នាក់ដឹកនាំលើកដំបូងស្តីពី យន្តការនៃកិច្ចសហប្រតិបត្តិការទន្លេឡានឆាង និង ទន្លេមេគង្គនៅប្រទេសចិន។ ម្យ៉ាងទៀត ភាគីកម្ពុជាក៏បានរួមសហការជាមួយភាគីចិនក្នុងការបង្ក្រាបលើករណីបោកបញ្ឆោតតាមបណ្តាញអ៊ីនធើណេត និងទូរគមនាគមន៍ និងផ្តល់ការគាំទ្រយ៉ាងម៉ឺងម៉ាត់ដល់ប្រទេសចិនក្នុងការរួមសហការតាមដានចាប់ខ្លួនមន្ត្រីស៊ីសំណូក ដែលរត់គេចខ្លួននៅឯនាយសមុទ្រទៀតផង។ មិនត្រឹមតែប៉ុណ្ណោះ ក្នុងខណៈដែលប្រទេសចិនកើតនូវគ្រោះមហន្តរាយធម្មជាតិ ព្រះករុណា ព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហនុ** បានបរិច្ចាគប្រាក់ជាច្រើនលើកដល់តំបន់រងគ្រោះរបស់ប្រទេសចិន។ នៅខែកក្កដា ឆ្នាំ២០១៦ ព្រះករុណា ព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** ព្រះវរៈរាជមាតាជាតិខ្មែរ បានបរិច្ចាគប្រាក់ដល់តំបន់រងគ្រោះដោយសារទឹកជំនន់នៅប្រទេសចិនផងដែរ។ ជាមួយគ្នានេះគ្រប់មជ្ឈដ្ឋានក្នុងសង្គមកម្ពុជាបានយកចិត្តទុកដាក់ដល់តំបន់រងគ្រោះដោយធម្មជាតិរបស់ប្រទេសចិន និងបានផ្តល់ការជួយជ្រោមជ្រែងបាន

ទាន់ពេលវេលាទៀតផង។ ព្រមជាមួយគ្នានេះដែរ ភាគីកម្ពុជាក៏បានដើរតួនាទីជាវិជ្ជមានក្នុងការគាំពារនិងជំរុញការអភិវឌ្ឍទំនាក់ទំនងរវាងចិន-អាស៊ានទៀតផង។

កាលពីខែធ្នូ ឆ្នាំ២០០៩ ឯកឧត្តម ស៊ី ជីនភីង ប្រធានរដ្ឋចិនដែលកាលនេះលោកជាអនុប្រធានរដ្ឋចិន បានអញ្ជើញមកបំពេញទស្សនៈកិច្ចនៅប្រទេសកម្ពុជា។ ដោយឡែកសម្រាប់ដំណើរទស្សនៈកិច្ចរបស់ឯកឧត្តម **ស៊ី ជីនភីង** លើកនេះ គឺជាទស្សនៈកិច្ចលើកដំបូងដែលថ្នាក់ដឹកនាំសំខាន់ៗរបស់ប្រទេសចិន និងអញ្ជើញមកបំពេញទស្សនៈកិច្ចនៅកម្ពុជា ក្រោយពីចាប់ផ្តើមបង្កើតក្រុមថ្នាក់ដឹកនាំអាណត្តិថ្មីរបស់ប្រទេសចិន កាលពីខែវិច្ឆិកា ឆ្នាំ២០១២។ ដំណើរទស្សនៈកិច្ចលើកនេះ មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ពង្រឹង និងពង្រីកមិត្តភាពជាប្រពៃណីរវាងប្រទេសទាំងពីរ កម្ពុជានិងចិន ហើយក៏នឹងអាចជំរុញធ្វើឲ្យកិច្ចសហប្រតិបត្តិការ ជាយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរវាងប្រទេសទាំងពីរមានភាពកាន់តែស៊ីជម្រៅថែមទៀតផង។ ក្នុងអំឡុងពេលបំពេញទស្សនៈកិច្ចនេះដែរ ឯកឧត្តម ស៊ី ជីនភីង ប្រធានរដ្ឋចិន នឹងចូលថ្វាយបង្គំគាល់ព្រះករុណា ព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសួរសុខទុក្ខសម្តេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** ព្រះវរៈរាជមាតាជាតិខ្មែរ ព្រមទាំងជួបធ្វើកិច្ចសន្ទនាជាមួយនឹងសម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងចូលរួមក្នុងពិធីចុះហត្ថលេខាលើឯកសារស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ក្នុងន័យជំរុញឲ្យយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា និងចិន តភ្ជាប់គ្នាយ៉ាងរឹងមាំ និងធ្វើឲ្យកិច្ចសហប្រតិបត្តិការជាក់ស្តែងលើគ្រប់វិស័យកាន់តែមានភាពស៊ីជម្រៅ ហើយទទួលបាននូវសមិទ្ធិផលថ្មីៗថែមទៀត។

## ១.៤. ទំនាក់ទំនងកម្ពុជានិងវៀតណាម

យោងតាមសេចក្តីក្រាបបង្គំគាល់ និងយោងពីឯកឧត្តម ង្វៀន ហ្វូចុក អគ្គលេខាធិការបក្សប្រមុខរដ្ឋ នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ព្រះករុណា ព្រះបាទសម្តេច **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត បានចាប់ផ្តើមបំពេញទស្សនៈកិច្ចផ្លូវការហើយ នៅប្រទេសវៀតណាម ចាប់ពីថ្ងៃទី១៩ រហូតដល់ថ្ងៃទី២១ធ្នូឆ្នាំ២០១៨នេះ។ ប្រទេសកម្ពុជា និងប្រទេសវៀតណាម ជាប្រទេសជួមជងរបងជាមួយគ្នាដែលមានព្រំដែន ប្រវែង១ពាន់១៣៧គីឡូម៉ែត្រមានទន្លេមេគង្គហូរកាត់រវាងប្រទេសទាំង២។

នៅក្នុងប្រវត្តិសាស្ត្រពីទំនាក់ទំនង កម្ពុជា និងវៀតណាមធ្លាប់ឆ្លងកាត់នូវការតស៊ូរួមលេនដ្ឋានតែមួយ ប្រឆាំងនឹងអានិគមនិយមចាស់ថ្មី។ ផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ហើយរហូតមកដល់សព្វថ្ងៃនេះ ប្រទេសទាំងពីរ បានរួមសហប្រតិបត្តិការកសាងប្រទេស ដើម្បីភាពសម្បូររុងរឿងនៃប្រជាជាតិរៀងៗខ្លួន និងសុភមង្គលរបស់ប្រជាជន នៃប្រទេសទាំង២កម្ពុជាវៀតណាម។

កម្ពុជា-វៀតណាម បានបង្កើតចំណងទាក់ទងការទូតផ្លូវការកាលពី២៤ មិថុនា ឆ្នាំ១៩៦៧ ដែលកាលនោះ ព្រះរាជាអាណាចក្រកម្ពុជា មានសម្តេច **ព្រះនរោត្តម សីហនុ** ជាព្រះប្រមុខរដ្ឋ និង លោកហូជីមិញ ជាប្រមុខរដ្ឋ នៃសាធារណៈរដ្ឋប្រជាធិបតេយ្យវៀតណាម (បច្ចុប្បន្នសាធារណៈរដ្ឋសង្គមនិយមវៀតណាម)។ ទំនាក់ទំនង ប្រទេសទាំងពីរបានរីកចម្រើនឡើង ជាលំដាប់រហូតមកទល់សព្វថ្ងៃនេះ ដែលយើងបានឃើញថាថ្មីៗនេះ សម្តេចតេជោ **ហ៊ុន សែន** បានបំពេញទស្សនៈកិច្ចផ្លូវការនៅទីក្រុងហាណូយ តាមការអញ្ជើញ របស់ឯកឧត្តម ង្វៀន ស៊ុនហ្វុក នាយករដ្ឋមន្ត្រីវៀតណាម ដែលនៅទីនោះ មានកិច្ចព្រមព្រៀងសំខាន់ៗ មួយចំនួនត្រូវបានចុះហត្ថលេខារវាងរដ្ឋមន្ត្រី និងប្រធានស្ថាប័ននានា នៃរដ្ឋាភិបាលប្រទេសទាំងពីរ ដើម្បីជាប្រយោជន៍ នៃកិច្ចសហប្រតិបត្តិការបន្ថែមទៀត ជាពិសេសឆ្ពោះទៅកាន់ការផ្លាស់ប្តូរពាណិជ្ជកម្មប្រទេសទាំងពីរឲ្យសម្រេចបាន ៥ពាន់លានដុល្លារនៅឆ្នាំ ២០២០ខាងមុខ។

ទស្សនៈកិច្ចចុងក្រោយ របស់ព្រះមហាវីរៈក្សត្រ **នរោត្តម សីហនុ** និងហ្លួងម៉ែ បានបំពេញព្រះរាជទស្សនៈកិច្ចផ្លូវការកាលពីថ្ងៃទី២២ ដល់២៥មិថុនា ២០១០ ដែលនៅគ្រានោះ ព្រះករុណា **សម្តេច សីហមុនី** បានដង្ហែរព្រះរាជដំណើររបស់មាតាបិតាទ្រង់នៅឯរដ្ឋធានីហាណូយ។ ក្រោយកម្ពុជា មានកិច្ចបង្រួបបង្រួមជាតិ នាឆ្នាំ១៩៩៣ មេដឹកនាំវៀតណាមប្រកាសជាសាធារណៈថា **សម្តេច នរោត្តម សីហនុ** និងប្រជាជនកម្ពុជា ជាអ្នកមានគុណបំណាច់លើប្រទេសវៀតណាម ក្នុងការតស៊ូប្រឆាំងនឹងបរទេសឈ្លានពាន និងសម្រេចបានឯកភាពជាតិនាឆ្នាំ១៩៧៥។

## ១.៥. ទំនាក់ទំនងកម្ពុជានិងអាល្លឺម៉ង

បើរាប់ពីឥឡូវទៅវាហួសពេលយូរណាស់មកហើយ ចាប់តាំងពីបុរាណវិទូជនជាតិអាល្លឺម៉ង់ឈ្មោះលោក Adolf Bastian បានកំណត់នូវឫសគល់ហិណ្ឌូនៅក្នុងអរិយធម៌អង្គរនៅឆ្នាំ ១៨៦៣។

លោក John Clamp បានពិនិត្យមើលប្រវត្តិសាស្ត្រនៃទំនាក់ទំនងរវាងមហាអំណាចក្បាលម៉ាស៊ីនអ្នកផលិតនៅទ្វីបអឺរ៉ុប និងព្រះរាជាណាចក្រកម្ពុជា។

ទំនាក់ទំនងរវាងកម្ពុជា និងអាល្លឺម៉ង់មានប្រវត្តិគួរឲ្យចាប់អារម្មណ៍ បើទោះបីជាប្រទេសប៉ែកអាស៊ីអាគ្នេយ៍ស្ថិតនៅក្រោមឥទ្ធិពលនៃអាណានិគមនិយមបារាំងក៏ដោយ។

អាល្លឺម៉ង់ខាងលិច (សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ឬ ហៅខ្លីថា BDR សម្រាប់ Bundesrepublik Deutschland) បានបង្កើតទំនាក់ទំនងការទូតជាផ្លូវការជាមួយកម្ពុជានៅឆ្នាំ ១៩៦៧។

នៅសម័យនោះសង្គ្រាមត្រជាក់កំពុងស្ថិតក្នុងសកម្មភាពពេញទំហឹងដោយសង្គ្រាមវៀតណាម ទើបតែចាប់ផ្តើមក្តៅរក្លាយ៉ាងខ្លាំង ខណៈពេលប្រធានាធិបតីអាមេរិកលោក Lyndon Johnson

បានបង្កឲ្យមានភាពតានតឹងកាន់តែខ្លាំងជាមួយនឹងវៀតណាមខាងជើង ដោយការបញ្ជូនកងទ័ព កាន់តែច្រើនឡើងៗទៅក្នុងប្រទេសដែលកំពុងស្ថិតក្នុងការបំបែកមួយនេះ។

សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ (ឬហៅកាត់ថា DDR ហើយជាទូទៅត្រូវបានគេស្គាល់ថាជាអាល្លឺម៉ង់ខាងកើត) បានបញ្ជូនបេសកកម្មការទូតជាផ្លូវការជាលើកដំបូងមកកាន់ព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ ១៩៦៩ ដូច្នេះវាជាការចាប់ផ្តើមទំនាក់ទំនងមួយនៃប្រវត្តិសាស្ត្ររបស់ប្រទេសអាល្លឺម៉ង់ និងប្រទេសកម្ពុជា។ ពេលនោះវាត្រូវបានបែងចែកជាពីរ ដោយមានបេសកកម្មស្របគ្នានៅទីក្រុងភ្នំពេញពីប្រទេសអាល្លឺម៉ង់ទាំងពីរប៉ែកនេះ គឺអាល្លឺម៉ង់ខាងកើត និងខាងលិច។

DDR បានស្ថាបនាទំនាក់ទំនងជាមួយព្រះបាទនរោត្តម សីហនុ នៅទសវត្សរ៍ឆ្នាំ ១៩៥០ ហើយនៅឆ្នាំ ១៩៦០ ពួកគេបានចុះហត្ថលេខាលើសន្ធិសញ្ញាពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយកម្ពុជា។ ស្ថានកុងស៊ុលមួយបានស្ថាបនាឡើងក្រោយពេលចុះហត្ថលេខានេះនៅឆ្នាំ ១៩៦២។ ទំនាក់ទំនងរបស់អាល្លឺម៉ង់ខាងកើតជាមួយប្រទេសកម្ពុជាប្រហែលជាគួរឲ្យចាប់អារម្មណ៍ជាងទំនាក់ទំនងកម្ពុជាជាមួយអាល្លឺម៉ង់ខាងលិច។



កម្ពុជាប្រជាធិបតេយ្យ (ឈ្មោះដែលរបបខ្មែរក្រហមបានហៅខ្លួនឯង) បានផ្តាច់ទំនាក់ទំនងការទូតជាមួយបណ្តាប្រទេសចូលសម្ព័ន្ធ Warsaw ក្នុងអំឡុងពេលគ្រប់គ្រងប្រទេសរបស់ខ្លួន ពីព្រោះភាពស្និទ្ធស្នាលរបស់ខ្មែរក្រហមជាមួយប្រទេសចិនមានន័យថាអ្វីៗនឹងដើរតាមខ្សែបន្ទាត់ប្រឆាំងសម្ព័ន្ធ Comitern ដូចប្រទេសចិនដែរ។

ក្នុងនាមជាអ្នកថតរូបសារពត៌មាន លោក Al Rockoff បានរំឭកពីព្រឹត្តិការណ៍នៅឆ្នាំ ១៩៧៥ ថា ៖ «ពួកជនជាតិអាល្លឺម៉ង់ខាងកើតត្រូវបានគេបង្ខំឲ្យចេញពីស្ថានទូតរបស់ខ្លួនក្រោមការភ្ជង់កាំភ្លើងដោយទាហានខ្មែរក្រហម ហើយពួកគេត្រូវបានបញ្ជូនទៅស្ថានទូតបារាំងដោយសារតែហេតុការណ៍នេះពួកគេមានការអន់ចិត្តយ៉ាងខ្លាំងចំពោះព្រឹត្តការណ៍មួយនេះ។ ពួកគេពិតជាមានអារម្មណ៍គុំ

ណាស់។ ខ្ញុំចងចាំពីកំហឹងរបស់អាល្លឺម៉ង់ខាងកើត ព្រោះអីស្ថានតែពួកខ្លួនជិះយន្តហោះមកដើម្បីអបអរសាទរជ័យជម្នះ តែផ្ទុយទៅវិញពួកគេមិនទាំងនឹងបានត្រូវគេអញ្ជើញផង»។

ប៉ុន្តែនៅពេលដែលវៀតណាមបានឈ្លានពានប្រទេសកម្ពុជា ទំនាក់ទំនងជិតស្និទ្ធរបស់អាល្លឺម៉ង់ខាងកើតជាមួយក្រុងហាណូយគឺបន្ទាប់ពីសហភាពសូវៀត ពួកគេនឹងហើយដែលជាសម្ព័ន្ធមិត្តមានឥទ្ធិពលបំផុតនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលទើបតែត្រូវបានបង្កើតមួយនេះ បន្ទាប់ពីប្រទេសនេះត្រូវបានគេដាក់ឈ្មោះឲ្យក្រោយឆ្នាំ ១៩៧៨។ នេះគឺដោយសារតែ PRK គឺស្ថិតនៅដាច់តែឯងនៅក្រោមការគ្រប់គ្រងរបស់វៀតណាមក៏ដូចតែនៅក្រោមរបបខ្មែរក្រហមដែរ។ ការចងចាំនៃសង្គ្រាមវៀតណាមនៅតែស្រស់ៗនៅឡើយនៅក្នុងគំនិតរបស់អ្នកបង្កើតគោលនយោបាយអាមេរិក ហើយប្រទេសមហាអំណាចមួយនេះបានប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការធ្វើឲ្យមានជីវភាពលំបាកបំផុតសម្រាប់កងកម្លាំងឈ្លានពានរបស់វៀតណាម។



អតីតក្រុមនិស្សិតខ្មែរនៅប្រទេសអាល្លឺម៉ង់ខាងកើតកាលពីអំឡុងទសវត្សរ៍ឆ្នាំ ១៩៨០-៩០។ រូបថតសហការីនៅក្នុងចំណោមទិដ្ឋភាពនយោបាយតាមតំបន់ដែលស្មុគស្មាញបំផុតនៃសតវត្សរ៍ទី ២០ ត្រូវបានទីភ្នាក់ងារចារកម្មកណ្តាលអាមេរិកបានចាប់ផ្តើមផ្តល់មូលនិធិ និងបំពាក់អាវុធជាសម្ងាត់ដល់ពួកខ្មែរក្រហមដែលពេលនោះត្រូវបានបង្ខាំងទុកនៅតាមបណ្តាខេត្តជាយៗរបស់ប្រទេសកម្ពុជាជិតព្រំដែនថៃ។ តាមការពិតការគាំទ្រដល់ពួកខ្មែរក្រហមគឺមានលក្ខណៈទ្វេភាគីដោយជនជាតិចិន ក៏បានគាំទ្រពួកខ្មែរក្រហមដែលសម្លាប់មនុស្សរាប់លាននាក់នេះដែរ។

ការមិនមានប្រជាប្រិយភាព និងអំពើពុករលួយជាប្រព័ន្ធយ៉ាងជ្រាលជ្រៅរបស់ខ្មែរក្រហមមានន័យថាក្រៅពីគ្រាប់មីនរាប់លានគ្រាប់ដែលទទួលបានពីពួកអាមេរិក និងចិនប្រតិបត្តិការតស៊ូយ៉ាងក្រឡេះបេះរបស់ពួកគេមិនមានសមត្ថភាពគ្រប់គ្រាន់ដើម្បីផ្តួលរំលំ PRK ដែលមានខ្នងជាវៀតណាមនោះទេ។ ផ្ទុយទៅវិញពួកគេនៅតែមានបន្តធ្វើជាបន្លារចំពោះរដ្ឋាភិបាល និងវៀតណាមដូចដែលអ្នកគាំទ្ររបស់ខ្មែរក្រហមនៅលើពិភពលោកចង់បានដែរ។

មេបញ្ជាការកងទ័ពខ្មែរក្រហមបានក្លាយជាមានទ្រព្យសម្បត្តិស្តុកស្តម្ភពីការលក់នូវបរិមាណដ៏ច្រើននៃអាវុធដែលពួកគេបានប្រគល់ឲ្យកងទ័ពភូមិន្ទថៃ ដែលជាច្រកដើមសម្រាប់ការផ្គត់ផ្គង់របស់ពួកគេ។

បន្ទាប់មកពួកគេបានដឹកអាវុធនោះឆ្លងកាត់ប្រទេសថៃនៅទិសពាយព្យដែលនៅទីនោះពួកគេលក់អាវុធបានប្រាក់ចំណេញដ៏ច្រើនដល់ក្រុមឧទ្ទាមភូមា ដូចជាក្រុមខារ៉ែន។ ពួកគេក៏បានទន្ទ្រានកាប់ឈើប្រណីតជាច្រើន ហើយក៏បានលក់ទៅឲ្យកងទ័ពថៃពុករលួយមួយចំនួនផងដែរ។



គ្រូពេទ្យអាល្លឺម៉ង់នៅក្នុងសម័យ UNTAC កំពុងចែកថ្នាំដល់ប្រជាជនកម្ពុជា។ រូបថត សហការី

នៅពេលដែលវៀតណាមបានដំឡើងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងអតីតមេបញ្ជាការខ្មែរក្រហមដទៃទៀតឲ្យឡើងកាន់អំណាចនៅក្នុង PRK រដ្ឋាភិបាលនេះបានចាប់ផ្តើមទទូចឲ្យអាល្លឺម៉ង់ខាងកើតផ្តល់ជាជំនួយដល់ពួកគេជាមួយនឹងការជួយធានាសន្តិសុខផ្ទៃក្នុងរបស់ប្រទេស។ ដោយសារតែភាពល្បីល្បាញរបស់អង្គការសន្តិសុខរដ្ឋ Stasi របស់អាល្លឺម៉ង់ខាងកើតក្នុងការថែរក្សាសន្តិសុខក្នុងស្រុកនេះហើយទើបរបប PRK ជឿថាគ្មាននរណាម្នាក់ដែលអាចបង្ហាត់បង្រៀននគរបាលសម្ងាត់ និងកងកម្លាំងសន្តិសុខរបស់ពួកគេបានល្អដូចពួកនេះទេ។

អ្នកការទូតមកពីប្រទេសអាល្លឺម៉ង់ដែលទើបតែនឹងរួបរួមថ្មីៗនោះមិនបានបង្កើតស្ថានទូតនៅភ្នំពេញរហូតដល់ឆ្នាំ ១៩៩៣ តែប្រទេសអាល្លឺម៉ង់បានគាំទ្រដល់បេសកកម្មអន្តរកាលអ៊ុនតាក់របស់អង្គការសហប្រជាជាតិនៅកម្ពុជាចាប់ពីឆ្នាំ ១៩៩១ ដល់ឆ្នាំ ១៩៩៣ ដោយការបញ្ជូនទាហានពេទ្យដើម្បីទ្រទ្រង់ដល់ប្រតិបត្តិការនេះ។ វាជាការដាក់ពង្រាយកងទ័ពទៅក្រៅប្រទេសជាលើកដំបូងរបស់ប្រទេសអាល្លឺម៉ង់ចាប់តាំងពីសង្គ្រាមលោកលើកទីពីរមក។

ចាប់តាំងពីពេលនោះមកសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់បានដើរតួនាទីយ៉ាងសកម្មក្នុងការកសាងជីវិតធម្មតាឡើងវិញនៅប្រទេសកម្ពុជា។

# ជំពូកទី ២

# ការអភិវឌ្ឍវិស័យការទូត

# ជំពូកទី២ ៖ ការអភិវឌ្ឍន៍វិស័យការទូត

## ២.១. វិសាលភាពនៃទំនាក់ទំនងការទូតទ្វេភាគី

ប្រទេសកម្ពុជា មានទំនាក់ទំនងជាច្រើនជាមួយប្រទេសដ៏ទៃដោយមិនប្រកាន់ ពីភាព ខុសគ្នារវាងនយោបាយ និងរដ្ឋធម្មនុញ្ញ ទើបធ្វើអោយកម្ពុជា មានវិសាលភាពយ៉ាងទូលំទូលាយ ជាមួយប្រទេសដ៏ទៃ និងប្រទេសជិតខាងដែលជាហេតុបង្កើតបាននូវចំណងទំនាក់ទំនងយ៉ាងល្អដែល គួរអោយកត់សម្គាល់។ លើសពីនេះទៀត យើងឃើញថាកម្ពុជា មានសន្ទុះស្ទើរគ្រប់វិស័យដែលសុទ្ធសឹង តែជាការអភិវឌ្ឍដែលអាចជួយអោយកម្ពុជាមានការរីកចម្រើន និងជាដៃគូរសហការដ៏ល្អជាមួយប្រទេសមួយចំនួនទៀតដែលជំរុញអោយមានការកាន់តែវិវត្តន៍ទៅមុខ។ ជាក់ស្តែង កម្ពុជាមានទំនាក់ទំនងជាមួយប្រទេសជាច្រើន ដោយយើងនិងលើកយកប្រទេសមួយចំនួនមកបង្ហាញ ដូចជា៖

### ២.១.១. ទំនាក់ទំនងការទូតកម្ពុជានិងប្រទេសជិតខាង

ក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ យើងឃើញថាកម្ពុជាបានរីកដុះដាលយ៉ាងខ្លាំងដោយមានការសហការជាមួយប្រទេសជិតខាង ក្នុងការជំរុញអោយមានការពិភាក្សាលើការលើកស្ទួយ និងការលើកកម្ពស់នៅវិស័យផ្សេងៗបន្ថែម ក្នុងនោះយើងមានដៃគូរសហការជាច្រើន និងជាដៃគូរដែលមានការសហការល្អលើការវិនិយោគ ពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម និងមានការបង្កើតនូវហេដ្ឋានសម្ព័ន្ធជាច្រើនទៀត ជំរុញអោយទីផ្សារអន្តរជាតិកាន់តែស្គាល់កម្ពុជាកាន់តែច្បាស់ដែលនិងបន្តអោយ កម្ពុជាទទួលបានលទ្ធផលល្អលើវិស័យសេដ្ឋកិច្ច និងជាឪកាសដ៏ល្អមួយដែលកម្ពុជានិងអាចបង្ហាញពីស្នាដៃរបស់ខ្លួនអោយប្រទេសជិតខាងបានដឹងពីសក្តានុពល នៃកម្ពុជា។

### ២.១.២. កិច្ចសហប្រតិបត្តិការទ្វេភាគី

គិតមកដល់ឆ្នាំ២០១៦ កម្ពុជាបានភ្ជាប់ទំនាក់ទំនងការទូតជាមួយប្រទេសទាំងអស់ក្នុងពិភពលោកចំនួន១៧១ប្រទេស និងបានបង្កើតគណៈកម្មាការអន្តររដ្ឋាភិបាលជាមួយប្រទេសចំនួន២

គណៈកម្មាការចម្រុះទ្វេភាគីជាមួយប្រទេសចំនួន១១ និងកិច្ចពិគ្រោះយោបល់នយោបាយជាមួយ១៨ប្រទេស។ ទន្ទឹមនិងនេះ កម្ពុជាមានស្ថានតំណាងនៅបរទេសចំនួន៥៥ (ស្ថានទូតចំនួន២៤ ស្ថានតំណាងអចិន្ត្រៃយ៍ចំនួន៤ ស្ថានអគ្គកុងស៊ុល១០ និងស្ថានកុងស៊ុលកិត្តិយស១៧)។

តាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជាបានទទួលផលប្រយោជន៍ជាជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសក្នុងវិស័យជាច្រើន ដូចជា ហេដ្ឋានរចនាសម្ព័ន្ធ ការអភិវឌ្ឍន៍ធនធានមនុស្ស អប់រំ សុខាភិបាល កសិកម្ម អភិវឌ្ឍន៍ជនបទ ។ល។ ទន្ទឹមនឹងនេះ ការផ្លាស់ប្តូរវប្បធម៌ ពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍បរទេសមកទស្សនានៅកម្ពុជាកាន់តែមានការកើតឡើង។

## ២.១.៣. កិច្ចសហប្រតិបត្តិការនៅតំបន់ទ្វេភាគីនៅតំបន់អាស៊ី

ប្រទេសសំខាន់ៗដែលជាដៃគូរអភិវឌ្ឍន៍មានដូចតទៅៈ

- **ជាមួយប្រទេសចិន**

ជាការគួរអោយកត់សម្គាល់ទំនាក់ទំនងអន្តរជាតិមិត្តភាពជាប្រពៃណី និងកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កា កម្ពុជា-ចិន ត្រូវបានពង្រឹងពង្រីក និងអោយកាន់តែស៊ីជម្រៅថែមទៀតរហូតឈានដល់កម្រិត "ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ" កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០។ ក្នុងឪកាសទស្សនៈកិច្ចផ្លូវរដ្ឋរបស់ ឯកឧត្តមប្រធានាធិបតី ស៊ី ជីនពីន កាលពីខែតុលា ឆ្នាំ២០១៦ ឯកសារកិច្ចសហប្រតិបត្តិការចំនួន៣១ លើវិស័យសាធារណៈ និងវិស័យឯកជនត្រូវបានចុះហត្ថលេខា។ រដ្ឋាភិបាលចិនបានផ្តល់ចំណងឥតសំណងចំនួន ១២០០លានយ័នសម្រាប់ការសាងសង់អាគារមន្ទីរពេទ្យ មិត្តភាពកម្ពុជា-ចិន មន្ទីរពេទ្យត្បូងឃ្មុំ និងកម្ចីសម្បទានប្រមាណ ២៩០លានៀដុល្លាអាមេរិចសម្រាប់អភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រវៃកូជំហានទី២ ការសាងសង់ផ្លូវ និងខ្សែបណ្តាញ អគ្គីសនី និងផ្តល់អាហារូបករណ៍ដល់និស្សិតកម្ពុជា ប្រមាណជា២០០នាក់ (២០១៦-២០១៧)។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៦ ទំហំពាណិជ្ជកម្មកម្ពុជា-ចិន បានកើនឡើងលើស៥ពាន់ដុល្លារអាមេរិច។

ប្រទេសចិន គឺជាមហាអំណាចសកលលោក ដែលប្រទេសកម្ពុជា មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ។ នៅខែធ្នូ ឆ្នាំ២០១០ ប្រទេសទាំងពីរ បានបង្កើនទំនាក់ទំនងទៅដល់កម្រិត "ភាពដៃគូរជាយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ"។ ពាណិជ្ជកម្ម រវាងប្រទេសទាំងពីរ បានរីកធំធាត់ពី ២.៣៥ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១២ ទៅប្រមាណជា ៣.៣ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ ២០១៣ ជាមួយនឹងកិច្ចព្រមព្រៀងបង្កើនពាណិជ្ជកម្មរហូតដល់ ៥ប៊ីលានដុល្លារអាមេរិក នៅត្រឹមឆ្នាំ២០១៧។

វិនិយោគចិន នៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនៃប្រទេសកម្ពុជា មានចំនួនច្រើនគួរជាទីកត់សម្គាល់។

ឧទាហរណ៍ៈ តាមរបាយការណ៍ ក្រុមហ៊ុនចិន បានវិនិយោគជាង ១.៦ប៊ីលានដុល្លារ ដើម្បីសាងសង់ទំនប់វារីអគ្គិសនីចំនួន ៦ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រទេសទាំងពីរ គឺជាអ្នកគាំទ្រខាងនយោបាយខ្លាំងខ្លា ឱ្យគ្នាទៅវិញទៅមក។ ចាប់តាំងពីការចាកចេញពីទំនាក់ទំនងផ្លូវការជាមួយនឹងតៃវ៉ាន់ នៅឆ្នាំ១៩៩៧មក ប្រទេសកម្ពុជា គឺជាអ្នកគាំទ្រយ៉ាងមុតមាំលើគោលនយោបាយ 'ចិនតែមួយ'។

នៅដើមឆ្នាំ២០០០ ប្រទេសចិន លុបចោលបំណុលប្រមាណជាជិត ១ប៊ីលានដុល្លារអាមេរិក ដែល កម្ពុជាជំពាក់នៅក្នុងអំឡុងទសវត្សរ៍ទី ១៩៧០ (ប្រទេសចិនបានផ្តល់កម្ចីភាគច្រើនសម្រាប់ សម្ភារៈសង្គ្រាម)។

- **ជាមួយប្រទេសវៀតណាម**

ប្រទេសវៀតណាម គឺជាប្រភពនៃការនាំចូលទំនិញមួយដ៏សំខាន់ ហើយក៏ជាទីផ្សារនាំចេញសំខាន់ សម្រាប់ប្រទេសកម្ពុជា ផងដែរ។ ប៉ុន្តែ ជាមួយនឹងជម្លោះរវាងអ្នកតវ៉ាព្រំដែន និងវៀតណាម ភាពតានតឹងលើបញ្ហាព្រំដែន រឹតតែតឹងតែងឡើងនៅឆ្នាំ២០១៥។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសកម្ពុជា បានបញ្ជូនកំណត់ការទូតតវ៉ារាប់សិប ជម្រុញ អាជ្ញាធរវៀតណាម ឱ្យបញ្ឈប់សកម្មភាពនៅតាមព្រំដែន ដែលធ្វើឱ្យប៉ះពាល់ស្ថានការណ៍បច្ចុប្បន្ន។ នៅចុងឆ្នាំ២០១៥ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានដាក់បញ្ជាទៅគ្រប់អាជ្ញាធរមូលដ្ឋាន ឱ្យហាមឃាត់ប្រជាជនកម្ពុជា ដែលមានដីនៅជាប់នឹងព្រំដែនវៀតណាម មិនឱ្យជួលទៅកសិករវៀតណាម។

ស្របតាមពាក្យស្លោក "ភាពជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណី កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយនិងយូរអង្វែង" ទំនាក់ទំនងមិត្តភាពយូរលង់រវាងកម្ពុជានិងវៀតណាម ត្រូវបានពង្រឹងពង្រីកអោយបានកាន់តែស៊ីជម្រៅលើមូលដ្ឋានការគោរពទៅវិញទៅមក។ នៅក្នុងឱកាសទស្សនកិច្ចសម្តេចតេជោនាយករដ្ឋមន្ត្រី កាលពីខែធ្នូ ឆ្នាំ២០១៦ កិច្ចព្រមព្រៀងសហប្រតិបត្តិការចំនួន០៣ លើវិស័យព្រហ្មទណ្ឌ ការផ្ទេរទណ្ឌិត និងវប្បធម៌ ត្រូវបានចុះហត្ថលេខា។ ដោយឡែកនៅក្នុងឱកាសទស្សនកិច្ច ឯកឧត្តម ទេសរដ្ឋមន្ត្រី កាលពីខែមិថុនា ឆ្នាំ២០១៦ ភាគីទាំងពីរបានឯកភាពជំរុញពាណិជ្ជកម្មរវាងប្រទេសទាំងពីរអោយកើនឡើងដល់៥ពាន់ដុល្លារអាមេរិច ព្រមទាំងដោះស្រាយបញ្ហាអោយបានកាន់តែឆាប់នៅបញ្ហាព្រំដែនដែលនៅសេសសល់។ ទំហំពាណិជ្ជកម្មកម្ពុជានៅក្នុង៦ខែដើមនៃឆ្នាំ២០១៦ មានចំនួនប្រមាណ៧៨០លានដុល្លារអាមេរិច។ បច្ចុប្បនិស្សិតអាហារូបករណ៍កម្ពុជា កំពុងសិក្សារយៈពេលខ្លី និងរយៈពេលវែងនៅប្រទេសវៀតណាមមានចំនួនប្រមាណ៩៥០នាក់។

- **ជាមួយប្រទេសថៃ**

យ៉ាងណាក៏ដោយ ទំនាក់ទំនងរវាងប្រទេសកម្ពុជា និងប្រទេសថៃ មានការរីកចម្រើនគួរកត់សម្គាល់ នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរ មាន ៥.១ប៊ីលាន ដុល្លារអាមេរិក នៅឆ្នាំ២០១៤ ដែលបង្ហាញពីកំណើន ១១ភាគរយ បើធៀបនឹងឆ្នាំ២០១៣។ ការនាំចេញរបស់ប្រទេសកម្ពុជា ទៅប្រទេសថៃបានហក់ឡើងជាង ១០០ភាគរយ នៅក្នុងរយៈ ពេល ៩ខែ នៃឆ្នាំ២០១៥។

តាមរបាយការណ៍ មន្ត្រីនៃប្រទេសទាំងពីរ មើលឃើញពីសក្តានុពល ក្នុងការបង្កើនពាណិជ្ជកម្ម ទ្វេភាគីឱ្យបាន ៣០ភាគរយក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០១៦ រហូតដល់ឆ្នាំ២០២០។ កន្លែងត្រួតពិនិត្យនៅព្រំដែន ចំនួន ៦កន្លែង នាពេលបច្ចុប្បន្ន នឹងត្រូវបង្កើនឡើងរហូតដល់ ១០ កន្លែង។

ការឆ្លងដែនខុសច្បាប់មកពីប្រទេសកម្ពុជា ទៅប្រទេសថៃកើតឡើងក្នុងទ្រង់ទ្រាយធំដូចគ្នាទៅ នឹងការនិរទេសខ្លួនត្រឡប់មកប្រទេសកម្ពុជាវិញដែរ។ លោក ឡាយ គីមលន់ ប្រធាននគរបាលប្រឆាំងការជួញដូរមនុស្សប្រចាំខេត្តបន្ទាយមានជ័យ ត្រូវបានស្រង់សម្តីកាលពីខែធ្នូ ឆ្នាំ២០១៥ ថា ចាប់ពីដើមឆ្នាំមក ប្រជាជនកម្ពុជា ចំនួន ៥៥,៦២៦ នាក់ ត្រូវបានចាប់បញ្ជូនខ្លួនមកវិញដោយអាជ្ញាធរថៃតាមច្រកត្រួតពិនិត្យប៉ោយប៉ែត។

ចំណងទំនាក់ទំនងមិត្តភាពជាប្រពៃណី ភាពជាអ្នកជិតខាងល្អ និងកិច្ចសហប្រតិបត្តិការជិតស្និទ្ធលើគ្រប់វិស័យរវាងប្រទេសទាំងពីរត្រូវបានពង្រឹងពង្រីកឥតឈប់ឈររហូតឈានបានឡើងដល់កម្រិត "ភាពជាដៃគូសន្តិភាពនិងវិបុលភាព"។ ក្នុងឱកាសទស្សនៈកិច្ច ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន កាលពីខែមិថុនា ឆ្នាំ២០១៦ ភាគីទាំងពីរបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការបង្កើតមជ្ឈមណ្ឌលសំចតទទួលជនរងគ្រោះដោយអំពើជួញដូរ ក្រោមជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលថៃ។ កម្ពុជានិងថៃក៏បានសហការគ្នាក្នុងការពង្រីកនិងលើកកំពស់ពាណិជ្ជកម្មទ្វេភាគី តាមរយៈការអភិវឌ្ឍន៍ផ្លូវគោក ផ្លូវដែក ផ្លូវសមុទ្រ ដើម្បីតភ្ជាប់ប្រទេសទាំងពីរ និងការបើកច្រកទ្វារអន្តរជាតិ និងហត្ថលេខាលើឥណទានសម្បទានសម្រាប់គម្រោងរៀបចំសម្រាប់ការសាងសង់ស្ពានស្ទឹងបត់។ បច្ចុប្បន្ន និស្សិតកម្ពុជាចំនួន១៩៣នាក់ កំពុងសិក្សានៅប្រទេសថៃកម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈ ធម្យមសិក្សាបច្ចេសទេស បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់។

- **ជាមួយប្រទេសជប៉ុន**

ចាប់តាំងពីឆ្នាំ១៩៩២មក ប្រទេសជប៉ុន បានផ្តល់ជំនួយអភិវឌ្ឍន៍ដល់ប្រទេសកម្ពុជា ជាង ២ ប៊ីលាន ដុល្លារអាមេរិក និងនៅតែជាប្រទេសម្ចាស់ជំនួយធំបំផុតរបស់ប្រទេសកម្ពុជា។ ប្រទេសជប៉ុនផ្តល់អាទិភាពជំនួយរបស់ខ្លួនលើវិស័យហេដ្ឋារចនាសម្ព័ន្ធ រាប់បញ្ចូលទាំងការភិវឌ្ឍបណ្តាល ផ្លូវប្រព័ន្ធអគ្គិសនីស្ថេរភាព និងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍។

នៅដើមឆ្នាំ២០១៥ ប្រទេសជប៉ុន បានយល់ព្រមផ្តល់ ៣៦លានដុល្លារអាមេរិក មកប្រទេសកម្ពុជា ក្រោមកម្មវិធីជំនួយអភិវឌ្ឍន៍ និងជិត ២០០លានដុល្លារអាមេរិក ជាកម្ចីសម្បទាន សម្រាប់កែលម្អ ហេដ្ឋារចនាសម្ព័ន្ធ និងមន្ទីរពេទ្យ។

ប្រទេសកម្ពុជា តែងតែគាំទ្រជានិច្ចចំពោះប្រទេសជប៉ុន នៅក្នុងការប្រកួតប្រជែងសម្រាប់អាសនៈអចិន្ត្រៃយ៍ នៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។

ក្រោយពីទំនាក់ទំនងកម្ពុជា-ជប៉ុនត្រូវបានតម្លើងដល់កម្រិតជា "ដៃគូយុទ្ធសាស្ត្រ" នៅឆ្នាំ ២០១៣ កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរទទួលបានលទ្ធផលប្រកបដោយផ្លែផ្កា និងរីកចម្រើនគួរអោយកត់សំគាល់ស្ទើរគ្រប់វិស័យ។ កាលពីខែកញ្ញា ឆ្នាំ២០១៦ ការហោះហើរត្រង់តូក្យូ-

ភ្នំពេញ-តូក្យូ ត្រូវបានចាប់ផ្តើមឡើង រដ្ឋាភិបាលជប៉ុនបានផ្តល់ជំនួយឥតសំណងចំនួន៤៧១៥លានយ៉េនសម្រាប់គម្រោងអភិវឌ្ឍន៍ធនធានមនុស្ស បណ្តាញចែកចាយអគ្គីសនី សមាហរណកម្មសំអាតមីន និងចរាចរណ៍នៅក្នុងរាជធានីភ្នំពេញ។ ជាមួយគ្នានេះជប៉ុនបានផ្តល់អ្នកជំនាញ និងអ្នកស្ម័គ្រចិត្តចំនួន៧២នាក់ ក្នុងឆ្នាំ២០១៦ លើវិស័យសុខាភិបាល អប់រំសម្រាប់ អភិវឌ្ឍន៍ជនបទ កីឡា និងកសិកម្ម។ និស្សិតកម្ពុជដែលកំពុងសិក្សានៅប្រទេសជប៉ុនមានជំនួនប្រមាណ៣.៣០០នាក់ ដែលកំពុងហ្វឹកហ្វឺនផ្នែកកសិកម្ម នេសាទ សំណង់ ផលិតកម្មអាហារ កាត់ដេរ គ្រឿងយន្ត និងលោហធាតុ។

- **ជាមួយសាធារណរដ្ឋកូរ៉េ**

ក្នុងរយៈពេលពេល១៩ឆ្នាំមកនេះ កិច្ចសហប្រតិបត្តិការរវាងកម្ពុជានិងកូរ៉េ ប្រកបដោយផ្លែផ្កាមានការរីកចម្រើនគួរអោយកត់សម្គាល់ស្ទើរគ្រប់វិស័យ។ នៅក្នុងកិច្ចប្រជុំលើកទី៣ នៃគណៈកម្មាការកម្ពុជា-កូរ៉េ កាលពីខែមីនា ឆ្នាំ២០១៦ នៅភ្នំពេញ ភាគីទាំងពីរបានពង្រឹងទំហំពាណិជ្ជកម្មទ្វេភាគីអោយបាន២ពាន់លានដុល្លារអាមេរិចក្នុងឆ្នាំ២០២០។ កូរ៉េបានផ្តល់ជំនួយឥតសំណងប្រមាណ២៣លានដុល្លារអាមេរិចសម្រាប់អាការបរណ៍ស៊ីវិល កសិកម្ម សាធារណ សុខាភិបាល អភិវឌ្ឍន៍ជនបទ ហិរញ្ញវត្ថុ ផ្សារមូលប័ត្រ និងវប្បធម៌។ កូរ៉េបានផ្តល់កម្ចីសម្បទានចំនួនជាង១៣លានដុល្លារអាមេរិចសម្រាប់អភិវឌ្ឍន៍ស្ទឹងសៀមរាបជំហានទី២ និងផ្តល់អាហារូបករណ៍ថ្នាក់អនុបណ្ឌិតចំនួន២០កន្លែង នៅសាធារណរដ្ឋកូរ៉េ។

- **ជាមួយប្រទេសឥណ្ឌា**

ឥណ្ឌាជាប្រទេសទី១ក្នុងតំបន់ដែលកាន់លទ្ធិប្រជាធិបតេយ្យ ដែលបានទទួលស្គាល់ប្រជាមានិកកម្ពុជា និងបានភ្ជាប់ទំនាក់ទំនងការទូតឡើងនៅឆ្នាំ១៩៨១។ ទំនាក់នង និងកិច្ចសហប្រតិបត្តិការទាំងពីរប្រទេសបានពង្រឹងពង្រីកនៅក្នុងវិស័យ អភិវឌ្ឍន៍ធនធានមនុស្ស អប់រំ កសិកម្ម យោធាពាណិជ្ជកម្ម វប្បធម៌ អភិរក្សនិងជួសជុលប្រសាទ ។ល។ រយៈពេល៦ខែដើមឆ្នាំ២០១៦ ទំហំពាណិជ្ជកម្មកម្ពុជានិងឥណ្ឌាមានចំនួន ៥៨,៥២លានដុល្លារអាមេរិច ឥណ្ឌាបានបោះទុនវិនិយោគនៅកម្ពុជាចំនួន ១០៨លានដុល្លារអាមេរិច និងបានផ្តល់អោយមន្ត្រីកម្ពុជាចំនួន ១២៩នាក់ ចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនៅប្រទេសឥណ្ឌា។

**កិច្ចសហប្រតិបត្តិការជាមួយប្រទេសក្នុងតំបន់អឺរ៉ុប**

បច្ចុប្បន្នកម្ពុជាមានទំនាក់ទំនងជាមួយប្រទេសចំនួន៥០ ក្នុងតំបន់អឺរ៉ុប ដែលជាទីផ្សារដ៏សំខាន់មួយសម្រាប់ផលិតផលកម្ពុជា ហើយប្រទេសមួយចំនួនទៀតនៅក្នុងតំបន់អឺរ៉ុននេះ ជាប្រទេសដែលផ្តល់ជំនួយដ៏សំខាន់ដល់កម្ពុជាផងដែរ។ ជារួមនៅឆ្នាំ២០១៦កន្លងមក ទំនាក់ទំនង

ទ្វេភាគីរវាងកម្ពុជាលនៅបណ្តាប្រទេសនៅតំបន់អឺរ៉ុប មានការរីកចម្រើនគួរអោយកត់សម្គាល់លើវិស័យការទូត សេដ្ឋកិច្ច វិនិយោគ ទេសចរណ៍ និងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។

ប្រទេសសំខាន់ៗដែលជាដៃគូរអភិវឌ្ឍន៍មានដូចតទៅៈ

- **ជាមួយសហព័ន្ធរុស្ស៊ី**

នៅឆ្នាំ២០១៥ ទំនាក់ទំនងរវាងប្រទេសកម្ពុជា និងប្រទេសរ៉ុស្ស៊ី បានអភិវឌ្ឍគួរជាទីកត់សម្គាល់ ជាមួយនឹងដំណើរទស្សនកិច្ចរបស់នាយករដ្ឋមន្ត្រីរ៉ុស្ស៊ី មកកាន់ប្រទេសកម្ពុជា។ នៅក្នុងបណ្តា កិច្ចព្រមព្រៀង និងសេចក្តីសម្រេចដែលត្រូវបានធ្វើឡើង ប្រទេសរ៉ុស្ស៊ីបានយល់ព្រមលុបបំណុល ៧០ភាគរយ នៃបំណុលសរុបប្រមាណជា ១.៥ ប៊ីលានដុល្លារអាមេរិក មកពីអំឡុងទសវត្សរ៍ទី១៩៧០ ដែលសាធារណរដ្ឋប្រជាមានិតកម្ពុជា បានជំពាក់។

**អ្នកវិនិយោគបរទេសធំៗ**: ចិន កូរ៉េខាងត្បូង ជប៉ុន វៀតណាម ម៉ាឡេស៊ី និង ថៃ ។

**ទីផ្សារនាំចេញសំខាន់ៗ**: សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស អាឡឺម៉ង់ កាណាដា សិង្ហបុរី និង វៀតណាម។

ឆ្នាំ២០១៦ ត្រូវបានចាត់ទុកជាឆ្នាំពិសេស ដែលប្រទេសទាំងពីរ កម្ពុជា-រុស្ស៊ីបានប្រារព្ធខួបលើកទី៦០ទំនាក់ទំនងការទូត ហើយជាឱកាសមួយដែលកម្ពុជានិងរុស្ស៊ីបានគូសបញ្ជាក់សារជាថ្មីនិងមិត្តភាពដ៏រឹងមាំក្នុងទំនាក់ទំនងប្រកបដោយទំនុកចិត្តទៅវិញទៅមក និងឈានដល់ការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កា។ នៅក្នុងឱកាសទស្សនកិច្ច សម្តេចតេជោ នៅរុស្ស៊ីកាលពីខែឧសភា ឆ្នាំ២០១៦ ឯកសារចំនួន៨លើវិស័យយុត្តិធម៌ កិច្ចការនគរបាល បច្ចេកទេស យោធាទូគមនាគមន៍និងបច្ចេកវិទ្យាព័ត៌មាន កីឡា ពាណិជ្ជកម្មនិងវិនិយោគ និងថាមពលនុយក្លេអ៊ែរ ត្រូវបានចុះហត្ថលេខា។ ជាការគួរអោយកត់សម្គាល់ នៅក្នុងឱកាសទស្សនកិច្ច ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន នៅរុស្ស៊ី។

- **ជាមួយសាធារណរដ្ឋបារាំង**

បារាំងគឺជាដៃគូរយ៉ាងសំខាន់របស់កម្ពុជាក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា សង្គម វប្បធម៌ និងវិនិយោគ។ ក្នុងឱកាសទស្សនៈកិច្ចការងារនៅសាធារណរដ្ឋបារាំង កាលពីខែវិច្ឆិកា ឆ្នាំ២០១៦ **ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** បានជួបពិភាក្សាការងារជាមួយ **ឯកឧត្តម ហ្សង់ ម៉ាកអែរ៉ូល** រដ្ឋមន្ត្រីការបរទេសនិងអភិវឌ្ឍន៍បារាំង ដោយផ្តោតសំខាន់លើការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យវប្បធម៌បេតិកភណ្ឌ ការវិនិយោគ ការផ្តល់ឥណទានពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ទេសចរណ៍ និងអាហារូបករណ៍។ ជាមួយគ្នានេះ សន្និសីទក្រោមប្រធានបទ "ស្មារតីសុន្ទរកថាទីក្រុងភ្នំពេញ និងប្រទេសកម្ពុជា" ដើម្បីរំលឹកខួបលើកទី៥០ឆ្នាំ នៃដំណើរការទស្សនកិច្ចរបស់ឧត្តមសេនីយ៍

Charles de Gaulla អតីតប្រធានាធិបតេយ្យនៃសាធារណរដ្ឋបារាំងនៅកម្ពុជា បានប្រព្រឹត្តទៅកាលពីខែតុលា ឆ្នាំ២០១៦។ ក្នុងរយៈពេល៦ខែដើមឆ្នាំ២០១៦ ទំហំពាណិជ្ជកម្មកម្ពុជា-បារាំង មានចំនួនប្រមាណ ២០៤លានដុល្លារអាមេរិច (បារាំងបាននាំចូលអង្ករពីកម្ពុជាចំនួន៤៨.២២៧តោន ក្នុងរយៈពេល៨ខែ ដើមឆ្នាំ២០១៦)។

- **ជាមួយប្រទេសផ្សេងទៀត**

ក្នុងឆ្នាំ២០១៦ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងរដ្ឋាភិបាលអាល្លឺម៉ង់បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេសនិងហិរញ្ញវត្ថុមានទឹកប្រាក់ជាង៤លានអឺរ៉ូ ស្វីសបានផ្តល់ជំនួយដល់កម្ពុជាចំនួនជជិត៣០លានហ្វ្រង់ស្វីស (ប្រហែល៣១លានដុល្លារអាមេរិច) សម្រាប់ឆ្នាំ២០១៣-២០១៧ លើវិស័យធំៗ៤គឺ៖ មន្ទីរពេទ្យគន្ធបុប្ផា អភិបាលកិច្ច កសិកម្មនិងសន្តិសុខស្បៀង និងការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ អង់គ្លេសបានផ្តល់អាហារូបករណ៍Chevening ថ្នាក់ក្រោមឧត្តមសិក្សារចំនួន២០កន្លែងដល់និស្សិតកម្ពុជាស៊ុយអែតបានផ្តល់ជំនួយដល់កម្ពុជាចំនួន១៣ាន់លានក្រោនស៊ុយអែតសម្រាប់ឆ្នាំ២០១៤ដល់ឆ្នាំ២០១៨ ដើម្បីអនុវត្តគម្រោងលើកកំពស់សិទ្ធមនុស្ស ប្រជាធិបតិយ្យ និងនីតិរដ្ឋ អប់រំ និងទីផ្សារការងារ និងអាកាសធាតុនិងការប្រើរប្រាស់ធនធានធម្មជាតិប្រកបដោយ និរន្តភាព។ល។

- **សហរដ្ឋអាមេរិក**

សហរដ្ឋអាមេរិក គឺមានសារៈសំខាន់ខាងសេដ្ឋកិច្ចជាខ្លាំងចំពោះប្រទេសកម្ពុជា។ អាមេរិកទិញប្រមាណជា មួយភាគបី នៃការនាំចេញរបស់ប្រទេសកម្ពុជា ភាគច្រើនជាសម្លៀកបំពាក់ និងស្បែកជើង។ នៅឆ្នាំ២០១៤ ពាណិជ្ជកម្មទ្វេភាគី មានតម្លៃជិត ៣.២ប៊ីលានដុល្លារអាមេរិក ប៉ុន្តែ មានអតុល្យភាពខាងជញ្ជីងពាណិជ្ជកម្មខ្លាំង៖ សហរដ្ឋអាមេរិក នាំចូល ២.៨៤ប៊ីលានដុល្លារ អាមេរិកមកពីប្រទេសកម្ពុជា ខណៈដែលនាំចេញតែ ៣២៨លានដុល្លារអាមេរិក ទៅព្រះរាជាណាចក្រកម្ពុជា។

នៅឆ្នាំ២០១៤ ជំនួយការបរទេសរបស់សហរដ្ឋអាមេរិក សម្រាប់សុខភាព អប់រំ អភិបាលកិច្ចកំណើនសេដ្ឋកិច្ច និងការដោះគ្រាប់មិនទាន់ផ្ទុះ មានតម្លៃសរុប ៧៤.៥ លានដុល្លារអាមេរិក។ ទំនាក់ទំនងមិត្តភាពនិងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងសហរដ្ឋអាមេរិក មានការរីកចម្រើនគួរអោយកត់សម្គាល់។ នៅក្នុងឆ្នាំ២០១៦ ភាគីទាំងពីរបានចុះហត្ថលេខា លើកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសម្រាប់ការអនុវត្តកម្មវិធីកសិកម្ម និងបរិស្ថានដែលមានទឹកប្រាក់ជាង១១លានដុល្លាអាមេរិកសម្រាប់ឆ្នាំ២០១៦។ អាមេរិកបានផ្តល់ការអនុគ្រោះ ពន្ធដល់កម្ពុជាលើការនាំចេញផលិយផលសម្រាប់ការធ្វើដំណើរ( កាបូបដាក់ខោអាវ ការបូបយួរ និងផ្តល់ជំនួយជាង១២ម៉ឺនដុល្លាអាមេរិកក្រោមមូលនិធិឯកអគ្គរដ្ឋទូតសម្រាប់អភិរក្សវប្បធម៌ ដើម្បីអភិរក្សប្រាសាទចំនួន២៤កន្លែងនៅកម្ពុជាជាមួយ

បណ្តាប្រទេសផ្សេងទៀតនៅតំបន់អាមេរិកកម្ពុជា មានទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អប្រសើរជាមួយ បណ្តាប្រទេសផ្សេងទៀតនៅតំបន់អាមេរិក ជាពិសេសជាមួយ កាណាដា គុយបា ប្រេស៊ីល អាហ្សង់ទីន ម៉ិចសិក កូឡុំប៊ី ឈីលី និងអេក្វាឌ័រដែលក្នុងនេះទំនាក់ទំនងកម្ពុជា និងគុយបា ជាទំនាក់ទំនងមិត្តភាពប្រពៃដ៏យូលង់ត្រូវបានពង្រឹងពង្រីកជាបន្តបន្ទាប់។ ជាមួយនិងការឧបត្ថមដល់កម្ពុជាក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ពីរបបប្រល័យពូជសាសន៍ប៉ុលពត គុយបានៅបន្តជួយអភិវឌ្ឍន៍កម្ពុជាជាពិសេសក្នុងវិស័យសិក្សារធិការ និងសុខាភិបាល។ ក្នុងពេលបច្ចុប្បន្ននិស្សិតកម្ពុជាចំនួន ២២ នាក់ កំពុងសិក្សារនៅគុយបាដែលភាគច្រើនសិក្សារលើជំនាញ សុខាភិបាល។

**កិច្ចសហប្រតិបត្តិការថ្នាក់អនុតំបន់ និងតំបន់១កិច្ចសហប្រតិបត្តិការថ្នាក់អនុតំបន់កម្ពុជាបានចូលរួមក្នុងកិច្ចសហប្រតិបត្តិការថ្នាក់អនុតំបន់សំខាន់ៗមានះ**

- **កិច្ចសហប្រតិបត្តិការមេគង្គះ** កិច្ចសហប្រតិបត្តិការផ្តោតលើ ហេដ្ឋារចនាសម្ព័ន្ធ ការគ្រប់គ្រងនិងអភិវឌ្ឍន៍ ធនធានទឹក សេដ្ឋកិច្ចឆ្លងដែន កាត់បន្ថយភាពក្រីក្រ។ល។
- **កិច្ចសហប្រតិបត្តិការកម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម** ( CLMV )៖ ក្នុងឆ្នាំ២០១៦កន្លងទៅថ្នាក់ដឹកនាំបានឯភាពពន្លឿនការសាងសង់និងកែរលម្អរហេដ្ឋារចនាសម្ព័ន្ធតាមច្រករបៀងសេដ្ឋកិច្ច សម្រួលការដឹកជញ្ជូន តាមផ្លូវអាកាស ជំរុញពាណិជ្ជកម្មនិងបង្កើតទីផ្សារតាមព្រំដែន ជំរុញកិច្ចសហប្រតិបត្តិការលើវិស័យឧស្សាហកម្មព្រមទាំងវិស័យទេសចរណ៍រវាងប្រទេសទាំងបួនដើម្បីប្រែក្លាទៅជា ប្រទេសបួនទិសដៅតែមួយ ។
- **កិច្ចសហប្រតិបត្តិការកម្ពុជា ឡាវ វៀតណាម** ៖ ១៥ គម្រោងអាទិភាព និងកិច្ចព្រមព្រៀងស្តីពីការលើកម្ពស់និងការសម្រួលពាណិជ្ជកម្មក្នុងតំបន់ CLV ត្រូវបានអនុម័តកាលពីខែវិច្ឆការ ឆ្នាំ២០១៦ នៅក្នុងឪកាសកិច្ចប្រជុំកំពូល កម្ពុជា ឡាវ វៀតណាមលើកទី៩នៅខេត្តសៀមរាប។
- **យុទ្ធសាស្រ្តកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចមេគង្គចៅប្រ៉ាយ៉ាអាយីយ៉ាវ៉ាឌី**( ACMECS ) ៖ កិច្ចប្រជុំលើកទី៧ខែតុលាឆ្នាំ២០១៦ បានសម្រេចការតភ្ជាប់កាដឹកជញ្ជូន ពង្រឹងភាពប្រកួត ប្រជែងសហគ្រាសធុនតូចនិងមធ្យម ពន្លឿនការអនុវត្តផែនការសកម្មភាពទេសចរណ៍ ACMECS (២០១៦-២០១៨)និងជំរុញការភិវឌ្ឍន៍លើវិស័យកសិកម្ម និងពាណិជ្ជកម្មលើកម្ម លើផលិតផលកសិកម្ម។

## ២.១.៤. កិច្ចសហប្រតិបត្តិការក្នុងតំបន់

- **ជាមួយអាស៊ាន**

កម្ពុជាបានចូលរួមសហការយ៉ាងសកម្មជាមួយនិងប្រទេសសមាជិកអាស៊ានដ៏ទៃទៀត ដើម្បីធ្វើឲ្យបាននូវគោលដៅរបស់អាស៊ានជាសហគមន៍មួយដោយផ្អែកលើវិធានច្បាប់ យកចិត្តទុកដាក់លើប្រជាជន និងយកប្រជាជនជាស្នូលស្របតាមទស្សនវិស័យតែមួយ អត្តសញ្ញាណតែមួយ សហគមន៍តែមួយ ។

នៅឆ្នាំ២០១៦កន្លងទៅនេះ កម្ពុជាបានចូលរួមកិច្ចប្រជុំជាច្រើនរបស់អាស៊ាន ដែលមានជាអាទិ៍៖

- o កិច្ចប្រជុំកំពូលអាស៊ានលើកទី២៨និងទី២៩
- o កិច្ចប្រជុំរំលឹកខួបអនុស្សាវរីយ៍២៥ឆ្នាំនៃទំនាក់ទំនងអាស៊ាន-ចិន
- o កិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍២០ឆ្នាំនៃទំនាក់ទំនងអាស៊ាន-រុស្ស៊ី
- o កិច្ចប្រជុំកំពូលពិសេសរបស់ថ្នាក់ដឹកនាំអាស៊ាន
- o សហរដ្ឋអាមេរិកនិងកិច្ចប្រជុំកំពូលពាក់ពន្ធ ដទៃទៀតសរុបចំនួន១១កិច្ចប្រជុំ។
- o កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានចង្អៀត
- o កិច្ចប្រជុំមន្ត្រីការបរទេសអាស៊ានលើកទី៤៩
- o កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានក្រៅផ្លូវការ
- o កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានពិសេសស្តីពីបញ្ហារូហ៊ីនយ៉ាង
- o កិច្ចប្រជុំពិសេសនៃរដ្ឋមន្ត្រីការបរទេសអាស៊ាន-ចិន វេទិការតំបន់អាស៊ាន និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសពាក់ព័ន្ធដទៃទៀតសរុបមានចំនួន២៣កិច្ចប្រជុំ។
- o កិច្ចប្រជុំឧត្តមមន្ត្រីអាស៊ានថ្នាក់អគ្គនាយក និងកម្រិតដទៃទៀតសរុបចំនួន៩៦កិច្ចប្រជុំ

ជាលទ្ធផលកិច្ចប្រជុំកំពូលបានអនុម័តៈ សេចក្តីថ្លែងការណ៍ ស្តីពី អាស៊ានមួយ ការឆ្លើយតបតែមួយ ការឆ្លើយតបរបស់អាស៊ាន តែមួយនៅនិងគ្រោះមហន្តរាយនានាក្នុងតំបន់និងនៅ ក្រៅតំបន់ ផែនការងារទី៣នៃគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ានផែនការ មេស្តីពីការតភ្ជាប់អាស៊ានឆ្នាំ២២៥ការផ្លាស់ប្តូរពីការងារក្រៅប្រព័ន្ធទៅជាការងារក្នុងប្រព័ន្ធដើម្បីឆ្ពោះទៅរកការលើក កំពស់ការងារសមរម្យក្នុងអាស៊ានសេចក្តីប្រកាសរួម អាស៊ានស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់សន្និសិទលើកទី២២នៃភាគី អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ល។

នៅក្នុងកិច្ចប្រជុំកម្ពុជាបានខិតខំចូលរួមចំណែកបន្ធូបន្ថយភាពតានតឹងនៅសមុទ្រចិនខាងត្បូងតាមរយៈការចូលសម្របសម្រួល ទំនាក់ទំនងអាស៊ានចិនដោយឈរលើជំហរ អព្យាក្រិត្យនិងជំរុញការដោះស្រាយជម្លោះដោយភាគីពាក់ព័ន្ធផ្ទាល់ដោយសន្តិវិធីស្របតាមច្បាប់អន្តរជាតិ។ ជាការ

គួរអោយ កត់សម្គាល់កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៤៩ នៅទីក្រុងវៀងច័ន្ទ ឆ្នាំ២០១៦ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** បានខិតខំសម្របសម្រួលរវាងសមាជិកអាស៊ាន និងចិនជៀសវាងបាននូវ ការផ្ទុះជម្លោះកាន់តែខ្លាំងរក្សាទំនាក់ទំនងអាស៊ាន ចិនរហូតសម្រេចបាននូវសេចក្តីប្រកាសរួមរបស់ រដ្ឋមន្ត្រីការបរទេសអាស៊ាន។ ជាមួយគ្នានេះកម្ពុជានិងបន្តលើកទឹកចិត្តអាស៊ាន និងចិនអនុវត្តសេចក្តី ថ្លែងការស្តីពីការប្រតិបត្តិរបស់ភាគីនៅសមុទ្រចិនខាងត្បូងដែលបានចុះហត្ថលេខានៅភ្នំពេញនៅក្នុងឆ្នាំ២០០២ ឲ្យមានប្រសិទ្ធិភាព និងបានពេញលេញនិងបន្តគាំទ្រដល់ជំហានទៅមុខជាវិជ្ជមាន ដើម្បី បញ្ចៀសការប្រឈមមុខឬការប៉ះ ទង្គិចណាមួយនៅសមុទ្រចិនខាងត្បូងព្រមទាំងបង្កើតបរិយាកាស អំណោយផលដើម្បីឈានទៅសម្រេចឲ្យបាននូវក្រមប្រតិបត្តិសមុទ្រចិនខាងត្បូងឲ្យបានឆាប់។

ដោយឡែក កម្ពុជាក៏មានកិច្ចសហប្រតិបនត្តិការល្អប្រសើរជាមួយអង្គការតំបន់ផ្សេងទៀតដែលមានជាអាទិ៍"អង្គការហ្វ្រង់កូហ្វូនី" "កិច្ចប្រជុំអាស៊ីអឺរ៉ុប (ASEM)" "កិច្ចសន្ទាស្តីពីកិច្ចសហប្រតិបត្តិការអាស៊ី (ACD)" "សន្និសិទស្តីពីអន្តរសកម្ម និងវិធានការកសាងទំនុកចិត្តនៅអាស៊ី (CICA) "។

### ២.១.៥. កិច្ចសហប្រតិបត្តិការជាមួយអន្តរការសហប្រជាជាតិ និងអង្គការអន្តរជាតិ

ជារួមកិច្ចសហប្រតិបត្តិការរវាងកម្ពុជាជាមួយអន្តរការសហប្រជាជាតិជាពិសេសជាមួយក្រុមភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំកម្ពុជា និងអង្គការអន្តរជាតិនានាមាន លក្ខណៈល្អប្រសើរ ទោះបីជាក្នុងឆ្នាំ២០១៦ មានបញ្ហាប្រឈមខ្លះៗ ពាក់ព័ន្ធនឹងបញ្ហាសិទ្ធមនុស្សបង្កឡើងដោយការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស អ.ស.ប នៅភ្នំពេញយ៉ាងក៏ដោយ។ ជាមួយគ្នានេះក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិបានធ្វើឲ្យសម្រេចសមិទ្ធផលផ្សេងៗ គួរជាទីមោទនៈក្នុងការលើកកម្ពស់មុខមាត់ប្រទេសជាតិលើវេទិលកាអន្តរជាតិតាមរយៈការចូលរួមយ៉ាងសកម្ម។

**សហការជាមួយអង្គការអន្តរជាតិនានាដូចខាងក្រោមៈ**

**+អង្គការសហប្រជាជាតិ**

ចូលរួមគាំទ្រសេចក្តីសម្រេចចិត្តរបស់គណៈកម្មាធិការទាំង៦ និងរបស់កិច្ចប្រជុំពេញអង្គរបស់មហាសិន្និបាត អ.ស.ប ចំនួន១៧៣ ដែលក្នុងចំនួននេះកម្ពុជាបានចូលជាប្រទេសតាក់តែងសេចក្តីសម្រេច (Co-sponsor) ចំនួន៦ បោះឆ្នោតគាំទ្រសេចក្តីសម្រេចចិត្តចំនួន៥៤ បោះឆ្នោតប្រឆាំងចំនួន៧ បោះឆ្នោតអនុវាទចំនួន២ ចូលរួមជាកុងស៊ុសចំនួន១០២ និងប្រកាន់ជំហរអវត្តមានចំនួន២។កម្ពុជាបានដាក់បេក្ខភាពជាអនុប្រធានសម័យប្រជុំមហាសន្និបាត អ.ស.បលើកទី៧២ សម្រាប់អាណត្តិចាប់ពីខែកញ្ញា ឆ្នាំ២០១៨ ដល់ ខែកញ្ញា ឆ្នាំ២០១៩ និងនៅក្នុងក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គម អ.ស.ប ECOSOC ក្នុងអាណត្តិ២០១៩។

កម្ពុជាបានទទួលការគាំទ្រជាឯកច្ឆ័ន្ទធ្វើជាប្រធានសម័យប្រជុំលើកទី១១ គណៈកម្មាធិការនៃអនុសញ្ញា ទីក្រុងឡាអេឆ្នាំ១៩៥៤ ស្តីពីការពារបេតិកភ័ណ្ឌវប្បធម៌ក្នុងគ្រាមានជម្លោះប្រដាប់អាវុធពីខែធ្នូ ឆ្នាំ២០១៦ ដល់ ខែធ្នូ ឆ្នាំ២០១៧។

ចាប់ពីឆ្នាំ២០០៦ ដល់ ឆ្នាំ២០១៧ កម្ពុជាបានបញ្ជូនកងកម្លាំងចូលរួមថែរក្សាសន្តិភាពពិភពលោកក្រោមក្របខណ្ឌ អ.ប មានចំនួន៤.ស.៣៦៧នាក់ ទៅប្រទេស៨៖ ម៉ាលី លីបង់ (ស្ត្រី១៦៧នាក់) ស៊ូដង់ ស៊ូដង់ខាងត្បូង អាហ្វ្រិកកណ្តាល ស៊ីប ស៊ីរី ឆាត។

**+កិច្ចសហប្រតិបត្តិការរវាងកម្ពុជានិងអង្គការអន្តរជាតិ**

ប្រទេសកម្ពុជាមានកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កាជាមួយអង្គការអន្តរជាតិមួយចំនួនជាអាទិ៍៖ វេទិកាសេដ្ឋកិច្ចពិភពលោកស្តីពី អាស៊ាន(កម្ពុជានឹងធ្វើចាម្ចាស់ផ្ទះនៃវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ាន នៅថ្ងៃទី១០-១២ ខែឧសភា ឆ្នាំ២០១៧ នៅទីក្រុងភ្នំពេញ) អង្គការពាណិជ្ជកម្មពិភពលោក កម្ពុជាត្រូវបានជ្រើសរើសធ្វើជាប្រធានសម្របសម្រួលក្រុមប្រទេសអភិវឌ្ឍន៍តិចតួចក្រោមក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០១៦ ធនាគារអភិវឌ្ឍន៍អាស៊ី ADB (កម្ពុជានិងADBបានចុះហត្ថលេខា លើកិច្ចព្រមព្រៀង ហិរញ្ញប្បទានដែលមានទឹកប្រាក់សរុប ២១៣លាមដុល្លារអាមេរិក)។

## ២.២. វិសាលភាពនៃទំនាក់ទំនងពហុភាគី

ប្រទេសកម្ពុជា មានចំណងការទូតជាមួយនឹងប្រទេសជាច្រើន រាប់បញ្ចូលទាំងសាធារណរដ្ឋប្រជាមានិតចិន សហរដ្ឋអាមេរិក រាជាណាចក្រជប៉ុន សាធារណរដ្ឋបារាំង ចក្រភពអង់គ្លេស សាធារណរដ្ឋកូរ៉េខាងត្បូង និងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េខាងជើង។ ប្រទេស នេះជាសមាជិកអង្គការអន្តរជាតិជាច្រើន ដូចជា អង្គការសហប្រជាជាតិ និងទីភ្នាក់របស់អង្គការ នេះ។ ប្រទេសនេះ ក៏មានសមាជិកភាពនៅក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ (អាយ អឹម អេហ្វ) ធនាគារអភិវឌ្ឍន៍អាស៊ី (អេឌីប៊ី) អង្គការពលកម្មអន្តរជាតិ (អាយឡូ) និង អង្គការពាណិជ្ជកម្មពិភពលោក (ដាប់ប៊ែលយូ ធី អូ)។ កម្ពុជា ក៏ជាប្រទេសស្ថាបនិកនៃធនាគារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាស៊ី ផងដែរ។

### ២.២.១. អង្គការសហប្រជាជាតិ

ក្រោយសោកនាដកម្ម នៃសង្គ្រាមលោកលើកទី១ និងទី២ អង្គការសហប្រជាជាតិត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៤៥ ក្នុងគោលបំណងស្តារឡើងវិញ និងរក្សានូវសន្តិភាព និងសន្តិសុខអន្តរជាតិ។ គោលបំណង និងគោលការណ៍របស់អង្គការសហប្រជាតិ ត្រូវបានចែងនៅក្នុងមាត្រាទី១ និងទី២ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។ អង្គការសហប្រជាជាតិគឺជា អង្គការអន្តរជាតិមួយដែល

បច្ចុប្បន្នមានប្រទេសសមាជិកចំនួន ១៩៣។ កម្ពុជា បានចូលជាសមាជិកនៃអង្គការនេះ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៥៥។ អស់រយៈកាល ៧០ឆ្នាំមកហើយ ដែលអង្គការសហប្រជាជាតិបានដើរជួរមុខ ជារៀងរាល់ថ្ងៃនៅជុំវិញពិភពលោក ដោយឈរលើសរសរស្តម្ភ៣គឺ បញ្ហាសិទ្ធិមនុស្ស សន្តិភាព និងសន្តិសុខ និងការអភិវឌ្ឍន៍។ កម្ពុជាផ្តល់សារៈសំខាន់ទៅលើសរសរស្តម្ភទាំងបីនេះ។

ក្រៅពីលើកកម្ពស់របៀបវារៈអភិវឌ្ឍន៍ អង្គការសហប្រជាជាតិគឺជាកំលាំងសាមគ្គីភាពក្នុងការដោះស្រាយបញ្ហាប្រឈមផ្សេងៗដែលយើងជួបប្រទះ ដើម្បីជាប្រយោជន៍រួមរបស់មនុស្សលោក ជាពិសេសជនក្រីក្រ និងជនងាយរងគ្រោះ។

លោក អាន់តូនីញ៉ូ ហ្គូទែរ៉េស ជាអគ្គលេខាធិការទី៩ នៃអង្គការសហប្រជាជាតិ ដែលកំពុងកាន់តំណែងរយៈពេល៥ឆ្នាំចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧។

- **ការប្តេជ្ញារបស់កម្ពុជាចំពោះអង្គការសហប្រជាជាតិ**

កម្ពុជាផ្តល់សារៈសំខាន់លើទំនាក់ទំនងពហុភាគីតាមរយៈក្របខ័ណ្ឌនៃអង្គការតំបន់ និងអង្គការអន្តរជាតិដែលប្រកាន់ខ្ជាប់គោលការណ៍មិនជ្រៀតជ្រែកផ្ទៃក្នុង។

កម្ពុជាផ្តល់សារៈសំខាន់ចំពោះ ការអនុវត្តន៍ប្រកបដោយប្រសិទ្ធិភាព នៃគោលដៅអភិវឌ្ឍដោយចីរភាពដែលអនុម័តដោយអង្គការសហប្រជាជាតិ នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ ជាមួយនឹងគោដៅ បញ្ឈប់ភាពក្រីក្រ ការពារភពផែនដី និងធានាវិបុលភាពសម្រាប់ទាំងអស់គ្នា ដែលជាផ្នែកថ្មីមួយនៃរបៀបវារៈអភិវឌ្ឍន៍ដោយចីរភាព។ កម្ពុជាចាត់ទុករបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពជាពេលវេលាប្រវត្តិសាស្ត្រមួយសម្រាប់រាជរដ្ឋាភិបាលកម្ពុជា និងប្រជាជនទាំងមូលព្រោះថា ប្រធានបទនេះបានបញ្ជាក់យ៉ាងច្បាស់ថាមិនទុកនរណាម្នាក់ចោលនោះឡើយ។

កម្ពុជាទទួលស្គាល់ថា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) រឺហៅខ្លីថាគោលដៅពិភពលោកគឺ កសាងភាពជោគជ័យបន្តពីគោលដៅការអភិវឌ្ឍសហស្សវត្សរ៍ (MDGs) និងមានគោលបំណងដើម្បីបញ្ឈប់ភាពក្រីក្រគ្រប់បែបយ៉ាង។ កម្ពុជាមានកិត្តិយសសូមប្រកាសដោយមោទនៈភាពអំពីការសម្រេចបាននូវ គោលដៅការអភិវឌ្ឍសហស្សវត្សរ៍ (MDGs) នាពេលកន្លងមក។

សំខាន់ជាងនេះទៅទៀត ដោយកម្ពុជាធ្លាប់បានទទួលកងកម្លាំងថែរក្សាសន្តិភាព ក្នុងអំឡុងពេលអាជ្ញាធរអន្តរកាលនៃប្រទេសកម្ពុជា (UNTAC) នៅឆ្នាំ១៩៩៣ បច្ចុប្បន្នកម្ពុជាបានក្លាយជាប្រទេសបញ្ជូនកងកម្លាំងថែរក្សាសន្តិភាពនៅក្រោមឆ័ត្រអង្គការសហប្រជាតិ ទៅបម្រើនៅក្នុងបណ្តាប្រទេសមានជំលោះមួយចំនួនដូចជា ស៊ូដង់ ស៊ូដង់ខាងត្បូង ឆាដ អាហ្វ្រិកកណ្តាល លីប៊ី ស៊ីប ម៉ាលី

និងប្រទេសផ្សេងៗទៀត។ ចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១៧ កម្ពុជាបានបញ្ជូនកងទ័ពមួកខៀវចំនួន ៩៩៨៥នាក់ ទៅបណ្តាប្រទេសទាំងនោះ។កំណើនតួនាទីរបស់កម្ពុជា នៅក្នុងអង្គការសហប្រជាជាតិ៖

### ២.២.២. អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី

កាលបរិច្ឆេទបង្កើត ៖ ២០ ខែមីនា ឆ្នាំ១៩៧០ ។

បិតាស្ថាបនិក ៖ Léopold Sédar Senghor អតីតប្រធានាធិបតីសេនេហ្កាល Habib Bourguiba អតីតប្រធានាធិបតីទុយនីសីHamani Diori អតីតប្រធានាធិបតីនីហ្សេ និងព្រះរុណា នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

ទីស្នាក់ការ ៖ ទីក្រុងប៉ារីស ប្រទេសបារាំង ។

សមាជិក ៖មាន ៨៤រដ្ឋ និងរដ្ឋាភិបាល(៥៤ពេញសិទ្ធិ ៤មិនពេញសិទ្ធិ និង២៦សង្កេតការណ៍)គោលដៅ ៖ អង្គការអន្តរជាតិហ្វ្រង់កូហ្វូនីមានបេសកកម្មធ្វើឲ្យសម្រេចនូវសាមគ្គីភាពរវាងរដ្ឋ និងរដ្ឋាភិបាលជាសមាជិក ព្រមទាំងចូលរួមចំណែកធ្វើអោយប្រសើរឡើងនូវកំរិតជីវភាពរបស់ប្រជាពលរដ្ឋនៃប្រទេសជាសមាជិក ។ អង្គការ OIF គាំទ្រដល់រដ្ឋជាសមាជិកក្នុងការបង្កើត ឬពង្រឹងគោលនយោបាយរបស់រដ្ឋសមាជិក ដឹកនាំសកម្មភាពនយោបាយអន្តរជាតិ និងកិច្ចសហប្រតិបត្តិការពហុភាគី លើបេសកកម្មចំបងចំនួនបួន តាមការកំណត់របស់កិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី ៖

- លើកកម្ពស់ភាសាបារាំង វប្បធម និងភាសាផ្សេងៗ
- លើកកម្ពស់សន្តិភាព លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស
- គាំទ្រការអប់រំ ការបណ្តុះបណ្តាល ឧត្តមសិក្សា និងការស្រាវជ្រាវ
- អភិវឌ្ឍកិច្ចសហប្រតិបត្តិការ ដោយបំរើអោយការអភិវឌ្ឍប្រកបដោយចីរភាព

អ្នកប្រើប្រាស់ភាសាបារាំង (២០១៤) ៖ មានចំនួនប្រមាណ ២៧៤លាននាក់ អាចត្រូវគេកំណត់ថាជាអ្នកចេះនិយាយភាសាបារាំងពិតប្រាកដ។ អ្នកប្រើប្រាស់ភាសាបារាំង នៅអាស៊ីអាគ្នេយ៍៖ នៅកម្ពុជាមានចំនួន ៤២៣ ០០០នាក់ គឺស្មើនឹង០,០២% នៃប្រជាជនរបស់ខ្លួន, ឡាវមានចំនួន១៩០ ០០០នាក់ គឺស្មើនឹង ០,០៣% នៃប្រជាជនរបស់ខ្លួន, វៀតណាមមានចំនួន ៦៥៤ ០០០នាក់ គឺស្មើនឹង ០,០០៦%។

### ក. នៅក្នុងអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី

អគ្គលេខាធិការនៃអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី គឺជាអ្នកទទួលខុសត្រូវដ៏ខ្ពស់បំផុតរបស់អង្គការនេះ ។ លោកជំទាវ Michaëlle JEAN ត្រូវបានចាត់តាំងអោយបំពេញមុខដំណែងនេះ ដោយកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី នៅឆ្នាំ ២០១៤ នាទីក្រុងដាការ ប្រទេសសេនេហ្កាល់ ។ អភិបាលនៃអង្គការ OIF ត្រូវបានតែងតាំងដោយអគ្គលេខាធិការ ។ អភិបាលទទួលបន្ទុកអនុវត្ត និងគ្រប់គ្រងកិច្ចសហ

ប្រតិបត្តិការរបស់អង្គការ OIF។ លោក Adama OUANE បំពេញមុខដំណែងនេះ ចាប់តាំងពីខែ មេសា ឆ្នាំ២០១៥ ។ អង្គការអន្តរជាតិប្រ្វង់កូហ្វូនីត្រូវដាក់អោយស្ថិតនៅក្រោមការដឹកនាំរបស់ស្ថាប័ននយោបាយចំនួន ៣គឺ: កិច្ចប្រជុំកំពូល (Sommet) ជាស្ថាប័នកំពូលរបស់អង្គការអន្តរជាតិប្រ្វង់កូហ្វូនី ដែលប្រជុំរៀងរាល់ពីរឆ្នាំម្តង សន្និសីទថ្នាក់រដ្ឋមន្ត្រីប្រ្វង់កូហ្វូនី (CMF) និងក្រុមប្រឹក្សាអចិន្ត្រៃយ៍ប្រ្វង់កូហ្វូនី (CPF) ។ អង្គការអន្តរជាតិប្រ្វង់កូហ្វូនីមាន ៖

**តំណាងអចិន្ត្រៃយ៍ចំនួន ៤ គឺ**

– នៅអាប់ឌីអាបេបា (Addis-Abeba) ប្រចាំសហភាពអាហ្វ្រិក និងប្រចាំគណៈកម្មការសេដ្ឋកិច្ចអាហ្វ្រិកនៃអង្គការសហប្រជាជាតិ

– នៅទីក្រុងប្រ៊ុចសែល (Bruxelles) ប្រចាំសហភាពអឺរ៉ុប

– នៅទីក្រុងញូវយ៉ក(New York) និងនៅទីក្រុងហ្សឺណែវ(Genève)ប្រចាំអង្គការសហប្រជជាតិ

ការិយាល័យតំបន់ចំនួន ៦ គឺ

– នៅទីក្រុងឡូមេ (ប្រទេសតូហ្គោ) សំរាប់អាហ្វ្រិកខាងលិច

– នៅទីក្រុងលីប្រឺវីល (ប្រទេសហ្កាបុង) សំរាប់អាហ្វ្រិកកណ្តាល

– នៅទីក្រុងហាណូយ (ប្រទេសវៀតណាម) សំរាប់តំបន់អាស៊ី-ប៉ាស៊ីហ្វិក

– នៅទីក្រុងព័រអូប្រាំងស៍ (ប្រទេសហៃទី) សំរាប់តំបន់ការាអ៊ីប និងអាមេរិកឡាទីន

– នៅទីក្រុងប៊ុយការេស្ត (ប្រទេសរ៉ូមានី) សំរាប់អឺរ៉ុបកណ្តាល និងអឺរ៉ុបខាងកើត

– នៅទីក្រុងអង់តាណាណារីវ៉ូ (ប្រទេសម៉ាដាហ្កាស្កា) សំរាប់មហាសមុទ្រឥណ្ឌា ។

## ខ. ស្ថាប័នរបស់អង្គការអន្តរជាតិប្រ្វង់កូហ្វូនី

អង្គការអន្តរជាតិប្រ្វង់កូហ្វូនីធ្វើសកម្មភាពដោយពួតដៃគ្នាជាមួយសភានិយាយភាសាបារាំង (APF) ជាមួយប្រតិបត្តិករឯកទេសចំនួន ៤ នៃកិច្ចប្រជុំកំពូលដូចជា ទីភ្នាក់ងារឧត្តមសិក្សានិយាយភាសាបារាំង(AUF) ទូរទស្សន៍ TV5 សមាគមអន្តរជាតិនៃបណ្តាអភិបាលក្រុងនិយាយភាសាបារាំង (AIMF) និងសាកលវិទ្យាល័យសេងហ័រដាឡិចហ្សង់ឌ្រី (Université Senghor d'Alexandrie) ។ អង្គការ OIF ធ្វើសកម្មភាពដោយពួតដៃគ្នាផងដែរជាមួយសន្និសីទថ្នាក់រដ្ឋមន្ត្រីជាអចិន្ត្រៃយ៍ពីរ គឺសន្និសីទរដ្ឋមន្ត្រីអប់រំជាតិ (Confémen) និងសន្និសីទរដ្ឋមន្ត្រីយុវជន និងកីឡា (Conféjes) ។

## គ. ព្រះរាជាណាចក្រកម្ពុជា និងអង្គការអន្តរជាតិប្រ្វង់កូហ្វូនី

នៅខែវិច្ឆិកា ឆ្នាំ១៩៩១ ៖ ជាសមាជិកសង្កេតការ នាកិច្ចប្រជុំកំពូលប្រ្វង់កូហ្វូនីលើកទី៤ នៅឆាយយ៉ូ (ទីក្រុងប៉ារីស) ប្រទេសបារាំង

នៅខែតុលា ឆ្នាំ១៩៩៣ ៖ ជាសមាជិកពេញសិទ្ធ នាកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី៥ នៅទីក្រុងក្រង់បេ ប្រទេសម៉ូរីស ។

**ឃ. កិច្ចប្រជុំហ្វ្រង់កូហ្វូនីនាពេលខាងមុខ**

សន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនីលើកទី ៣៥ (CMF) នឹងប្រព្រឹត្តទៅនៅថ្ងៃទី ៨ និង ៩ ខែតុលា ឆ្នាំ ២០១៨ នៅទីក្រុងអ៊ែរវីវាន (Erevan) ប្រទេសអាមេនី

កិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី ១៧ នឹងប្រព្រឹត្តទៅនៅថ្ងៃទី១១ដល់ថ្ងៃទី១២ខែតុលាឆ្នាំ ២០១៨ នៅទីក្រុងអ៊ែរវីវាន (Erevan) ប្រទេសអាមេនី ។

**២.២.៣. កិច្ចសហប្រតិបត្តិការមេគង្គ**

កិច្ចសហប្រតិបត្តិការមេគង្គ គឺជាកិច្ចសហប្រតិបត្តិការថ្នាក់អនុតំបន់ដែលមានការចូលរួមពីបណ្តាប្រទេសជាប់ដងទន្លេមេគង្គ ដូចជា កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម។ កិច្ចសហប្រតិបត្តិការនេះមានការចូលរួមសហការពីសំណាក់ដៃគូអភិវឌ្ឍន៍សំខាន់ៗ ដូចជា ចិន ជប៉ុន កូរ៉េ ឥណ្ឌា អាមេរិក សហភាពអឺរ៉ុប និងធនាគារអភិវឌ្ឍន៍អាស៊ី ។ល។ ក្នុងគោលបំណងធានានូវការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានទឹកប្រកបដោយចីរភាព រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជន កាត់បន្ថយគម្លាតនៃការអភិវឌ្ឍន៍ក្នុងចំណោមប្រទេសក្នុងតំបន់គាំទ្រដល់ការកសាងសហគមន៍អាស៊ាន និងដោះស្រាយបញ្ហាប្រឈមនានា នៅក្នុងតំបន់មេគង្គ។

**ក. ក្របខ័ណ្ឌការងារកិច្ចសហប្រតិបត្តិការមេគង្គ**

ក្របខ័ណ្ឌការងារក្នុងកិច្ចការសហប្រតិបត្តិការមេគង្គបច្ចុប្បន្នមាន៖

- កិច្ចសហប្រតិបត្តិការមេគង្គគង្គា (ជាមួយឥណ្ឌា)
- កិច្ចសហប្រតិបត្តិការមេគង្គជប៉ុន
- កិច្ចសហប្រតិបត្តិការមេគង្គសាធារណរដ្ឋកូរ៉េ
- គំនិតផ្តួចផ្តើមទន្លេមេគង្គក្រោម (ជាមួយសហរដ្ឋអាមេរិកនិងមិត្តរបស់មេគង្គក្រោយ)
- កិច្ចសហប្រតិបត្តិការមេគង្គឡានឆាង ជាមួយសាធារណរដ្ឋប្រជាមានិតចិន មហាអនុតំបន់មេគង្គ និងគណៈកម្មការទន្លេមេគង្គ។

**ខ. ព័ត៌មានសង្ខេបស្តីពីក្របខ័ណ្ឌការងារកិច្ចសហប្រតិបត្តិការមេគង្គ**

កិច្ចសហប្រតិបត្តិការមេគង្គ-គង្គា ត្រូវបានបង្កើតឡើងចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០០០ ដែលមាន ប្រទេសជាសមាជិកចំនួន៦គឺ កម្ពុជា ឡាវ មីយ៉ាន់ម៉ារ ថៃ វៀតណាម និងឥណ្ឌា។ កិច្ចសហ

ប្រតិបត្តិការនេះ គ្របដណ្តប់លើវិស័យចំនួន៥គឺ ៖ ទេសចរណ៍ វប្បធម៌ អប់រំ បច្ចេកវិទ្យាព័ត៌មានវិទ្យា និងដឹកជញ្ជូន។ ស្ថិតក្រោមកិច្ចសហប្រតិបត្តិការនេះ សារមន្ទីរវាយនភណ្ឌប្រពៃណី អាស៊ី មានទីតាំងនៅខេត្តសៀមរាប ប្រទេសកម្ពុជា ត្រូវបានបង្កើតឡើង និងបើកឲ្យសាធារណជនចូលទស្សនាចាប់តាំងពីឆ្នាំ២០១៤ ដើម្បីតាំងបង្ហាញនូវ វាយនភណ្ឌ បែបប្រពៃណី និងការសម្តែងសិល្បៈនានារបស់បណ្តាប្រទេសមេគង្គ-គង្គា។ យន្តការដើម្បីពង្រឹង និងអនុវត្ត កិច្ចសហប្រតិបត្តិការមេគង្គគង្គា រួមមាន កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស និងកិច្ចប្រជុំឧត្តមមន្ត្រី។

គំនិតផ្តួចផ្តើមទន្លេមេគង្គក្រោម សហរដ្ឋអាមេរិក ត្រូវបានបង្កើតឡើងចាប់តាំងពីឆ្នាំ២០០៩។ គំនិតផ្តួចផ្តើមនេះគឺជាដៃគូពហុភាគីក្នុងចំណោមប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ារ ថៃ វៀតណាម និងសហរដ្ឋអាមេរិក ដើម្បីបង្កើតកិច្ចសហប្រតិបត្តិការសមាហរណកម្មអនុតំបន់ក្នុងចំណោមប្រទេស មេគង្គក្រោមទាំង៥។ គំនិតផ្តួចផ្តើមនេះក៏ជា វេទិកាដោះស្រាយបញ្ហាពិបាកៗ និងបញ្ហាប្រឈមនៃ ការអភិវឌ្ឍន៍ និងនយោបាយអន្តរប្រទេស នៅក្នុងអនុតំបន់មេគង្គក្រោម។ គំនិតផ្តួចផ្តើមនេះ ផ្តោតលើសសរស្តម្ភចំនួន៦គឺ កសិកម្ម និងសន្តិសុខស្បៀង ការតភ្ជាប់ ការអប់រំ សន្តិសុខថាមពល បរិស្ថាន ទឹក និងសុខភាព។ យន្តការដើម្បីពង្រឹង និងអនុវត្តកិច្ចសហប្រតិបត្តិការគំនិតផ្តួចផ្តើមមេគង្គ ក្រោម រួមមាន កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស កិច្ចប្រជុំឧត្តមមន្ត្រី និងកិច្ចប្រជុំក្រុមការងារថ្នាក់តំបន់។



មិត្តរបស់ទន្លេមេគង្គក្រោម ត្រូវបានបង្កើតឡើងនៅខែកក្កដា ឆ្នាំ២០១១ ក្នុងគោលបំណងបម្រើជា វេទិកាប្រជុំ និងយន្តការមួយដ៏សំខាន់ ដើម្បីធ្វើឲ្យការសម្របសម្រួលជាមួយប្រទេសដៃគូមេគង្គ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងអង្គការពហុភាគី កាន់តែប្រសើរឡើង សម្រាប់កម្មវិធីជំនួយអភិវឌ្ឍន៍ នៅក្នុងអនុតំបន់មេគង្គ។ ប្រទេសស្ថាប័ន ជាសមាជិក រួមមាន កម្ពុជា ឡាវ មីយ៉ាន់ម៉ារ ថៃ វៀតណាម អូស្ត្រាលី ជប៉ុន សាធារណរដ្ឋកូរ៉េ ញូវហ្សេលែន សហភាពអឺរ៉ុប ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារ

ពិភពលោក។ កិច្ចសហប្រតិបត្តិការនេះ មានទិសដៅសំខាន់ពីរ៖ កិច្ចសន្ទនាក្នុងចំណោម បណ្តា (១) កិច្ចសន្ទនា នយោបាយ (២) ប្រទេសជាដៃគូ បណ្តាទីភ្នាក់ងារអភិវឌ្ឍន៍ និងស្ថាប័នអភិវឌ្ឍន៍ពហុភាគី ប្រចាំឆ្នាំរវាងក្រសួងការបរទេស។ យន្តការដើម្បីពង្រឹង និងអនុវត្តកិច្ចសហប្រតិបត្តិការ មិត្តរបស់មេគង្គក្រោម រួមមាន កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី និងកិច្ចប្រជុំឧត្តមមន្ត្រី។

កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង (ជាមួយសាធារណរដ្ឋប្រជាមានិតចិន ត្រូវបានបង្កើតឡើងចាប់ តាំងពីខែវិច្ឆិកា ឆ្នាំ២០១៥) ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម នៅក្នុង ប្រទេសអនុតំបន់មេគង្គ កាត់បន្ថយគម្លាតអភិវឌ្ឍន៍ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការ គ្រប់ជ្រុង ជ្រោយរវាងអាស៊ាន និងចិន។ ប្រទេសសមាជិកនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង រួមមាន កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ារ ថៃ និងវៀតណាម។ កិច្ចសហប្រតិបត្តិការនេះផ្តោតលើ សរសរស្តម្ភចំនួនបី៖

១-កិច្ចសហប្រតិបត្តិការនយោបាយ-សន្តិសុខ

២-ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព

៣-ការផ្លាស់ប្តូរទំនាក់ទំនងសង្គមវប្បធម៌ប្រជាជន និងប្រជាជន

និងវិស័យអាទិភាពចំនួន៥ គឺ៖ ការតភ្ជាប់សមត្ថភាពផលិត កិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ចឆ្លងដែនធនធានទឹកនិងកសិកម្មនិងការកាត់បន្ថយភាពក្រីក្រ។

មូលនិធិពិសេសមេគង្គឡានឆាង ត្រូវបានបង្កើត និងដាក់ឲ្យដំណើរការដើម្បីគាំទ្រ គម្រោងខ្នាតតូចនិងមធ្យមនៃបណ្តាប្រទេសមេគង្គឡានឆាង។ នៅក្នុងឆ្នាំ ២០១៧ ប្រទេសសមាជិក បានបង្កើតនូវលេខាធិការដ្ឋានជាតិអង្គភាពសម្របសម្រួលចំណុះក្រសួងការបរទេសរៀងៗខ្លួន។ យន្តការដើម្បីពង្រឹង និងអនុវត្តកិច្ចសហប្រតិបត្តិការនេះរួមមាន កិច្ចប្រជុំកំពូល កិច្ចប្រជុំ រដ្ឋមន្ត្រីការបរទេស កិច្ចប្រជុំឧត្តមមន្ត្រី កិច្ចប្រជុំក្រុមការងារវិស័យការបរទេស និងកិច្ចប្រជុំក្រុមការងារ រួមតាមវិស័យអាទិភាពនីមួយៗ។

មហាអនុតំបន់មេគង្គ (Greater Mekong Sub-region-GMS) គឺជាកិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ចអនុតំបន់ដែលបានបង្កើតឡើងដើម្បី ពង្រឹងទំនាក់ទំនងផ្នែកសេដ្ឋកិច្ចនៅក្នុងចំណោម ប្រទេសទាំង៦ នៃមហាអនុតំបន់មេគង្គដែលរួមមានកម្ពុជា ចិន ឡាវ (ខេត្តយូណាន និងតំបន់ ស្វ័យតហ្គ័ងស៊ី) មីយ៉ាន់ម៉ារ ថៃ និងវៀតណាម។ កម្មវិធីនៃកិច្ចសហប្រតិបត្តិការនេះបាន ចាប់ផ្តើមនៅឆ្នាំ១៩៩២ ក្រោមការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី។ វិស័យអាទិភាពនៃកម្មវិធី កិច្ចសហប្រតិបត្តិការមហាអនុតំបន់មេគង្គ រួមមាន ដឹកជញ្ជូន ថាមពល ទូរគមនាគមន៍ បរិស្ថាន ការអភិវឌ្ឍន៍ធនធានមនុស្ស ទេសចរណ៍ ពាណិជ្ជកម្ម ការវិនិយោគវិស័យឯកជន និងកសិកម្ម។ កម្ពុជាមានលេខាធិការដ្ឋានជាតិ

មហាអនុតំបន់មេគង្គ ជាអ្នកសម្របសម្រួល និងអនុវត្តកម្មវិធី ខាងលើនេះ ដែលស្ថិតនៅក្រោមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

គណៈកម្មការទន្លេមេគង្គ MRC ត្រូវបានបង្កើតឡើងជាផ្លូវការចាប់តាំងពីឆ្នាំ១៩៩៥ គណកម្មការ នេះ គឺជាអង្គការអន្តររដ្ឋាភិបាលមួយ ដែលធ្វើការដោយផ្ទាល់ជាមួយរដ្ឋាភិបាលនៃប្រទេស កម្ពុជា ឡាវ ថៃ និងវៀតណាម ដើម្បីធ្វើការគ្រប់គ្រងរួមគ្នា លើការចែករំលែកធនធានទឹក និងការអភិវឌ្ឍន៍ អាងទន្លេមេគង្គប្រកបដោយចីរភាព។ គណៈកម្មការទន្លេមេគង្គ មានលេខាធិការដ្ឋានរបស់ខ្លួន នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។ ប្រទេសសមាជិកនីមួយៗ មានគណៈកម្មាធិការជាតិទន្លេមេគង្គ ខ្លួនសម្របសម្រួល និងអនុវត្តការងាររបស់ខ្លួន។ យន្តការសំខាន់ៗរបស់គណៈកម្មការ ទន្លេមេគង្គ រួមមានកិច្ចប្រជុំកំពូល កិច្ចប្រជុំក្រុមប្រឹក្សាសមាជិក គណៈកម្មការទន្លេមេគង្គ កិច្ចប្រជុំ គណៈកម្មាធិការរួម នៃគណៈកម្មការទន្លេមេគង្គ និងកិច្ចប្រជុំក្រុមការងារបច្ចេកទេសមួយចំនួនទៀត។ គណៈកម្មការទន្លេមេគង្គមានដៃគូសន្ទនាចំនួនពីរគឺ ប្រទេសចិន និងមីយ៉ាន់ម៉ារ និងដៃគូរអភិវឌ្ឍន៍ និងអង្គការ ជាដៃគូរមួយចំនួនដូចជាអូស្ត្រាលី បែលហ្ស៊ិក ដាណឺម៉ាក សហគមន៍អឺរ៉ុប ហ្វាំងឡង់ បារាំង អាល្លឺម៉ង់ ជប៉ុន ឡុចហ្សំបួរ ធនាគារពិភពលោក ហូឡង់ ស្វីស និងសហរដ្ឋអាមេរិក ធនាគារ អភិវឌ្ឍន៍អាស៊ី អាស៊ាន អង្គការកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ និង UNESCAP ។

**គ. ការពាក់ព័ន្ធរបស់កម្ពុជា និងអត្ថប្រយោជន៍នៃកិច្ចសហប្រតិបត្តិការសម្រាប់កម្ពុជា**

កម្ពុជាបានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចសហប្រតិបត្តិការខាងលើតាមរយៈការលើកគម្រោងនានា ការអនុវត្តគម្រោង ការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំ និងចូលរួមកិច្ចប្រជុំពាក់ព័ន្ធ។

កម្ពុជាទទួលបាននូវ អត្ថប្រយោជន៍ជាច្រើនពីកិច្ចសហប្រតិបត្តិការខាងលើនេះ ជាពិសេសលើវិស័យអភិវឌ្ឍន៍ធនធានមនុស្ស ការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ ការពង្រីកវិស័យពាណិជ្ជកម្មជាមួយប្រទេសក្នុងតំបន់ និងពិភពលោក ការទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និងការរីកចម្រើនលើវិស័យទេសចរណ៍ ។ល។

## ២.៣. ការចូលរួមយ៉ាងសកម្មរបស់កម្ពុជាក្នុងឆាកអន្តរជាតិ

⇒ **កម្ពុជាទទួលបានជោគជ័យលើឆាកអន្តរជាតិ ក្នុងកិច្ចការការពារសម្បត្តិវប្បធម៌ពិភពលោក**

តួនាទីជាប្រធានគណៈកម្មាធិការ នៃអនុសញ្ញាទីក្រុងឡាអេឆ្នាំ១៩៥៤ របស់អង្គការយូណេស្កូ ស្តីពីកិច្ចការពារសម្បត្តិវប្បធម៌ ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ គឺជាជោគជ័យថ្មីមួយទៀត នៃគោលនយោបាយអភិរក្ស និងលើកតម្លៃបេតិកភណ្ឌវប្បធម៌របស់មនុស្សជាតិ ដែលត្រូវបានលើកស្ទួយ បានបង្ហាញយ៉ាងច្បាស់នូវតួនាទីកាន់តែសំខាន់ និងឈានមុខរបស់កម្ពុជានៅលើឆាកអន្តរជាតិ ជា

ពិសេសនៅក្នុងវិស័យបេតិកភណ្ឌ និងវប្បធម៌សម្រាប់មនុស្សជាតិ។ នេះបើយោងតាមសារលិខិតរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦នេះ។

នាយករដ្ឋមន្ត្រីកម្ពុជា បានសរសេរក្នុងសារលិខិតថា ប្រទេសកម្ពុជាត្រូវបានជ្រើសរើសជាឯកច្ឆ័ន្ទឱ្យធ្វើជាប្រធានគណៈកម្មាធិការ នៃអនុសញ្ញាទីក្រុងឡាអេឆ្នាំ១៩៥៤ របស់អង្គការយូណេស្កូ ស្តីពីកិច្ចការពារសម្បត្តិវប្បធម៌ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ នៅក្នុងកិច្ចប្រជុំលើកទី១១របស់ខ្លួន ដែលបានប្រព្រឹត្តិទៅនៅទីស្នាក់ការកណ្ដាលអង្គការយូណេស្កូ នាទីក្រុងប៉ារីស នៅថ្ងៃទី៨ ដល់ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៦។ ការជ្រើសរើសប្រទេសកម្ពុជាជាប្រធានគណៈកម្មាធិការនេះ គឺអាស្រ័យដោយសារការចូលរួមយ៉ាងសកម្មដ៏លេចធ្លោរបស់ប្រទេសកម្ពុជា ក្នុងការងារពង្រឹងការអនុវត្តអនុសញ្ញាទីក្រុងឡាអេឆ្នាំ១៩៥៤ នាពេលកន្លងមក ជាពិសេសការយកចិត្តទុកដាក់ និងកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មការជាតិយូណេស្កូកម្ពុជា ប្រតិភូអចិន្ត្រៃយ៍របស់ប្រទេសកម្ពុជាប្រចាំអង្គការយូណេស្កូ និងគណៈប្រតិភូកម្ពុជា ក្នុងការចលនាស្វែងរកការគាំទ្រពីសំណាក់ភាគីពាក់ព័ន្ធ ទើបសមាជិកនៃគណៈកម្មាធិការទាំងអស់ បានសម្រេចជ្រើសរើសកម្ពុជា ធ្វើជាប្រធានសម្រាប់អណត្តិ២០១៦ ២០១៧ ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់ខ្លឹមសារបន្ថែមថា៖ ប្រការដែលគួរឱ្យកត់សម្គាល់ និងជាមោទនភាព គឺក្នុងចន្លោះពេលតែបីឆ្នាំប៉ុណ្ណោះ កម្ពុជាបានធ្វើជាប្រធានគណៈកម្មាធិការនៃអនុសញ្ញាសំខាន់ៗចំនួនពីរ នៃអង្គការយូណេស្កូ ពោលគឺ ប្រធានគណៈកម្មាធិការបេតិកភណ្ឌពិភពលោក នៃអនុសញ្ញាឆ្នាំ១៩៧២ ស្តីពីការការពារបេតិកភណ្ឌវប្បធម៌ និងធម្មជាតិពិភពលោក កាលពីឆ្នាំ២០១៣ និងជាប្រធានគណៈកម្មាធិការនៃអនុសញ្ញាទីក្រុងឡាអេឆ្នាំ១៩៥៤ នាពេលនេះ។ កិច្ចការដ៏សំខាន់លើកឆាកអន្តរជាតិទាំងនេះ ពិតជាបានរួមចំណែកលើកតម្កើងកិត្តិស័ព្ទរបស់ប្រទេសកម្ពុជាកាន់តែប្រសើរឡើងថែមទៀត។

គួររំលឹកផងដែរថា គិតត្រឹមថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ មានប្រទេសចំនួន១២៧ ជា រដ្ឋភាគីនៃអនុញ្ញាឆ្នាំ១៩៥៤ ក្នុងនោះ ១០៤ប្រទេសជារដ្ឋភាគីនៃពិធីសារទី១ឆ្នាំ១៩៥៤ និងមាន ៦៩ប្រទេសបានចូលជារដ្ឋភាគីនៃពិធីសារទី២។ ពិធីសារទី២ គឺជាក្របខណ្ឌគតិយុត្តិដ៏មានសារសំខាន់ ដោយបានបង្កើតឱ្យមាន «គណៈកម្មាធិការដើម្បីការពារបេតិកភណ្ឌវប្បធម៌ ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ» ដែលជាយន្តការសម្រាប់អនុវត្តអនុសញ្ញាឆ្នាំ១៩៥៤ ជាមួយនឹងមុខងារចម្បងក្នុងការផ្តល់ ផ្អាក ឬលុបចោលកិច្ចការពារពិសេស និងពិនិត្យសម្រេចផ្តល់ជំនួយអន្តរជាតិ ឬប្រើប្រាស់ «មូលនិធិដើម្បីការពារបេតិកភណ្ឌវប្បធម៌ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ»។ អនុសញ្ញាទីក្រុងឡាអេឆ្នាំ១៩៥៤នេះ កាន់តែទទួលបានការយកចិត្តទុកដាក់ខ្ពស់ ជាពិសេសក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ

ដោយសារការវិវត្តនៃសភាពការណ៍សកលលោក ពោលគឺការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សម្បត្តិបេតិកភណ្ឌវប្បធម៌នៅជុំវិញពិភពលោក ជាក់ស្តែង នៅមជ្ឈឹមបូព៌ា។

⇒ **កិច្ចពិភាក្សាការងារទ្វេភាគីរវាងកម្ពុជា និងឯកអគ្គរដ្ឋទូតនៃប្រទេសអឺរ៉ុប**

ជំនួបពិភាក្សាការងារទ្វេភាគីរវាងឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន ជាមួយឯកឧត្តម George Edgar ជំនួបពិភាក្សាការងារទ្វេភាគីរវាងឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន ជាមួយឯកឧត្តម George Edgar ឯកអគ្គរដ្ឋទូតអឺរ៉ុបប្រចាំនៅកម្ពុជា នាថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៦។



កាលពីថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១៦ វេលាម៉ោង ០៩៣០ នាៈទីព្រឹក **ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឱ្យឯកឧត្តម **George Edgar** ឯកអគ្គរដ្ឋទូតនៃសហភាពអឺរ៉ុប ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

នៅក្នុងជំនួបនេះ ឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** បានជម្រាបជូនឯកអគ្គរដ្ឋទូតរបស់សហភាពអឺរ៉ុប ផ្តោតទៅលើចំណុច៣សំខាន់ គឺ ៖

១–អំពីការរីកចំរើនផ្នែកសេដ្ឋកិច្ចនៅកម្ពុជាហើយនិងការប្រព្រឹត្តិទៅជាប្រក្រតីធម្មតានៃជីវភាពរស់ នៅរបស់ប្រជាជន ដោយឧបនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់ពីការរីកចំរើនលើផ្នែកសេដ្ឋកិច្ច ដែលកម្ពុជាសម្រេចបានប្រមាណ ៧,៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ដែលបង្ហាញឱ្យឃើញច្បាស់ពីការខិតខំយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍប្រទេសជាតិ។ ក្នុងចំណុចនេះ ឯកឧត្តមទេសរដ្ឋមន្ត្រីក៏បានគូសបញ្ជាក់ ពីការប្រព្រឹត្តទៅ ជាធម្មតានៃជីវភាព រស់នៅរបស់ប្រជាជនកម្ពុជា ដូចជា ការប្រកបរបររកស៊ី សាលារៀន ការកំសាន្តសប្បាយផ្សេ

ងៗ។ល។ ដែលពុំមានសញ្ញាណណាមួយបង្ហាញឱ្យឃើញថា សភាពការណ៍ នៅកម្ពុជាមានភាពតានតឹង គួរឱ្យព្រួយបារម្ភនោះទេ។

២– អំពីការខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំសម្រាប់ការបោះឆ្នោតឃុំសង្កាត់នៅឆ្នាំ ២០១៧ក៏ដូចជាការបោះឆ្នោតជាតិនៅឆ្នាំ២០១៨ដែលនៅក្នុងនោះឧបនាយករដ្ឋមន្ត្រីបានសង្កត់ធ្ងន់ទៅលើការធ្វើវិសោធនកម្ម នៃច្បាប់បោះឆ្នោតការរៀបចំឡើងវិញ នូវគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពិសេសការចុះឈ្មោះបោះឆ្នោតដែលទើបនឹងបានបញ្ចប់ថ្មីៗនេះ ដើម្បីរៀបចំឡើងវិញនូវបញ្ជីបោះឆ្នោតថ្មីឆ្នាំ ២០១៦ សម្រាប់ការបោះឆ្នោតនាពេលខាងមុខនេះ ហើយដែលការចុះឈ្មោះបោះឆ្នោតនេះ សម្រេចបានលទ្ធផលមួយគួរឱ្យមានការចាប់អារម្មណ៍ខ្លាំង គឺប្រជាជនចំនួនប្រមាណ៨១%នៃចំនួនប្រជាជនដែលមានអាយុគ្រប់បោះឆ្នោតបានទៅចុះឈ្មោះបោះឆ្នោត។ ក្នុងស្មារតីនេះឧបនាយករដ្ឋមន្ត្រីក៏បានថ្លែងអំណរគុណដល់សហភាពអឺរ៉ុប ដែលបាន ជួយឧបត្ថម្ភ និងផ្តល់កិច្ចសហការដល់ការចុះឈ្មោះបោះឆ្នោតនេះ។

ក្នុងការត្រៀមរៀបចំការបោះឆ្នោតនេះ **ឧបនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់អំពីការខិតខំរបស់គណបក្សប្រជាជនកម្ពុជា ក៏ដូចជាការខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការយកចិត្តទុកដាក់ដោះស្រាយនូវរាល់បញ្ហាពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃ និងរាល់សំណូមពររបស់ប្រជាជន ដែលបានបង្ហាញឱ្យឃើញច្បាស់ ពីការខិតខំរបស់គណបក្សប្រជាជន ដើម្បីទទួលបានការគាំទ្ររបស់ប្រជាជនដែលជាមូលដ្ឋានសម្រាប់ធានានូវជោគជ័យក្នុងការបោះឆ្នោត ដោយសេរី និងត្រឹមត្រូវ ពុំមែនដូចជាការចោទប្រកាន់គ្មានមូលដ្ឋានរបស់ជនអគតិខ្លះ ចំពោះគណបក្សប្រជាជនកម្ពុជាឡើយ ។

**៣**– អំពីការវិវត្តន៍នៃសភាពការណ៍នាពេលបច្ចុប្បន្ននេះ ដោយ **ឧបនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់ទៅលើការលើកលែងទោសចំពោះឯកឧត្តម កឹម សុខា បន្ទាប់ពីឯកឧត្តម កឹម សុខា សរសេរលិខិតស្នើសុំទៅសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** សូមឱ្យទូលថ្វាយ**ព្រះករុណា ព្រះមហាក្សត្រ** លើកលែងទោសដល់រូបគាត់ ការវិលត្រឡប់របស់គណបក្សសង្គ្រោះជាតិ ចូលរួមក្នុងកិច្ចប្រជុំរបស់រដ្ឋសភា ហើយនិងសកម្មភាពចូលរួមរបស់គណបក្សសង្គ្រោះជាតិ នៅក្នុងសកម្មភាពនានារបស់រដ្ឋសភាព្រមទាំងលទ្ធភាពដែលអាចមានការជួបសន្ទនាគ្នារវាងក្រុមសភាភាគច្រើន និងក្រុមសភាភាគតិច នៅពេលខាងមុខ។

ក្នុងចំណុចនេះ **ឧបនាយករដ្ឋមន្ត្រី** ក៏បានលើកឡើងផងដែរ អំពីការពិភាក្សារវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាមួយនឹងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដែលមានទីស្នាក់ការ នៅទីក្រុងហ្សឺណែវ ពិសេសការខិតខំសម្របសម្រួលផ្ទាល់របស់ **ឧបនាយករដ្ឋមន្ត្រី** ស្របតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** របៀត

សម្រេចបាននូវការព្រមព្រៀងគ្នាមួយ និងបានចុះហត្ថលេខាលើអនុស្សរណៈ ស្តីអំពីវត្តមានរបស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បន្តទៀត ។

**ឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ថា រាល់ការលើកឡើងខាងលើនេះ បានបង្ហាញពីការវិវត្តន៍ដ៏ល្អប្រសើរនៃសភាពការណ៍នៅកម្ពុជា ហើយក៏ជាមូលដ្ឋានសម្រាប់ធ្វើការវាយតម្លៃពីសភាពការណ៍នៅកម្ពុជាផងដែរ ។ **ឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ច្បាស់ថា អ្វីដែលឯកឧត្តម ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជាចង់បាន គឺការវាយតម្លៃឱ្យបានត្រឹមត្រូវ និងដោយសត្យានុម័តចំពោះសភាពការណ៍នៅកម្ពុជា។

ឯកឧត្តម George Edgar បានសម្តែងការរីករាយចំពោះការវិវត្តន៍នៃសភាពការណ៍នៅកម្ពុជាក្នុងរយៈពេលថ្មីៗនេះ និងបានធានាអះអាងជាមួយ**ឧបនាយករដ្ឋមន្ត្រី** ថា ជំហររបស់សហភាពអឺរ៉ុប គឺពុំមានការគាំទ្រគណបក្សណាមួយនៅកម្ពុជានោះទេ សហភាពអឺរ៉ុបគ្រាន់តែចង់រក្សាទំនាក់ទំនងល្អជាមួយគណបក្សទាំងអស់ ហើយឯកឧត្តម ក៏ពុំមានបំណងការពារសកម្មភាពណាមួយ ដែលជាការរំលោភបំពានទៅលើច្បាប់របស់កម្ពុជា ឬមានគោលដៅញុះញង់អំពើហិង្សានោះឡើយ។

ឯកឧត្តម George Edgar បានជម្រាបជូន **ឧបនាយករដ្ឋមន្ត្រី** ថា ក្នុងការពិនិត្យមើលពីសភាពការណ៍នៅប្រទេសកម្ពុជាក្នុងពេលកន្លងមក ទាំងរូបឯកឧត្តមផ្ទាល់ និងសហភាពអឺរ៉ុប បានទទួលស្គាល់យ៉ាងច្បាស់ នូវការផ្លាស់ប្តូរជាវិជ្ជមាននិងការអភិវឌ្ឍយ៉ាងច្រើន នៅប្រទេសកម្ពុជា។

ឯកឧត្តម George Edgar បានជម្រាបជូន **ឧបនាយករដ្ឋមន្ត្រី** អំពីការចាប់អារម្មណ៍ខ្ពស់របស់សហភាពអឺរ៉ុប ចំពោះដំណើរការត្រៀមរៀបចំសម្រាប់ការបោះឆ្នោតនៅកម្ពុជា ជាពិសេសគឺការចុះឈ្មោះបោះឆ្នោត ដែលទើបតែនឹងបញ្ចប់ដោយលទ្ធផលល្អនាពេលថ្មីៗនេះ។ ឯកឧត្តមឯកអគ្គរដ្ឋទូតក៏បានបញ្ជាក់ថា សហភាពអឺរ៉ុប នឹងបន្តកិច្ចសហប្រតិបត្តិការ និងផ្តល់ជំនួយឧបត្ថម្ភចំពោះគណៈកម្មាការជាតិរៀបចំការបោះឆ្នោតបន្តទៅទៀត។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងយោគយល់គ្នា។

**⇒លទ្ធផលដំណើរទស្សនៈកិច្ចផ្លូវរដ្ឋរបស់ប្រធានាធិបតីហ្វីលីពីន នៅព្រះរាជាណាចក្រកម្ពុជា**

លទ្ធផលដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ឯកឧត្តម រ៉ូឌ្រីហ្គោ ឌូតឺតេ (Rodrigo Duterte) ប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីននៅព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី១៣១៤ ខែធ្នូ ឆ្នាំ២០១៦-

តបតាមការអញ្ជើញរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ឯកឧត្តម **រ៉ូឌ្រីហ្គោ ឌូតឺតេ** (Rodrigo Duterte) **ប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន** បានដឹកនាំគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី ១៣ ដល់ទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៦។

ឯកឧត្តម រ៉ូឌ្រីហ្គោ ឌូតឺតេ និងគណៈប្រតិភូ បានចូលក្រាបបង្គំគាល់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថនរោត្តមសីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជានៅព្រះបរមរាជវាំង។

ក្នុងអំឡុងពេលការចរចារផ្លូវការដែលបានប្រព្រឹត្តទៅនៅវិមានសន្តិភាពនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០១៦ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តមប្រធានាធិបតី ឌុយតឺតេបានធ្វើការផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមក និងបានពិភាក្សាលើការពង្រឹង និងធ្វើឲ្យស៊ីជម្រៅនូវទំនាក់ទំនងជាមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។សម្តេចតេជោ ហ៊ុន សែន បានស្នើឯកឧត្តមប្រធានាធិបតីឌុយតឺតេ ធ្វើការពិនិត្យពីកាលានុវត្តភាពក្នុងការជម្រុញកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យពាណិជ្ជកម្ម ទេសចរណ៍ ការងារ និងការវិនិយោគលើវិស័យកសិកម្ម ជាពិសេសស្រូវ ព្រមទាំងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន និងការរត់ពន្ធគ្រឿងញៀន។ សម្តេចតេជោនាយករដ្ឋមន្ត្រីក៏បានបញ្ជាក់ពីការគាំទ្រ និងការអបអរសាទររបស់កម្ពុជា ដល់ប្រទេសហ្វីលីពីនដែលនឹងធ្វើជាប្រធានអាស៊ាននៅឆ្នាំ២០១៧។

ឯកឧត្តមប្រធានាធិបតី ឌូតឺតេ បានជំរុញប្រទេសទាំងពីរលើកកំពស់កិច្ចសហប្រតិបត្តិការ ជាពិសេសក្នុងផ្នែកស្រូវ ការអភិវឌ្ឍធនធានមនុស្ស ការតភ្ជាប់រវាងប្រជាជន និងប្រជាជន។ ឯកឧត្តមក៏បានជំរាបជូនសម្តេចតេជោនាយករដ្ឋមន្ត្រី ពីការសម្រេចចិត្តរបស់ឯកឧត្តមក្នុងការផ្តល់អាហារូបករណ៍ចំនួន៦០កន្លែងដល់និស្សិតកម្ពុជាទៅសិក្សានៅហ្វីលីពីន នៅក្នុងឆ្នាំសិក្សា២០១៧។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណហ្វីលីពីនចំពោះការផ្តល់អាហារូបករណ៍ និងជំនួយចំពោះកម្ពុជា។ សម្តេចតេជោនាយករដ្ឋមន្ត្រីបានស្នើឲ្យក្រសួងការបរទេសនៃប្រទេសទាំងពីររៀបចំរួមគ្នាពិធីរំលឹកខួបអនុស្សាវរីយ៦០ ឆ្នាំ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ នៅឆ្នាំ២០១៧ និងរៀបចំកិច្ចប្រជុំលើកទី២របស់គណៈកម្មការចំរុះកិច្ចសហប្រតិបត្តិការទ្វេភាគីដែលរដ្ឋមន្ត្រីការបរទេសនៃប្រទេសទាំងពីរជាប្រធាន។

បន្ទាប់ពីកិច្ចចរចាផ្លូវការ **សម្តេចតេជោនាយករដ្ឋមន្ត្រី និងឯកឧត្តមប្រធានាធិបតីឌុយតឺតេ** បានធ្វើជាសាក្សីក្នុងពិធីចុះហត្ថលេខាលើឯកសារ ដូចខាងក្រោម៖

– អនុស្សារណៈយោគយល់គ្នា រវាងនគរបាលជាតិនៃព្រះរាជាណាចក្រកម្ពុជា និងនគរបាលជាតិនៃសាធារណរដ្ឋហ្វីលីពីន ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលត្រូវបានចុះហត្ថលេខាដោយឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងឯកឧត្តម Perfector Yasay រដ្ឋមន្ត្រីការបរទេសហ្វីលីពីន

– អនុស្សារណៈនៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ ដែលត្រូវបានចុះហត្ថលេខាដោយឯកឧត្តម អ៊ិត

សំហោង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងឯកឧត្តម Perfector Yasay រដ្ឋមន្ត្រីការបរទេសហ្វីលីពីន

– អនុស្សារណៈនៃកិច្ចព្រមព្រៀងរវាងក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា និងគណកម្មាការកីឡានៃសាធារណរដ្ឋហ្វីលីពីន ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យកីឡា ដែលត្រូវបានចុះហត្ថលេខាដោយឯកឧត្តម ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងឯកឧត្តម Perfector Yasay រដ្ឋមន្ត្រីការបរទេសហ្វីលីពីន និង

– កម្មវិធីអនុវត្តនៃកិច្ចសហប្រតិបត្តិការវិស័យទេសចរណ៍ រវាងក្រសួង (២០២០-២០១៦) ទេសចរណ៍នៃព្រះរជាណាចក្រកម្ពុជា និងក្រសួងទេសចរណ៍នៃសាធារណរដ្ឋហ្វីលីពីនដែលត្រូវបានចុះហត្ថលេខាដោយ ឯកឧត្តមបណ្ឌិត ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងលោកជំទាវ Wanda Corazon Tulfo-Teo រដ្ឋមន្ត្រីទេសចរណ៍ហ្វីលីពីន។

**⇒ ទស្សនៈកិច្ចផ្លូវការរបស់កម្ពុជានៅសាធារណៈរដ្ឋសង្គមនិយមវៀតណាម សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំប្រតិភូជាន់ខ្ពស់ អញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅសារធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី ២០ ដល់ទី ២១ ខែ ធ្នូ ឆ្នាំ ២០១៦**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំគណៈប្រតិភូជាន់ខ្ពស់ អញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅសារធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី ២០ ដល់ទី ២១ ខែ ធ្នូ ឆ្នាំ ២០១៦ តបតាមការអញ្ជើញរបស់ឯកឧត្តម ង្វៀន សួន ហ្វ៊ុក (Nguyen Xuan Phuc) នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ឯកឧត្តម ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ និងឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នឹងអញ្ជើញអមដំណើរ សម្តេចតេជោនាយករដ្ឋមន្ត្រី រួមជាមួយឥស្សរជនជាន់ខ្ពស់ដទៃទៀត ដូចជា៖

- ឯកឧត្តម វ៉ា គីមហុង ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការព្រំដែន
- ឯកឧត្តម អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ
- ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល
- ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង

សមាជិករាជរដ្ឋាភិបាលកម្ពុជាដទៃទៀត។

ក្នុងអំឡុងពេលទស្សនៈកិច្ចនេះ សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នឹងជួប ពិភាក្សាទ្វេភាគីជាមួយឯកឧត្តម ង្វៀន សួនហ្វ៊ុក ហើយនិងជួបសម្តែងការគួរសមដោយឡែកៗពីគ្នាជាមួយឯកឧត្តម ង្វៀន ហ្វ៊ូ ជុង (Nguyen Phu Trong) អគ្គលេខាធិការបក្សកុម្មុយនិស្តវៀតណាម ឯកឧត្តម ត្រាន់ ដាយ ក្វាង (Tran Dai Quang) ប្រធានាធិបតីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងលោកជំទាវ ង្វៀន ធីគីម ង៉ិន (Nguyen Thi Kim Ngan) ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម។កិច្ចព្រមព្រៀងអនុស្សារណៈមួយចំនួនត្រូវបានរំពឹងទុកថា នឹង ត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងសមភាគីវៀតណាម ផងដែរ។ក្រៅពីនេះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក៏ នឹង ទទួលការជួបសម្តែងការគួរសម របស់សមាគមមិត្តភាពកម្ពុជា-វៀតណាម ថ្នាក់ដឹកនាំទីក្រុងហូជីមិញ និងអតីតយុទ្ធជនវៀតណាម ព្រមទាំងសមាជិកគ្រួសារផងដែរ។

⇒ **ដើម្បីលើកមុខមាត់របស់ខ្លួននៅលើឆាកអន្តរជាតិ កម្ពុជាត្រៀមខ្លួនរួចជាស្រេចក្នុងការចូលរួមយ៉ាងសកម្មជាមួយអង្គការសហប្រជាជាតិ**

- កម្ពុជាត្រៀមខ្លួនធ្វើជាអនុប្រធានមហាសន្និបាតរបស់អង្គការសហប្រជាជាតិនៃសម័យប្រជុំលើកទី៧៣ សម្រាប់រយៈពេល១ឆ្នាំ ចាប់ពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០១៩។
- កម្ពុជាគឺជា បេក្ខភាពក្នុងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមអ.ស.ប សម្រាប់ឆ្នាំ២០១៩។
- កម្ពុជាត្រូវបានជ្រើសរើសជាសមាជិក នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោកក្នុងគ្រាមានជម្លោះប្រដាប់អាវុធជាលើកទី២ ចាប់ពីឆ្នាំ២០១៧ ដល់ ២០២១ នៅទីក្រុងប៉ារីស។

# ជំពូកទី ៣
# បញ្ហាប្រឈម និងដំណោះស្រាយ
# នៃគោលនយោបាយការទូត

# ជំពូកទី៣ ៖ បញ្ហាប្រឈម និងដំណោះស្រាយនៃគោលនយោបាយការទូត

## ៣.១. បញ្ហាប្រឈមទូទៅនៃគោលនយោបាយការទូត

ទោះបីជាមានការអភិវឌ្ឍន៍ជាច្រើននៅលើវិស័យទំនាក់ទំនងការទូត ក៏ពិតមែនប៉ុន្តែប្រទេសកម្ពុជាក៏នៅតែមានបញ្ហាប្រឈមជាមួយកត្តាជាច្រើន ដូចជា កត្តាការអនុវត្តន៍ច្បាប់ កត្តាធនធានមនុស្ស និងកត្តាហិរញ្ញវត្ថុ ជាដើម។ ទាំងអស់នេះក៏ជាកត្តា ដែលធ្វើឲ្យប្រទេសខ្លះមានការស្ទាក់ស្ទើរ ក្នុងការដំណើរការវិស័យការបរទេសជាមួយប្រទេសកម្ពុជា។

ការដែលមិនពង្រឹងលើការអនុវត្តន៍ច្បាប់ មិនត្រឹមតែមានការប៉ះពាល់តែមួយចំណែកណាមួយ នៃប្រទេសនោះទេ តែមានការប៉ះទង្គិចទៅដល់កត្តាមួយចំនួនដែលសុទ្ធសឹងតែជាការចាំបាច់និងកត្តា ដែលសំខាន់ក្នុងនាពេលបច្ចុប្បន្ននេះ។ កត្តាមួយចំនួនមិនទាន់មានការដាក់អោយអនុវត្តនៅឡើយ ដែលក្នុងនោះមានការធ្វើអោយខូចខាតចំពោះកត្តាមួយចំនួនដូចជា៖

### ៣.១.២. ការអនុវត្តន៍ច្បាប់

នៅក្នុងការអនុវត្តន៍ច្បាប់ នៅក្នុងប្រទេសប្រទេសកម្ពុជា នាពេលបច្ចុប្បន្ន មានការល្អប្រសើជាងពេលអតីតកាលមែនក្តី ប៉ុន្តែមិនទាន់មានភាពពេញលេញស្របតាមស្តង់ ដារអន្តរជាតិនៅឡើយទេ នេះជាមូលហេតុមួយផ្នែកដែលធ្វើឲ្យប្រទេសខ្លះមានការភ័យខ្លាច ក្នុងការបង្កើតទំនាក់ទំនងការទូតជាមួយកម្ពុជា។

ហើយកត្តាទាំងនោះមានដូចជាការគោរពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា នៅមានចន្លោះខ្វះខាតនៅឡើយ។ ដោយយោងតាម លោកស្រី អារុណា ខេសៃយ៉ាប់(Aruna Kashyap) អ្នកស្រាវជ្រាវ។

សិទ្ធិស្ត្រីថ្នាក់ខ្ពស់នៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស បានបង្ហាញថារដ្ឋាភិបាលកម្ពុជា គួរចាត់វិធានការជាប្រញ៉ាប់ ដើម្បីប្រែក្រឡាស់ប្រវត្តិដ៏សែនអាក្រក់នៃការគោរពសិទ្ធិការងាររបស់ខ្លួន និងការពារកម្មករពីការរំលោភ។ អង្គការឃ្លាំមើលសិទ្ធិបានរកឃើញថា រោងចក្រជាច្រើនបានចេញកិច្ចសន្យារយៈពេល ខ្លីខុសច្បាប់ ដើម្បីជៀសវាងការបង់តម្លៃសម្រាប់មាតុភាពរបស់កម្មការីនី និងប្រាក់អត្ថប្រយោជន៍ដទៃទៀត និងដើម្បីបំភិតបំភ័យ និងត្រួតត្រាលើពួកគេ។ ស្ត្រីមានចំនួនរហូតដល់ ៩ % នៃកម្មករកាត់ដេរជាង ៧០០,០០០ នាក់ ធ្វើការក្នុងមុខរបរកាត់ដេរចំនួន ១,២០០ រងចក្រ នេះបើយោងតាមក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

យោងតាមអង្គការសហប្រជាជាតិបានថ្លែងថា សកម្មជនដីធ្លីនិងផ្ទះសម្បែង បុគ្គលិកសិទ្ធិមនុស្ស អ្នកសារព័ត៌មានថ្នាក់ដឹកនាំសហជីព សកម្មជនបរិស្ថានត្រូវបានចាប់ខ្លួន ព្រមទាំងប្រឈមនឹ

ការគំរាមកំហែងផ្លូវច្បាប់ នេះហើយជាមូលហេតុ ដែលស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា កំពុងប្រឈមមុខ នឹងការរិះគន់ទាំងក្នុងប្រទេសនិងសហគមន៍អន្តរជាតិ។

ចរាចរណ៍នៅប្រទេសកម្ពុជាក៏ផ្តល់ភាពភ័យព្រួយដល់ ដំណើរកាទំនាក់ទំនងរបស់កម្ពុជាជាមួយប្រទេសដ៏ទៃផងដែរ។

លោក រុន រ័ត្នវាសនា ប្រធាននាយកដ្ឋាននគរបាលចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈនៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានប្រាប់ VOA ថា ក្នុងមួយឆ្នាំពេញនៃឆ្នាំ២០១៨ គ្រោះថ្នាក់ចរាចរណ៍កើតឡើងចំនួនជាង៣ពាន់លើក(៣២៦៧)។ លោកបន្ថែមថា មនុស្សស្លាប់ ក្នុងគ្រោះថ្នាក់ចរាចរណ៍នោះដោយរាប់តែនៅលើផ្លូវ មិនរាប់តាមមន្ទីរពេទ្យគឺមាន ចំនួនជិត១៨០០នាក់ (១៧៦១នាក់)ចំណែកអ្នករងរបួសទាំងធ្ងន់និងស្រាលមានចំនួនជិត៥ពាន់នាក់។ ស្ថានភាពនេះ នៅតែ ជាបញ្ហាគួរឲ្យបារម្ភ ខណៈដែលសីលធម៌ក្នុងការបើកបរ និងការមិនគោរពច្បាប់របស់ប្រជាពលរដ្ឋគឺ ជាកត្តាចម្បងដែលបណ្តាលឲ្យមានគ្រោះថ្នាក់ចរាចរណ៍។

កត្តាសន្តិសុខសង្គម ប្រទេសកម្ពុជា នៅតែមានករណីចោរឆក់ ដែលកើតឡើងស្ទើរតែជារៀងរាល់ថ្ងៃជាពិសេស នៅក្នុងរាជធានីភ្នំពេញ ខេត្តព្រះសីហនុ នឹង ខេត្តសៀមរាប។ បទល្មើសចោរឆក់មិនត្រឹមតែកើតលើពលរដ្ឋខ្មែរទេ ប៉ុន្តែ វាក៏បានកើតឡើងចំពោះជនបរទេសដែលជាទេសចរដែលមកទស្សនាប្រទេសកម្ពុជាផងដែរ។ ក្នុងករណីខ្លះជនរងគ្រោះជាជនបរទេសដែលជាភ្ញៀវទេសចរ ត្រូវបានចោរឆក់អស់ពីខ្លួននៅក្នុងកាបូប ដែលមានដូចជា លុយ ប៉ាស្ព័រ ទូរស័ព្ទ កាត ATM ដែលផ្តល់ផលវិបាក។

ករណីបែបនេះច្រើនគ្នាទៅ ពួកគេត្រឡប់ទៅស្រុកវិញ ពួកគេចេះតែប្រាប់តៗគ្នា អ្វីដែលកើតឡើងចំពោះពួកគេ ហើយពិបាកដោះស្រាយ ធ្វើឲ្យអ្នកក្រោយៗទៀតញញើតក្នុងការមកដើរកម្សាន្តនៅស្រុកខ្មែរ ដែលជាហេតុដែលប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ ប្រទេសកម្ពុជាក្នុង ការទំនាក់ទំនងផងដែរ។

ដូចជាក្នុងករណី ថ្ងៃទី៧កុម្ភៈឆ្នាំ២០១៩ ក្រុមចោរបានជិះម៉ូតូធ្វើសកម្មភាពឆក់យកកាបូបពីជនបរទេសម្នាក់ ដែលជាភ្ញៀវទេសចរជនជាតិបារាំង ពេលកំពុងជិះកង់នៅចំណុចច្រកចូលវត្តពោធិវាល ស្ថិតក្នុងភូមិរតនៈ សង្កាត់រតនៈ ក្រុងបាត់ដំបង។ ការបាត់បង់នោះមានកាបូបមួយ ហើយនៅក្នុងកាបូបនោះមានលុយចំនួន៥០០ដុល្លារលិខិតឆ្លងដែន១ច្បាប់ លេខ13CY89769 និងប័ណ្ណធនាគារចំនួន២សន្លឹក ។ ស្រ្តីបរទេសរូបនេះបានបញ្ជាក់ថា គាត់បានធ្វើដំណើរដោយជិះកង់ម្នាក់មួយជាមួយនឹងក្រុមគាត់ប៉ុន្មាននាក់ទៀត ដើម្បីដើរទស្សនាកន្លែងទេសចរណ៍ប្រវត្តិសាស្ត្រនានានៅក្នុងក្រុងបាត់

ដំបង ហើយកាបូបដែលត្រូវពួកចោរឆក់យកទៅនោះ គឺគាត់បានទុកនៅក្នុងកន្ត្រកកង់ខាងមុខ លុះពួកគាត់ជិះដល់ចំណុចខាងលើ ក៏ត្រូវជនដៃដល់ជិះមកឆក់យកទៅបាត់តែម្តង ។

ដោយសារកត្តាអនុវត្តន៍ច្បាប់នៅប្រទេសកម្ពុជានៅមានកំរិតនៅឡើយ ទើបធ្វើអោយប្រទេសមួយចំនួនមានការស្ទាក់ស្ទើរក្នុងការវិនិយោគ និងបង្កើតចំណងសហប្រតិបត្តិការការទូតរបស់ពួកគេជា មួយកម្ពុជា ដោយគិតពីសុវត្ថិភាពរបស់ ប្រជាជាតិពួកគេ។

**៣.១.២ កត្តាធនធានមនុស្ស**

ធនធានមនុស្សមានសារសំខាន់ ដែលមិនអាចប្រកែកបាន សម្រាប់ការអភិវឌ្ឍន៍ប្រទេសទាំងអស់នៅក្នុងពិភពលោក មិនថាសម្រាប់ប្រទេសកំពុងតែអភិវឌ្ឍន៍ (developing country) ឬក៏សម្រាប់ប្រទេសដែលអភិវឌ្ឍន៍ហើយនោះទេ (developed country)។ កត្តាធនធានមនុស្ស នៅប្រទេសកម្ពុជាក៏នៅ តែជាបញ្ហាចម្បង ដែលជះឥទ្ធិពលដល់ដំណើរការ ទំនាក់ទំនងការបរទេសផងដែរ។ ដោយកម្ពុជាបានជួបប្រឈម និងងើបពីសង្គ្រាមទាំងក្នុង និងក្រៅប្រទេសជាច្រើនឆ្នាំដូចជា របបខ្មែរក្រហម ជាដើម ដែលជាមូលហេតុធ្វើអោយ ប្រទេសកម្ពុជាពុំទាន់មានសមត្ថភាពពេញលេញក្នុងការប្រាស្រ័យទាក់ទង ដើម្បីផ្លាស់ប្តូរចំណេះដឹង និងទាញយកអត្ថប្រយោជន៍ ពីការបង្កើតទំនាក់ទំនងលើវិស័យការទូតនេះ។ កត្តាកង្វះធនធានមនុស្សដែលមានចំណេះដឹង និងការអប់រំ ស្របតាមស្តង់ដាមិនទាន់គ្រប់គ្រាន់ក៏កត្តាយ៉ាងចម្បង ដែលជាឧបសគ្គ សម្រាប់កម្ពុជានាពេលបច្ចុប្បន្ន។

ដោយយោងតាម លោកហង់ ជួនណារ៉ុន បានឲ្យដឹងថា បញ្ហាប្រឈម ក្នុងប្រព័ន្ធអប់រំនៅកម្ពុជារួមមាន៖ ធនធានមនុស្សខុសជំនាញពីតម្រូវការទីផ្សារ គុណភាពអប់រំនៅមានកម្រិតទាប ការអនុវត្តកម្មវិធីសិក្សាស្ថិតក្រោមស្តង់ដា គុណភាពរបស់គ្រូបង្រៀននៅមានកម្រិត ហេដ្ឋារចនាសម្ព័ន្ធសាលារៀននៅខ្វះខាត កង្វះការប្រើ ប្រាស់សម្ភារៈបច្ចេកវិទ្យាពត៌មាន មន្ទីរពិសោធន៍ក្នុងការបង្រៀន និងការរៀន ទំនាក់ទំនងរវាងគោល នយោបាយការបណ្តុះ បណ្តាលគ្រូក្នុងសាលារៀន និងថ្នាក់រៀនស្ថិតនៅក្នុងសតវត្សរ៍ទី ២០នៅឡើយ។

ថ្លែងនៅក្នុងពិធីបើកសន្និបាតបូកសរុបការងារអប់រំយុវជននិងកីឡា លោក ហង់ ជួនណារ៉ុន រដ្ឋមន្ត្រី ក្រសួងអប់រំយុវជននិងកីឡា បានលើកឡើងថា ដើម្បីដោះស្រាយបញ្ហាធនធានមនុស្សខុសជំនាញ និងការធ្វើពិពិធកម្មនៃកំណើនឧស្សាហាកម្ម ក្រសួងបានចាប់ផ្តើមធ្វើកំណែទម្រង់វិស័យអប់រំ ដើម្បីផ្តល់ ការអប់រំប្រកបដោយគុណភាព និងមូលដ្ឋានគ្រឹះជំនាញដល់យុវវ័យ ដើម្បីឲ្យពួកគេអាចចាប់យកនា ពេលអនាគត ដោយចង់ឲ្យពួកគេទទួលបានចំណេះដឹង ជំនាញទន់ និងបំណិនជីវិត។

**៣.១.៣. កត្តានិស្សិត**

ការអប់រំនៅកម្ពុជាបច្ចុប្បន្នប្រឈមមុខនឹងបញ្ហាសំខាន់ៗដូចជា៖

- វិសមភាពអ្នកចូលរៀន
- បញ្ហាកង្វះថវិការ
- បញ្ហាសិស្សបោះបង់ការសិក្សា
- បញ្ហាសិស្សចូលរៀនត្រួតថ្នាក់
- បញ្ហាសាលារៀននៅឆ្ងាយពីផ្ទះ
- បញ្ហាថ្នាក់រៀនមានមិនគ្រប់កម្រិត
- បញ្ហាប្រពៃណីទំនៀមទំលាប់។
- កត្តាគុណភាពរបស់គ្រូបង្រៀន

គុណភាពរបស់គ្រូបង្រៀននៅមានកម្រិត ដោយសារតែគ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិ ប្រហែល៨០ភាគរយប៉ុណ្ណោះ មានសញ្ញាបត្រយ៉ាងទាបត្រឹមបរិញ្ញាបត្រ និងគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ មានសញ្ញាបត្រយ៉ាងហោច ណាស់ត្រឹមមធ្យមសិក្សាទុតិយភូមិ ។ដូចនេះ ការលើកកម្ពស់គុណភាពគ្រូបង្រៀន ឲ្យស្របតាមគោលនយោបាយ គឺលើកកម្ពស់គ្រូបង្រៀនកម្រិតបឋមសិក្សា។

ធនាគារពិភពលោក បានថ្លែងថា រដ្ឋាភិបាលកម្ពុជាបានបង្កើនកិច្ចខិតខំធ្វើឲ្យមានវឌ្ឍនភាពនៃវិស័យអប់រំសិក្សាធិការនៅកម្ពុជា។ ក៏ប៉ុន្តែសិស្សសាលាមួយចំនួននៅថ្នាក់ទី២មិនទាន់អាចចេះអានអក្សរមួយពាក្យនៅឡើយ។ មន្ត្រីសង្គមស៊ីវិល អះអាងថា កំណែទម្រង់ក្នុងវិស័យអប់រំត្រូវតែបង្កើនឲ្យខ្លាំងថែមទៀត នៅកម្រិតបឋមសិក្សា។

### ៣.១.៤ កត្តាហិរញ្ញវត្ថុ

ធនាគារពិភពលោកបានឲ្យដឹងនៅក្នុងរបាយការណ៍របស់ខ្លួនថាហានិភ័យនានានៅក្នុងវិស័យហិរញ្ញវត្ថុ នឹងបន្តកើនឡើងដែលពាក់ព័ន្ធច្រើនទៅលើវិស័យសំណង់ និងអចលនទ្រព្យ ខណៈហានិភ័យពីមជ្ឈដ្ឋានខាងក្រៅរួមមាន សក្តានុពលនៃការដកប្រព័ន្ធអនុគ្រោះពន្ធលើទំនិញនាំចេញសម្រាប់កម្ពុជា និងផលប៉ះពាល់ដែលមិនអាចព្យាករណ៍ទុកបានដែលកើតចេញពីជម្លោះពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងប្រទេសចិន ។

ដោយកម្ពុជា នៅតែស្ថិតនៅក្នុងចំណាត់ថ្នាក់ ប្រទេសមានប្រាក់ចំណូលមធ្យមទាប ដែលអាចមើលឃើញថា កម្ពុជានៅតែជាប្រទេសកំពុងអភិវឌ្ឍន៍នៅឡើយ។ កត្តាមួយវិញទៀតកម្ពុជា គឺជាប្រទេស ដែលមានការនាំចេញតិចជាងការនាំចូលដែលជាហេតុ ធ្វើអ្នកវិនិយោគមានការស្ទាក់ស្ទើរក្នុង ការសម្រេចចិត្ត ដើម្បីបណ្តាក់ទុនក្នុងកម្ពុជា។

សហភាពអឺរ៉ុប (EU) បានជូនដំណឹងដល់រដ្ឋាភិបាលកម្ពុជា ថា ខ្លួននឹងចាប់ផ្តើមអនុវត្តដំណើរការនីតិវិធីសម្រាប់ការដកការអនុគ្រោះពន្ធក្រោមកម្មវិធី គ្រប់មុខលើកលែងតែអាវុធ ឬ EBA របស់សហភាពអឺរ៉ុប និងថា ដំណើរការនេះអាចនឹងឈានទៅដល់ការព្យួរការអនុគ្រោះពន្ធក្រោមកម្មវិធី EBA ប្រសិនបើកម្ពុជាមិនធ្វើឲ្យមានការកែលម្អច្បាស់លាស់ និងមានភ័ស្តុតាងបញ្ជាក់ទេនោះ។ ប្រសិនបើកម្ពុជាបាត់បង់ឋានៈអនុគ្រោះពន្ធ EBA នេះ វិស័យដែលនឹងរងផលប៉ះពាល់ខ្លាំងជាងគេបំផុត គឺវិស័យកាត់ដេរនិងផលិតស្បែកជើង ដែលផ្តល់ការងារដល់កម្មករជាង ៧សែននាក់។ ទោះយ៉ាងណា វិធានការរបស់សហភាពអឺរ៉ុបជុំវិញការអនុគ្រោះពន្ធ EBA សម្រាប់កម្ពុជានេះ មិនទាន់ជាការបិទផ្លូវទាំងស្រុងនៅឡើយទេ។ នេះក៏ជាផ្នែកមួយ កម្ពុជាប្រឈមមុខក៏ជាចំនុចដែលប្រទេសផ្សេងពិចារណាមុនបណ្តាក់ទុនផងដែរ។

## ៣.២. ដំណោះស្រាយដើម្បីពង្រឹងលើវិស័យកការទូតកម្ពុជា

ថ្វីត្បិតតែកម្ពុជាមានការប្រឈមមុខ ជាមួយកត្តាដូចដែលបានរៀបរាប់ ខាងលើក៏ពិតមែនតែរាជរដ្ឋាភិបាលកម្ពុជា គួរគប្បីធ្វើតាមដំណោះស្រាយ និងផ្តល់ជាការកែតម្រូវទៅ លើកត្តាប្រឈមទាំងអស់នោះដើម្បីអោយមានការវិវត្តន៍ឆ្លើយតប និងបញ្ហានៃកត្តាប៉ះពាល់ខាងលើ ដូចជាៈ

### ៣.២.១. កត្តាធនធានមនុស្ស

- បណ្តុះបណ្តាលមន្ត្រីការទូត មុនចេញទៅធ្វើបេសកកម្ម
- ពង្រឹងពង្រីកចំណេះដឹងដល់សិស្ស និងនិស្សិតដែលប្រកបដោយគុណភាពជាក់ស្តែងគួរតែ មានបញ្ចូលកម្មវិធីសិក្សាដែលពាក់ព័ន្ធ អំពីដំណើរការ និងគោលនយោបាយទំនាក់ទំនងការបរទេស ដល់កំរឹតសិក្សាចាប់ពីថ្នាក់មធ្យមសិក្សា ដែលអាចធ្វើជាប្រយោជន៍ និងជាគ្រឹះ នាំឲ្យយុវជនមានការយល់ដឹង និងអាចទាញយកប្រយោជន៍សម្រាប់មកធ្វើការអភិវឌ្ឍន៍ប្រទេសបាន។
- ត្រូវតែមានការអប់រំ ពីគ្រូដែលមានជំនាញច្បាស់លាស់ដើម្បីអោយនិស្សិត បានទទួលនូវការយល់ដឹងនីមួយៗ អោយស្ទាត់ជំនាញនោះយ៉ាងពិតប្រាកដ
- ពង្រឹងគុណភាពរបស់គ្រូបង្រៀនទៅតាមកំរឹត
- ផ្តល់ឪកាសសម្រាប់ការបណ្តុះបណ្តាលអោយមានការចូលរួម ដើម្បីទទួលបានចំណេះ ដឹងថ្មីៗ
- បន្ថែមអោយមានគ្រឿងសម្ភារៈគ្រប់គ្រាន់ សម្រាប់ការបណ្តុះបណ្តាលតាមស្តង់ដា

- ផ្តល់ឪកាសឲ្យយុវជនបានមានការងារបាត្តការ ជាការរឹតហាត់ដើម្បីពង្រឹងចំណេះរបស់ ខ្លួន ក្នុងបន្តចំណេះរបស់ខ្លួនមួយកម្រិតទៀត
- បង្កើតអោយមានការផ្សព្វផ្សាយនូវចំណេះដឹងផ្សេងៗ ដែលមានចំណេះដឹងបច្ចេកទេស
- ផ្តល់ឱកាសឲ្យក្មេងៗបានសិក្សា ព្រមទាំងទទួលបានគុណភាពនៃការអប់រំ
- បន្តបណ្តុះគំនិតក្នុងការរក្សាប្រពៃណីជាតិដែលជាកេរ្តិ៍តំណែលរបស់ខ្មែរយើង។

**៣.២.២. កត្តាហិរញ្ញវត្ថុ**

- រៀបចំផែនការចំណាយហិរញ្ញវត្ថុឲ្យត្រូវ និងស្របទៅតាមលើគោលដៅ ក្នុងការអភិវឌ្ឍន៍
- ស្វែងរកទីប្រឹក្សាខាងគណនេយ្យ ឲ្យបានត្រឹមត្រូវដែលបានបង្ហាញផ្លូវនៃការចំណាយដែលផ្តល់មកវិញនៃផ្លែផ្កា ក្នុងការវិវត្តគោលនយោបាយការបរទេស

**៣.២.៣. ពង្រីក និងពង្រឹងវិសាលភាពការទូតទ្វេភាគី និងពហុភាគី**

- កម្ពុជាគួរតែព្យាយាមបន្តចូលរួមយ៉ាងសកម្មនៅក្នុងឆាកអន្តរជាតិ បន្ថែមទៀតដើម្បីបង្ហាញពីសក្តានុពលដែលជាការបង្ហាញឲ្យឃើញថា កម្ពុជាអាចជាដៃគូរសហប្រតិបត្តិការមួយយ៉ាងល្អប្រសើរសម្រាប់ដំណើរការការបរទេស ។
- ស្វែងរក និងបង្កើតការទំនាក់ទំនងការទូតបន្ថែមទៀតជាមួយ ប្រទេសដែលមិនទាន់ជាដៃគូរសហការ ក្នុងគោលបំណងស្វែងរក ការអភិវឌ្ឍន៍ថ្មីៗ ពីចំណងការទូត។
- បង្កើតបន្ថែមទៀតនូវ ស្ថានទូតទៅតាមបណ្តា ប្រទេសដែលមានមិនទាន់ មានស្ថានទូតក្នុងគោលដៅរក្សា និងពង្រឹងទំនាក់ទំនងរវាងប្រទេសកម្ពុជាជាមួយប្រទេសដ៏ទៃ ហើយអាចការពារនៅ ពលរដ្ឋរបស់កម្ពុជាដែលស្នាក់នៅក្នុង ប្រទេសទាំងនោះផងដែរ។ ជាក់ស្តែង សព្វថ្ងៃកម្ពុជាមានស្ថានទូតចំនួន ២៧ ស្ថានតំណាងអចិន្ត្រៃយ៍កម្ពុជាប្រចាំអង្គការអន្តរជាតិចំនួន ០៤ និងអគ្គកុងស៊ុលចំនួន ១១ ។
- ពិចារណាយកមន្ត្រី និងអ្នកជំនាញដែលមានជំនាញច្បាស់លាស់ ក្នុងការចូលរួមជាមួយប្រទេសដ៏ទៃនិងឆាកអន្តរជាតិ
- កម្ពុជាគួរគប្បី មានការផ្លាស់ប្តូរចំណេះដឹងជាមួយប្រទេសដ៏ទៃឲ្យបានច្រើនដើម្បីយកចំណេះទាំងនោះមកដោះស្រាយបញ្ហាដែលកំពុងតែជួបប្រទះក្នុងការអភិវឌ្ឍន៍វិស័យការបរទេស។

### ៣.២.៤. ពង្រឹងអនុភាពនៃការអនុវត្តច្បាប់ជាតិ

ថ្វីត្បិតតែច្បាប់ខាងក្រោម ពុំមែនជាច្បាប់ពាក់ព័ន្ធកលារទូត ឬគោលនយោបាយ ប៉ុន្តែច្បាប់នេះអាចជាចំណុចបន្ថែមក្នុងការធ្វើអោយប្រទេសកម្ពុជាកាន់តែមានកេរ្តិ៍ឈ្មោះល្អនៅក្នុងឆាកការទូតអន្តរជាតិ។

- ត្រូវតែមានការរឹតបន្តឹង បន្ថែមទៀតនូវចំនុចខ្វះខាត ក្នុងពេលអនុវត្តច្បាប់ ជាក់ស្តែងត្រូវតែមានការពិន័យទៅលើជនដែលបានប្រព្រឹត្តការល្មើសច្បាប់ដដែលៗ ដែលជាហេតុធ្វើអោយមានការមើលឃើញពីភាពអសន្តិសុខពីអន្តរជាតិ
- គប្បីមានការចុះផ្សព្វផ្សាយ នូវចំណេះដឹងអំពីផ្នែកច្បាប់ដល់ ពលរដ្ឋជាពិសេសយុវជនដែលជាទំពាំងស្នងឬស្សីក្នុងការកសាង ប្រទេសជាតិកុំឲ្យមានការប្រព្រឹត្ត ខុសនូវអំពើដែលប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ប្រទេសដែលជាការបង្ហាញដល់អន្តរជាតិ
- មន្ត្រីប៉ូលីសគួរតែទទួលបាននូវកម្មវិធីបណ្តុះបណ្តាលយ៉ាងម៉ត់ចត់ ដែលបង្រៀនវិធីសាស្ត្រ និងជំនាញទំនើបដើម្បីជួយប្រយុទ្ធប្រឆាំង ឧក្រិដ្ឋកម្ម និងបញ្ហាល្មើសច្បាប់ដោយប្រើប្រាស់ជំនាញនោះប្រកបដោយប្រសិទ្ធិភាព
- បច្ចុប្បន្នគួរតែធ្វើការរឹតបណ្តឹងនៅការគោរព ច្បាប់ចរាចរណ៍ នៅកម្ពុជាដើម្បីការពារដល់អាយុ ជីវិតប្រជាពលរដ្ឋ និងជនបរទេសដែលបានមកធ្វើការ ឬដំណើរកំសាន្តនៅកម្ពុជាអោយកាន់ តែមាន លក្ខណៈល្អប្រសើរកាន់តែខ្លាំង
- ព្យាយាមលុប កាត់បន្ថយនូវការរំលោភបំពានសិទ្ធិ និងអំពើរពុករលួយ អាចធ្វើឲ្យអន្តរជាតិមើលឃើញពីគុណសម្បត្តិរបស់ប្រទេស។

# សេចក្តីសន្និដ្ឋាន

សរុបមកវិញ យើងបានឃើញហើយថាថ្វីត្បិតតែកម្ពុជាជាប្រទេសដែលនិងកំពុងអភិវឌ្ឍន៍ក្តី ទោះមើលឃើញនៅមានបញ្ហាមួយចំនួនកើតឡើងក៏ពិតមែន ក៏យើងនៅសង្កេតឃើញនៅការរីកចម្រើន ស្ទើតែគ្រប់វិស័យទាំងអស់ ជាពិសេសវិស័យការទូត។ ម្យ៉ាងទៀត យើងឃើញថា គោលនយោបាយការបរទេសរបស់កម្ពុជា ត្រូវបានគេមើលឃើញនូវភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ បន្ទាប់ពីឆ្នាំ១៩៩៣ នៅពេលដែលប្រទេសនេះបានរៀបចំការបោះឆ្នោតជាតិ ដែលរៀបចំដោយអង្គការសហប្រជាជាតិ។ កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក បាននាំឱ្យកម្ពុជាចូលជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍នៅឆ្នាំ១៩៩៩ និងអង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅឆ្នាំ២០០៤។ ព្រះរាជាណាចក្រកម្ពុជាមានទំនាក់ទំនងល្អជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតនៅអាស៊ីអាគ្នេយ៍ និងលើសពីនេះទៀត ។

រាជរដ្ឋាភិបាលកម្ពុជាពិតជាបាន ខិតខំស្វាត់ស្វែងក្នុងការផ្តល់ជាដំណោះស្រាយដល់បញ្ហាដែល កម្ពុជាកំពុងប្រឈមចំពោះមុខយ៉ាងពិតប្រាកដមែន ទោះបីជាមិនបានទាំងស្រុងនាពេលបច្ចុប្បន្នតែ កម្ពុជាក៏បានបន្តស្វែងរកដំណោះស្រាយផ្សេងៗទៀតសម្រាប់ដោះស្រាយ និងការពារនាពេល អនាគតផងដែរ។ ស្ថិតនៅចំពោះមុខការវិវឌ្ឍផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃភូមិសាស្ត្រនយោបាយ នៅក្នុង តំបន់និងពិភពលោកដោយផ្អែកលើគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល កម្ពុជាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានខិតខំយ៉ាងប្តូរផ្តាច់ ក្នុងការបំពេញភារកិច្ច ដ៏ឱត្តុងឱត្តមដែលរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាប្រគល់ឲ្យក្នុងការការពារផលប្រយោជន៍ ប្រទេសជាតិ លើឆាកអន្តរជាតិតាមរយៈការធ្វើសមាហរណកម្មកម្ពុជាក្នុងសហាគមន៍អន្តរជាតិការ ពង្រឹងពង្រីកចំនងមិត្តភាពនិងកិច្ចសហប្រតិបត្តិការដ៏ល្អប្រសើរជាមួយប្រទេសជិតខាង និងបណ្តាល ប្រទេសទាំងអស់ក្នុងពិភពលោក រួមចំនែកកាពារឯករាជ្យជាតិអធិបតិយ្យភាព និងបូរណភាពដែនដី និងការអភិវឌ្ឍន៍។ ១១ខែកន្លងផុត ក្រោមការចង្អុលបង្ហាញប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ការបន្សល់ ទុកនូវស្នាដៃដ៏ថ្លៃថ្លារបស់ឯកឧត្តមទេសរដ្ឋមន្ត្រី **ហោ ណាំហុង** ក្នុងការបំពេញបេសកកម្មការ ទូតដ៏ឱត្តុងឱត្តម និងក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ ឯកឧិត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** ថ្នាក់ដឹកនាំ

មន្ត្រីបុគ្គលិកគ្រប់ស្រទាប់ជាន់ថ្នាក់នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិបាន ពង្រឹងផែន ការសាមគ្គីភាពរួមគ្នា ធ្វើអោយបានសម្រេចនូវសមិទ្ធិផលដ៏ច្រើនជាទីមោទនសម្រាប់ប្រទេសជាតិ និង មាតុភូមិ ទាំងនៅក្នុងកិច្ចការផ្ទៃក្នុងរបស់ក្រសួង ទាំងការងារការទូតទូទៅនៅលើឆាកអន្តរជាតិ។ នៅក្នុងផ្ទៃក្នុងក្រសួងកំណែទម្រង់ស៊ីជម្រៅត្រូវបាន អោយដាក់អនុវត្តសមស្រមតាមអនុសាសន៍ដ៏មានសារៈសំខាន់របស់ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីតាមពាក្យស្លោក( ងូតទឹកឆ្លុះកញ្ចក់ ដុះក្អែល)សំដៅអភិវឌ្ឍន៍ធនធានមនុស្សជំរុញនិងបង្កើនប្រសិទ្ធភាពការងារ ទំនើបកម្មនិងកែលម្អសេវាសារធារណៈ និងធ្វើអោយជីវភាពមន្ត្រីរាជការកាន់តែប្រសើរឡើង។ ដោយឡែកការងារបំពេញ ភារកិច្ចទំនាក់ទំនងការទូតនិងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីសម្រេចបានលទ្ធិផលគួរឲ្យកត់សម្គាល់។

# ឯកសារយោង

# ឯកសារយោង

- **ប្រភពនាំចូលសំខាន់ៗ**: ថៃ វៀតណាម ចិន និង សិង្ហបុរី។
- **ទាក់ទងនឹងទំនាក់ទំនងអន្តរជាតិ**
- ប្រមុខរដ្ឋ
- រដ្ឋាភិបាលជាតិ
- អង្គនីតិប្រតិបត្តិ
- បច្ចុប្បន្នភាពចុងក្រោយ ២ វិច្ឆិកា ២០១៦


- ម៉ៃ គុណមករា. "ការជម្រុញបន្ថែមពាណិជ្ជកម្មកម្ពុជា-ថៃ ត្រូវការចាំបាច់." ខ្មែរថាម. ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥។ ចូលអាននៅថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៥។
- សាំង សុគន្ធរិទ្ធ. "ជនចំណាកស្រុកជាង ៥,០០០នាក់ត្រូវបានចាប់បញ្ជូនដោយថៃ នៅឆ្នាំ២០១៥." ឌឹ ខេមបូឌា ដេលី ថ្ងៃទី ៧ ខែធ្នូ ឆ្នាំ២០១៥។ ចូលអាននៅថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៥។ https://www.cambodiadaily.com/news/more-than-50000-migrants-deported-by-thailand-in-2015-102223/
- ប៉ាវ ស៊ុយ និង វែន រដ្ឋាវង្ស. "នាយករដ្ឋមន្ត្រីហាមការជួលដីនៅតាមបណ្តោយព្រំដែន". ខ្មែរថាម. ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១៥។ ចូលអាននៅថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៥។ http://www.khmertimeskh.com/news/17838/pm-bans-land-leasing-along-border/
- ឈឿងបូរាណ ចាន់បូរី. "ការតម្រង់យុទ្ធសាស្ត្រត្រឹមត្រូវរបស់កម្ពុជាជាមួយចិន." ឌឹ ឌីផ្លូមម៉ាត. ថ្ងៃទី ៨ ខែកក្កដា ឆ្នាំ២០១៥។ ចូលអាននៅថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៥។
- ថូមម៉ាស ឡាំ. ប្រទេសកម្ពុជា៖ សវតារ និងទំនាក់ទំនងសហរដ្ឋអាមេរិក ដោយសង្ខេប. ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥. សេវាស្រាវជ្រាវសភា។ ចូលអាននៅថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៥។ https://www.fas.org/sgp/crs/row/R44037.pdf
- បុគ្គលិកសារព័ត៌មាន ឌឹ ខេមបូឌា "នាយករដ្ឋមន្ត្រីលើកឡើងជាថ្មីអំពីគោលនយោបាយ'ចិនតែមួយ'." ឌឹ ខេមបូឌា ដេលី ថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០០០។ ចូលអាននៅថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៥។ https://www.cambodiadaily.com/archives/prime-minister-reiterates-one-china-policy-15932/
- ឯក មាត្រា. "រុស្ស៊ីត្រឡប់មករកកម្ពុជាវិញ." ខ្មែរថាម. ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥។ ចូលអាននៅថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១៥។ http://www.khmertimeskh.com/news/18216/russia-comes-back-to-cambodia/

- វ៉ា វាសនា. "កម្ពុជា៖ រវាងចិន និងសហរដ្ឋអាមេរិក." ឌី ឌីផ្លូមម៉ាត. ថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១៥។ ចូលអាននៅថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៥។ http://thediplomat.com/2015/05/cambodia-between-china-and-the-united-states/
- ស៊ុំ ម៉ាណោត, "ប្រទេសចិនផ្តល់ ២ ពាន់លានដុល្លារសម្រាប់ផ្លូវថ្នល់ និងស្ពាន". កាសែតខ្មែរថាមស៍, ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៦។
- ក្រសួងការបរទេសសហរដ្ឋអាមេរិក. "ទំនាក់ទំនងសហរដ្ឋអាមេរិក ជាមួយកម្ពុជា." ថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៥។ ចូលអាននៅថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៥។ https://www.state.gov/u-s-relations-with-cambodia/
- វីលៀម ថត. ទំនាក់ទំនងសហរដ្ឋអាមេរិក-កម្ពុជា៖ កិច្ចការកំពុងបន្ត. ព្រឹត្តិប័ត្ររបស់ឯកអគ្គរដ្ឋទូត. និទាឃរដូវឆ្នាំ២០១៣។
- ស៊ីម៉ន ហេនឌីសិន. "ជប៉ុនផ្តល់២៣៦លានដុល្លារអាមេរិកជាជំនួយអភិវឌ្ឍន៍និងកម្ចី." ឌី ខេមបូឌា ដេលី ថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០១៥។ ចូលអាននៅថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១៥។
- ស្ថានទូតជប៉ុនប្រចាំនៅកម្ពុជា. "ជំនួយអភិវឌ្ឍន៍ផ្លូវការ." ចូលអាននៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០១៥។ http://www.kh.emb-japan.go.jp/economic/economic-e.htm
- ស៊ីម៉ន ហេនឌីសិន ឆ្នាំ២០១៥។
- ឈាង វណ្ណារិទ្ធ. កម្ពុជា៖ រវាងចិន និងជប៉ុន. វិទ្យាស្ថានកម្ពុជាដើម្បីកិច្ចសហប្រតិបត្តិការនិងសន្តិភាព. ឯកសារលេខ៣១. រាជធានីភ្នំពេញ. ខែ តុលា ឆ្នាំ២០០៩។ http://bit.ly/1U6Bjft
- សេចក្តីសម្រេចលេខ ១៣សសរ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួល កិច្ចការបញ្ជូនកម្លាំងចូលរួមបេសកកម្មរក្សាសន្តិសុខ របស់អង្គការសហប្រជាជាតិ
- សេចក្តីសម្រេចលេខ ១២សសរ ស្តីពីការបង្កើតគណៈកម្មាធិកាជាតិកែទម្រង់គ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវ
- មាត្រា៥៣នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ប្រការ៣នៃសេចក្តីសម្រេចលេខ ១៣សសរ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួល កិច្ចការបញ្ជូនកម្លាំងចូលរួមបេសកកម្មរក្សាសន្តិសុខ របស់អង្គការសហប្រជាជាតិ
- ធម្មនុញ្ញអាស៊ាន ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០០៨
- អនុសញ្ញា ក្រុងវៀន ស្តីពី ទំនាក់ទំនងការទូត (Vienna Convention on Diplomatic Relations 1961)

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីយើងខ្ញុំបានបកស្រាយនូវប្រធានបទខាងលើរួចមកហើយ យើងអាចសន្និដ្ឋានបានថាខ្លឹមសារទាំងឡាយដែលមានចែងក្នុងសារណានេះ គឺមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការយកមកអនុវត្តជាក់ស្តែង ក្នុងព្រះរាជាណាចក្រកម្ពុជានាពេលនេះ ប៉ុន្តែបើយើងក្រលេកមើលអនាគតវិញ សង្គមនឹងមានការផ្លាស់ប្តូរបរិបទយ៉ាងច្រើនតទៅមុខទៀត ធ្វើកាជាហេតុដែលតម្រូវអោយមានឲ្យមានការកែតម្រូវច្បាប់ និងស្ថានភាពនានាឲ្យមានភាពសមស្របនិងការវិវឌ្ឍរបស់សង្គម។

ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវ យើងខ្ញុំសូមចូលរួមជាយោបល់ និងអនុសាន៍មួយចំនួនដូចខាងក្រោមដើម្បីចូលរួមជាចំណែកមួយ ក្នុងការធ្វើឲ្យប្រសើរឡើងនូវកត្តាមួយចំនួនមានការរីកចម្រើន នៃប្រទេសកម្ពុជា។ យើងខ្ញុំ សូមឲ្យស្ថាប័នផ្សេងៗដែលទាក់ទងនិងទៅនិងកត្តាច្បាប់ជាពិសេស ការអនុវត្តនូវគោលនយោបាយការទូត ពិនិត្យ និងអនុម័តនូវច្បាប់ ដើម្បីឲ្យតាមទាន់នូវការវិវឌ្ឍប្រែប្រួលសង្គម។ ជាពិសេសទៅទៀតគឺ យើងសូមធ្វើការអំពាវនាវដល់អាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ រួមទាំងរាជរដ្ឋាភិបាលធ្វើការផ្សព្វផ្សាយនូវ កត្តាច្បាប់ផ្សេងៗជាពិសេសទាក់ទង និងគោលនយោបាយការទូត និងច្បាប់ការទូតដើម្បីអោយប្រជាពលរដ្ឋមានការជ្រួតជ្រាបនិងយល់ដឹងក្នុងន័យចូលរួមកាត់បន្ថយ និងលុបបំបាត់ចោលនូវបញ្ហាផ្សេងៗនៅក្នុងសង្គមគ្រួសាររួមទាំងសង្គមជាតិ ដោយហេតុថាសង្គមដែលមានការអភិវឌ្ឍគឺ អាស្រ័យលើចំណេះដឹង និងការអនុវត្តរបស់ប្រជាជន។ម្យ៉ាងវិញទៀតប្រជាពលរដ្ឋទៀតសោតក៏ត្រូវស្វែងយល់នូវពត៌មានផ្សេងៗទាក់ទងនឹងបញ្ញត្តិច្បាប់និងដំណោះស្រាយលើបញ្ហាប្រឈមផ្សេងៗដើម្បីជាការយល់ដឹង។

ត្បិតតែអនុសាន៍ខាងលើមានភាពមិនគ្រប់គ្រាន់ និងស៊ីជម្រៅក៏ដោយ ក៏វាអាចជាកត្តាមួយជួយជម្រុញដល់ ការចូលរួមកាត់បន្ថយនូវវិវាទផ្សេងៗ ក៏ដូចជាបញ្ហាប្រឈម ដែលទាក់ទងទៅនិងបញ្ហាទំនាស់ផ្សេងៗ រួមទាំងធ្វើឲ្យមានភាពសុខសាន្ត និងសុខដុមរមនានៅក្នុងសង្គមគ្រួសារនិងសង្គមជាតិផងដែរ។

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៣៥៤ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០២/០០១ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីក្រមការការបរទេស

- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីការចាត់តាំង និងការប្រព្រឹត្តទៅនៃប្រព័ន្ធសម្របសម្រួលផ្ទៃក្នុង
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតអង្គភាពជាតិសម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន
- បានឃើញអនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតលេខាធិការដ្ឋានជាតិអាស៊ាន-កម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលបំណងដូចខាងក្រោម៖

- កំណត់បេសកកម្ម និងរៀបចំរចនាសម្ព័ន្ធរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- កំណត់មុខងារ និងភារកិច្ចរបស់អង្គភាពនានានៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- ធានាគុណភាព និងប្រសិទ្ធភាពនៃលទ្ធផលការងារក្នុងវិស័យការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់អង្គភាពនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនិងស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ដោយគ្របដណ្តប់លើវិស័យការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

## ជំពូកទី២
## បេសកកម្មនិងរចនាសម្ព័ន្ធ

**មាត្រា ៤.-**

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើការដឹកនាំ និងគ្រប់គ្រងវិស័យការបរទេសនិងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៥.-**

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដូចតទៅ៖

- ការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី សេចក្តីថ្លៃថ្នូរ និងកិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជា
- រៀបចំ អនុវត្ត តាមដានការអនុវត្ត និងការពារគោលនយោបាយនិងផែនការយុទ្ធសាស្ត្រការបរទេសរបស់រាជរដ្ឋាភិបាលកម្ពុជា
- រៀបចំ អនុវត្ត និងតាមដានការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ឬលិខិតូបករណ៍អន្តរជាតិក្នុងន័យជានានិងការពារផលប្រយោជន៍របស់រាជរដ្ឋាភិបាលក្នុងកិច្ចការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- ជាច្រកចេញចូលការទូតតែមួយក្នុងទំនាក់ទំនងជាមួយប្រទេសនិងអង្គការតំបន់ និងស្ថាប័នអន្តរជាតិនានាលើរាល់សកម្មភាពរបស់ក្រសួងស្ថាប័ននានាដែលមានទំនាក់ទំនងជាមួយបរទេស
- តំណាងរាជរដ្ឋាភិបាលកម្ពុជាក្នុងការចរចា និងធ្វើកិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគីជាមួយបណ្តាប្រទេស អង្គការតំបន់ និងស្ថាប័នអន្តរជាតិនានា
- ពង្រឹងនិងពង្រីកទំនាក់ទំនង រវាងព្រះរាជាណាចក្រកម្ពុជា ជាមួយប្រទេស អង្គការតំបន់ និងអង្គការអន្តរជាតិនានា តាមរយៈកិច្ចការការទូត កុងស៊ុល និងសហប្រតិបត្តិការអន្តរជាតិ
- ពង្រឹងវិស័យការទូតសេដ្ឋកិច្ចតាមរយៈការចូលរួមជំរុញវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ធុរកិច្ច ទេសចរណ៍ ការងារ អប់រំ និងបច្ចេកវិទ្យា
- ផ្សព្វផ្សាយនិងលើកតម្កើងភាសា វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ខ្មែរនៅក្រៅប្រទេស
- ចូលរួមការពារនិងរក្សាសន្តិភាព ស្ថិរភាព សន្តិសុខ នៅថ្នាក់អនុតំបន់ តំបន់ និងពិភពលោក
- ចូលរួម និងទទួលរៀបចំកិច្ចប្រជុំថ្នាក់អនុតំបន់ តំបន់ និងពិភពលោកពាក់ព័ន្ធនឹងកិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬតាមការចាត់តាំងរបស់រាជរដ្ឋាភិបាល
- តំណាងនិងការពារផលប្រយោជន៍ជាតិនិងប្រជាពលរដ្ឋខ្មែរទាំងរូបវន្តបុគ្គលនិងនីតិបុគ្គល ព្រមទាំងលើកកម្ពស់ និងការពារកិត្តិយសជាតិ ស្របតាមច្បាប់ជាតិ និងអន្តរជាតិ
- ដឹកនាំគ្រប់គ្រងស្ថានតំណាងរបស់ព្រះរាជាណាចក្រកម្ពុជាដែលតាំងនៅបរទេស

- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការចុះបញ្ជី និងសហការសម្របសម្រួលការធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់ស្ថានតំណាងបរទេស ស្ថានតំណាងស្ថាប័នអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលបរទេស ដោយយោងតាមច្បាប់ជាតិនិងអន្តរជាតិ
- សម្របសម្រួលនិងរៀបចំទស្សនកិច្ចរបស់គណៈប្រតិភូរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទៅបរទេស និងទទួលគណៈប្រតិភូបរទេសដែលមកបំពេញបេសកកម្មឬទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា
- បណ្តុះបណ្តាលនិងធ្វើក្រឹតការជាប្រចាំនូវមុខជំនាញកិច្ចការបរទេស និងការទូត
- តាមដាន ស្វែងយល់ និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលអំពីការវិវត្តនៃព្រឹត្តិការណ៍តំបន់ និងអន្តរជាតិសំខាន់ៗ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការចាត់តាំងរបស់រាជរដ្ឋាភិបាលកម្ពុជា។

**មាត្រា ៦.-**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានរចនាសម្ព័ន្ធដូចខាងក្រោម៖

ក- អង្គភាពរដ្ឋបាលកណ្តាល

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាន
- អគ្គនាយកដ្ឋានអាស៊ាន
- អគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន
- អគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក
- អគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា
- អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
- អគ្គាធិការដ្ឋាន
- វិទ្យាស្ថានជាតិទំនាក់ទំនងការទូត និងសិក្សាអន្តរជាតិ
- នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- នាយកដ្ឋានគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

ខ-ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស

- ស្ថានឯកអគ្គរាជទូតនិងស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រចាំអង្គការតំបន់ និងអង្គការអន្តរជាតិ
- ស្ថានអគ្គកុងស៊ុលនិងស្ថានកុងស៊ុល
- ស្ថានកុងស៊ុលកិត្តិយស។

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់។

អគ្គនាយកដ្ឋានដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនតាមការចាំបាច់។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូប និងអមដោយអគ្គាធិការរងមួយចំនួនតាមការចាំបាច់។

វិទ្យាស្ថាន ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយអនុប្រធានមួយចំនួនមានឋានៈស្មើអគ្គនាយករង តាមការចាំបាច់។

នាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនតាមការចាំបាច់។

អង្គការលេខរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៨.-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន វិទ្យាស្ថានជាតិនិងស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេសត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

## ជំពូកទី៣
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា ៩.-**

ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន។

## ជំពូកទី៤
## អគ្គលេខាធិការដ្ឋាន

**មាត្រា ១០.-**

អគ្គលេខាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិលើបេសកកម្មគ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង និងសម្របសម្រួលការងារពាក់ព័ន្ធពិធីការរដ្ឋ។

**មាត្រា ១១.-**

អគ្គលេខាធិការដ្ឋានមានភារកិច្ចដូចតទៅ៖

- គ្រប់គ្រង និងត្រួតពិនិត្យការចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង
- សម្របសម្រួលរាល់សកម្មភាពរដ្ឋបាលនៅគ្រប់ថ្នាក់ និងគ្រប់ផ្នែកនៅក្រោមសមត្ថកិច្ចរបស់ក្រសួង និងរបស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- សម្របសម្រួលរាល់សកម្មភាពរដ្ឋបាលជាមួយបណ្តាក្រសួង ស្ថាប័ន និងស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- គ្រប់គ្រង និងត្រួតពិនិត្យការងារផែនការហិរញ្ញវត្ថុ សម្ភារៈបរិក្ខារ និងបញ្ជីសារពើភណ្ឌ
- ពិនិត្យ និងសម្របសម្រួលរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង និងបូកសរុបរបាយការណ៍ហិរញ្ញវត្ថុនិងសកម្មភាពការងាររបស់ក្រសួង
- គ្រប់គ្រងមន្ត្រីរាជការនិងបុគ្គលិករបស់ក្រសួង
- សិក្សានិងវាយតម្លៃតម្រូវការសម្រាប់ការកសាងសមត្ថភាពធនធានមនុស្សនិងការបង្កើនគុណភាពវិជ្ជាជីវៈផ្នែកការបរទេសនិងសហប្រតិបត្តិការអន្តរជាតិដោយសហការជាមួយវិទ្យាស្ថានជាតិទំនាក់ទំនងការទូតនិងសិក្សាអន្តរជាតិ
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលនៅក្រោមសមត្ថកិច្ចរបស់ក្រសួង
- អនុវត្តគោលការណ៍ស្តីពីពិធីការការទូតតាមវិធាននិងទំនៀមទម្លាប់របស់ព្រះរាជាណាចក្រកម្ពុជា និងតាមវិធីនិងទម្លាប់អន្តរជាតិ
- សម្របសម្រួលនិងសហការរៀបចំកម្មវិធីទស្សនកិច្ចរបស់ ថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ និងដំណើរបំពេញទស្សនកិច្ចរបស់គណប្រតិភូថ្នាក់ដឹកនាំជាន់ខ្ពស់បរទេសនៅព្រះរាជាណាចក្រកម្ពុជា
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង
- អនុវត្តភារកិច្ចផ្សេងៗដែលក្រសួងប្រគល់ឱ្យ។

**មាត្រា ១២.-**

អគ្គលេខាធិការដ្ឋានមាននាយកដ្ឋានចំណុះចំនួន ០៤(បួន) ជាសេនាធិការ៖

- នាយកដ្ឋានរដ្ឋបាល : មានមុខងារសម្របសម្រួលការងារទូទៅរបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាលជាមួយស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- នាយកដ្ឋានហិរញ្ញវត្ថុ-គណនេយ្យ : មានមុខងារសម្របសម្រួលការងារហិរញ្ញវត្ថុ និងគណនេយ្យ
- នាយកដ្ឋានបុគ្គលិក : មានមុខងារសម្របសម្រួលការងារគ្រប់គ្រងបុគ្គលិក មន្ត្រីរាជការ និងការងារបណ្តុះបណ្តាល
- នាយកដ្ឋានពិធីការ : មានមុខងារសម្របសម្រួលការងារពិធីការ។

## ជំពូកទី៥
## អគ្គនាយកដ្ឋានអាស៊ាន

**មាត្រា ១៣.-**

អគ្គនាយកដ្ឋានអាស៊ាន បំពេញមុខងារជាសេនាធិការឲ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាសេនាធិការឲ្យលេខាធិការដ្ឋានជាតិអាស៊ាន-កម្ពុជា ដោយធ្វើការងារសម្របសម្រួលថ្នាក់ជាតិ និងថ្នាក់តំបន់ លើបេសកកម្មពាក់ព័ន្ធនឹងកិច្ចការអាស៊ាន ។

**មាត្រា ១៤.-**

អគ្គនាយកដ្ឋានអាស៊ានមានភារកិច្ច ដូចតទៅ៖

- សម្របសម្រួលរាល់កិច្ចការពាក់ព័ន្ធនឹងអាស៊ាន និងការអនុវត្តនូវកាតព្វកិច្ចនានា ដែលមានចែងនៅក្នុងធម្មនុញ្ញអាស៊ាន និងសេចក្តីសម្រេចនានារបស់អាស៊ាន នៅថ្នាក់ជាតិជាមួយនឹងក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា
- សម្របសម្រួលរាល់កិច្ចការអាស៊ានក្នុងកម្រិតតំបន់និងធ្វើទំនាក់ទំនងជាអន្តរជាតិជាមួយលេខាធិការដ្ឋានជាតិអាស៊ាន នៃបណ្តាប្រទេសសមាជិកអាស៊ាន លេខាធិការដ្ឋានអាស៊ាន ប្រទេសក្រៅតំបន់អាស៊ាន អង្គការតំបន់និងអន្តរជាតិជាដៃគូ និងអង្គភាពនានារបស់អាស៊ាន ក្នុងឋានៈជាសេនាធិការឲ្យលេខាធិការដ្ឋានជាតិអាស៊ាន-កម្ពុជា
- តាមដាន ត្រួតពិនិត្យ វាយតម្លៃនិងលើកយោបល់លើបញ្ហាពាក់ព័ន្ធនឹងមុខងារ និងដំណើរការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានអាស៊ាន និងគ្រឹះស្ថានអាស៊ាន
- សម្របសម្រួលជាមួយក្រសួង-ស្ថាប័ននានាលើការរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំកំពូលពាក់ព័ន្ធ កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាននិងកិច្ចប្រជុំអាស៊ានពាក់ព័ន្ធដទៃទៀត
- សិក្សា ស្រាវជ្រាវ និងតាមដានការវិវឌ្ឍនៃបញ្ហាសំខាន់ៗ ជាពិសេសផ្នែកនយោបាយ-សន្តិសុខ ព្រមទាំងរៀបចំជំនួយស្មារតី និងឯកសារទស្សនទានជូនថ្នាក់ដឹកនាំ ស្តីពីគោលជំហររបស់កម្ពុជាលើកិច្ចការសហគមន៍នយោបាយ-សន្តិសុខអាស៊ាន និងទំនាក់ទំនងខាងក្រៅរបស់អាស៊ានជាមួយប្រទេសជាដៃគូសន្ទនាទាំងអស់ និងអង្គការតំបន់នានា
- ផ្តួចផ្តើមគំនិត និងផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងការកសាងសហគមន៍អាស៊ាន ការកសាងសហគមន៍អាស៊ីបូព៌ា និងវឌ្ឍនភាពនៃនិម្មាបនកម្មតំបន់
- ចូលរួមកិច្ចប្រជុំអាស៊ាន និងសិក្សា តាមដាន និងផ្តល់យោបល់លើឯកសារពាក់ព័ន្ធក្នុងក្របខ័ណ្ឌអាស៊ាន និងឯកសារពាក់ព័ន្ធដទៃទៀតរវាងអាស៊ានជាមួយនឹងអង្គការតំបន់ និងអន្តរជាតិ

- ធ្វើការកៀរគរជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីសហគមន៍អាស៊ាន បណ្តាប្រទេសសមាជិកអាស៊ាន និងប្រទេសដៃគូរបស់អាស៊ាន ព្រមទាំងជួយជំរុញការវិនិយោគទុនផ្ទាល់បរទេស និងអ្នកទេសចរណ៍មកកម្ពុជា ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍព្រះរាជាណាចក្រកម្ពុជា
- តាមដានការប្រើប្រាស់មូលនិធិរបស់អាស៊ាន និងមូលនិធិនៃកិច្ចសហប្រតិបត្តិការរវាងអាស៊ាននិងប្រទេសដៃគូសន្ទនា ព្រមទាំងធ្វើការសម្របសម្រួល និងជួយដល់ក្រសួង-ស្ថាប័ននានា ក្នុងការរៀបចំ និងអនុវត្តគម្រោងសកម្មភាពនានាក្នុងក្របខ័ណ្ឌអាស៊ាន
- រៀបចំផែនការការងារប្រចាំឆ្នាំ ធ្វើរបាយការណ៍ស្តីពីសកម្មភាពអាស៊ាន និងរៀបចំថវិកាប្រចាំឆ្នាំសម្រាប់ដំណើរការរបស់អគ្គនាយកដ្ឋាន រួមទាំងសម្រាប់ការរៀបចំនិងការចូលរួមកិច្ចប្រជុំអាស៊ាននានា និងសកម្មភាពដទៃទៀត ដូចជា ការបណ្តុះបណ្តាល ការស្រាវជ្រាវ និងការផ្សព្វផ្សាយការយល់ដឹងអំពីសហគមន៍អាស៊ាន
- តំកល់ព័ត៌មាន របាយការណ៍ និងឯកសារពាក់ព័ន្ធនឹងអាស៊ាន
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ឲ្យ និងតាមការសម្រេចរបស់កិច្ចប្រជុំលេខាធិការដ្ឋានជាតិអាស៊ាន-កម្ពុជា។

**មាត្រា ១៥.-**

អគ្គនាយកដ្ឋានអាស៊ាន មាននាយកដ្ឋានចំណុះចំនួន ០៥ (ប្រាំ) ជាសេនាធិការៈ

- នាយកដ្ឋានកិច្ចការទូទៅ និងសហគមន៍: មានមុខងារសម្របសម្រួលការងាររដ្ឋបាលទូទៅ ថវិកា និងកិច្ចការសហគមន៍
- នាយកដ្ឋានកិច្ចការសហគមន៍នយោបាយ-សន្តិសុខអាស៊ាន: មានមុខងារសម្របសម្រួលការងារសហគមន៍នយោបាយ-សន្តិសុខអាស៊ាន
- នាយកដ្ឋានកិច្ចការសហគមន៍សេដ្ឋកិច្ចអាស៊ាន និងសង្គម-វប្បធម៌អាស៊ាន: មានមុខងារសម្របសម្រួលការងារសហគមន៍សេដ្ឋកិច្ច អាស៊ាន និងសហគមន៍សង្គម-វប្បធម៌អាស៊ាន
- នាយកដ្ឋានទំនាក់ទំនងដៃគូសន្ទនាអាស៊ាន: មានមុខងារសម្របសម្រួលការងារទំនាក់ទំនងរវាងអាស៊ាន និងប្រទេសជាដៃគូសន្ទនារបស់អាស៊ាន
- នាយកដ្ឋានទំនាក់ទំនងអាស៊ានបូកបី និងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា: មានមុខងារសម្របសម្រួលទំនាក់ទំនងរវាងអាស៊ានជាមួយប្រទេសបូកបី (ចិន-ជប៉ុន-សាធារណរដ្ឋកូរ៉េ) និងការងារកិច្ចប្រជុំកំពូលអាស៊ីបូព៌ា។

# ជំពូកទី៦
# អគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន

**មាត្រា១៦**.-

អគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន បំពេញមុខងារជាសេនាធិការឲ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិក្នុងបេសកកម្មពាក់ព័ន្ធនឹងកិច្ចការច្បាប់ កិច្ចការកុងស៊ុល និងកិច្ចការព្រំដែន។

**មាត្រា១៧**.-

អគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការយុទ្ធសាស្ត្រនិងថវិកាសម្រាប់កិច្ចការច្បាប់ សន្ធិសញ្ញា កិច្ចការកុងស៊ុល និងកិច្ចការព្រំដែន
- លើកគម្រោងកសាងគោលនយោបាយច្បាប់ និងលិខិតបទដ្ឋានសម្រាប់បម្រើឲ្យវិស័យការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ចូលរួមរៀបចំពិភាក្សានិងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលត្រូវបានរៀបចំដោយរាជរដ្ឋាភិបាល
- សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់លើក្របខណ្ឌច្បាប់ជាតិ និងអន្តរជាតិចំពោះសន្ធិសញ្ញា កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគីនិងការចូលជាភាគីនៃសន្ធិសញ្ញាអន្តរជាតិនានា
- ការពារផលប្រយោជន៍ពលរដ្ឋខ្មែរនៅបរទេស និងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការគ្រប់គ្រងជនបរទេសនៅព្រះរាជាណាចក្រកម្ពុជា
- គ្រប់គ្រងផ្តល់ និងពន្យារសុពលភាពលិខិតឆ្លងដែនការទូត និងលិខិតឆ្លងដែនផ្លូវការជូនមន្ត្រីរាជការ និងឥស្សរជនខ្មែរ
- គ្រប់គ្រងផ្តល់ និងពន្យារទិដ្ឋាការជូនជនបរទេស
- សហការជាមួយអាជ្ញាធរពាក់ព័ន្ធ ក្នុងការការពារអធិបតេយ្យភាព និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា តាមមធ្យោបាយការទូត និងក្នុងការគ្រប់គ្រងព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ជាតិ និងអន្តរជាតិ
- សហការជាមួយអាជ្ញាធរពាក់ព័ន្ធប្រយុទ្ធប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនព្រមទាំងអំពើជួញដូរ មនុស្ស អាវុធ និងគ្រឿងញៀន
- ធ្វើនីត្យានុកូលកម្មលើលិខិតស្នាមរបស់អាជ្ញាធរសាធារណៈ លើអត្ថបទបកប្រែលិខិតអត្រានុកូលដ្ឋាន និងឯកសារផ្សេងៗទៀតតាមការស្នើសុំរបស់ប្រជាពលរដ្ឋ
- ធ្វើរបាយការណ៍សកម្មភាពការងារជូនក្រសួង
- អនុវត្តភារកិច្ចផ្សេងទៀតដែលក្រសួងប្រគល់ឲ្យ។

**មាត្រា១៨.-**

អគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន មាននាយកដ្ឋានចំណុះចំនួន៣ (បី) ជាសេនាធិការ ៖

- នាយកដ្ឋានកិច្ចការច្បាប់និងសន្ធិសញ្ញា : មានមុខងារសម្របសម្រួលកិច្ចការច្បាប់ និងសន្ធិសញ្ញា
- នាយកដ្ឋានកិច្ចការកុងស៊ុល : មានមុខងារសម្របសម្រួលកិច្ចការកុងស៊ុល
- នាយកដ្ឋានកិច្ចការព្រំដែន : មានមុខងារសម្របសម្រួលកិច្ចការព្រំដែន។

## ជំពូកទី៧
## អគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក

**មាត្រា១៩.-**

អគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក បំពេញមុខងារជាសេនាធិការឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិលើការងារនយោបាយ និងការងារសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក។

**មាត្រា២០.-**

អគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក មានភារកិច្ចដូចតទៅ៖

- ធ្វើកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក
- សិក្សា ស្រាវជ្រាវ តាមដាន វិភាគ និងរាយការណ៍អំពីសភាពការណ៍នយោបាយ សន្តិសុខ វប្បធម៌ សេដ្ឋកិច្ច ពាណិជ្ជកម្មនៅក្នុងប្រទេសនៃតំបន់អាស៊ី និងប៉ាស៊ីហ្វិក
- សហការជាមួយក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ដើម្បីសិក្សា និងតាមដានសុពលភាពនៃកិច្ចព្រមព្រៀងទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក
- រៀបចំផែនការយុទ្ធសាស្ត្រនិងថវិកាសម្រាប់កិច្ចការសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក
- រៀបចំចំណុចពិភាក្សា និងជំនួយស្មារតីស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសនៅអាស៊ី និងប៉ាស៊ីហ្វិកជូនថ្នាក់ដឹកនាំ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ជាមួយស្ថានទូតបរទេសប្រចាំនៅកម្ពុជា
- សម្របសម្រួលការងារជាមួយស្ថានតំណាងកម្ពុជាប្រចាំនៅបណ្តាប្រទេសក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក
- ធ្វើរបាយការណ៍សកម្មភាពការងារជូនក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ឲ្យ។

**មាត្រា២១.-**

អគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក មាននាយកដ្ឋានចំណុះចំនួន០៣(បី)ជាសេនាធិការៈ

- នាយកដ្ឋានអាស៊ីអាគ្នេយ៍ : មានមុខងារសម្របសម្រួលកិច្ចការទំនាក់ទំនងទ្វេភាគីជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍
- នាយកដ្ឋានអាស៊ីកណ្តាល អាស៊ីខាងត្បូង និងអូសេអានី : មានមុខងារសម្របសម្រួលកិច្ចការទំនាក់ទំនងទ្វេភាគីជាមួយប្រទេស ក្នុងតំបន់អាស៊ីកណ្តាល អាស៊ីខាងត្បូងនិងអូសេអានី
- នាយកដ្ឋានអាស៊ីបូព៌ា : មានមុខងារសម្របសម្រួលកិច្ចការទំនាក់ទំនងទ្វេភាគីជាមួយប្រទេសក្នុងតំបន់អាស៊ីបូព៌ា។

## ជំពូកទី៨
## អគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា

**មាត្រា២២.-**

អគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា បំពេញមុខងារជាសេនាធិការឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិលើការងារនយោបាយនិងការងារសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសក្នុងតំបន់អឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា។

**មាត្រា២៣.-**

អគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា មានភារកិច្ចដូចតទៅៈ

- ធ្វើកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសក្នុងតំបន់អឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា
- សិក្សា ស្រាវជ្រាវ តាមដាន វិភាគ និងរាយការណ៍អំពីសភាពការណ៍នយោបាយ សន្តិសុខ វប្បធម៌ សេដ្ឋកិច្ច ពាណិជ្ជកម្មនៅក្នុងប្រទេសនៃតំបន់អឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា
- សិក្សា និងតាមដានសុពលភាពនៃកិច្ចព្រមព្រៀងទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសក្នុងតំបន់អឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា
- រៀបចំផែនការយុទ្ធសាស្ត្រនិងថវិកាសម្រាប់កិច្ចការសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់អឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា
- រៀបចំចំណុចពិភាក្សា និងជំនួយស្មារតីស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសនៅក្នុងតំបន់អឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា ជូនថ្នាក់ដឹកនាំ
- សម្របសម្រួលការងារជាមួយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ជាមួយស្ថានទូតបរទេសប្រចាំនៅកម្ពុជា

- សម្របសម្រួលការងារជាមួយស្ថានតំណាងរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំនៅបណ្តាប្រទេសក្នុងតំបន់អឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា
- ធ្វើរបាយការណ៍សកម្មភាពការងារជូនក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ឱ្យ។

**មាត្រា២៤.-**

អគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា មាននាយកដ្ឋានចំណុះចំនួន០៣(បី)ជាសេនាធិការៈ

- នាយកដ្ឋានអឺរ៉ុបៈ មានមុខងារសម្របសម្រួលកិច្ចការទំនាក់ទំនងទ្វេភាគីជាមួយប្រទេសនៅអឺរ៉ុប
- នាយកដ្ឋានអាមេរិកៈ មានមុខងារសម្របសម្រួលកិច្ចការទំនាក់ទំនងទ្វេភាគីជាមួយប្រទេសនៅអាមេរិក
- នាយកដ្ឋានអាហ្វ្រិក-មជ្ឈិមបូព៌ាៈ មានមុខងារសម្របសម្រួលកិច្ចការទំនាក់ទំនងទ្វេភាគីជាមួយប្រទេសនៅអាហ្វ្រិក-មជ្ឈិមបូព៌ា។

## ជំពូកទី៩
## អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

**មាត្រា២៥.-**

អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ បំពេញមុខងារជាសេនាធិការឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្នុងបេសកកម្មលើកកម្ពស់ ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការនិងសម្របសម្រួលការងារពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិទាំងក្នុងកម្រិតអនុតំបន់ តំបន់ អន្តរតំបន់ និងពិភពលោក ព្រមទាំង ការងារពាក់ព័ន្ធនឹងអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលធ្វើសកម្មភាពនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៦.-**

អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដូចតទៅៈ

- រៀបចំផែនការយុទ្ធសាស្ត្រ និងថវិកាសម្រាប់ការងារសហប្រតិបត្តិការអន្តរជាតិ
- សិក្សា ស្រាវជ្រាវ និងលើកយោបល់លើការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានាក្នុងកម្រិត អនុតំបន់ តំបន់ អន្តរតំបន់ និងពិភពលោក
- សម្របសម្រួលកិច្ចការសហប្រតិបត្តិការអន្តរជាតិលើគ្រប់វិស័យដែលមានជាអាទិ៍ នយោបាយ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ពាណិជ្ជកម្ម វប្បធម៌ អប់រំ វិទ្យាសាស្ត្រ-បច្ចេកទេស សង្គមកិច្ច ទេសចរណ៍។ល។

- សម្របសម្រួលកិច្ចការអង្គការអន្តររដ្ឋាភិបាលនានានិងអង្គការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច អនុតំបន់ តំបន់ អន្តរតំបន់ និងពិភពលោក ដែលមានកិច្ចសហប្រតិបត្តិការជាមួយព្រះរាជាណាចក្រកម្ពុជា
- សម្របសម្រួលនិងធ្វើកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអនុតំបន់ តំបន់ អន្តរតំបន់ និងពិភពលោក
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីជំរុញការរៀបចំនិងការអនុវត្តផែនការសកម្មភាព និងគម្រោងពាក់ព័ន្ធនានារបស់ព្រះរាជាណាចក្រកម្ពុជា នៅក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការ អនុតំបន់ តំបន់ អន្តរតំបន់ និងពិភពលោក
- គ្រប់គ្រងនិងសម្របសម្រួលការងារអង្គការមិនមែនរដ្ឋាភិបាលបរទេសនានា ដែលមានទីស្នាក់ការ និងធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំចំណុចពិភាក្សា និងជំនួយស្មារតីជូនថ្នាក់ដឹកនាំ និងចូលរួមកិច្ចប្រជុំសំខាន់ៗដែលពាក់ព័ន្ធនឹងសហប្រតិបត្តិការអនុតំបន់ តំបន់ អន្តរតំបន់ និងពិភពលោក ព្រមទាំងកិច្ចការពាក់ព័ន្ធនឹងអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិ
- ធ្វើរបាយការណ៍សកម្មភាពការងារជូនក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ជូន។

**មាត្រា២៧.-**

អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មាននាយកដ្ឋានចំណុះចំនួន០៥(ប្រាំ)ជាសេនាធិការៈ

- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ: មានមុខងារសម្របសម្រួលកិច្ចការពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តររដ្ឋាភិបាល អនុតំបន់ តំបន់ អន្តរតំបន់ និងអង្គការពិភពលោកដែលពាក់ព័ន្ធ
- នាយកដ្ឋានសហប្រតិបត្តិការមេគង្គ: មានមុខងារសម្របសម្រួលកិច្ចការពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការមេគង្គ
- នាយកដ្ឋានអង្គការសហប្រជាជាតិ : មានមុខងារសម្របសម្រួលកិច្ចការពាក់ព័ន្ធនឹងអង្គការសហប្រជាជាតិ
- នាយកដ្ឋានអង្គការអន្តរជាតិ : មានមុខងារសម្របសម្រួលកិច្ចការពាក់ព័ន្ធនឹងអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលមានទីស្នាក់ការនិងធ្វើសកម្មភាពនៅព្រះរាជាណាចក្រកម្ពុជា
- នាយកដ្ឋានអង្គការហ្វ្រង់កូហ្វូនី: មានមុខងារសម្របសម្រួលកិច្ចការពាក់ព័ន្ធនឹងអង្គការហ្វ្រង់កូហ្វូនី។

## ជំពូកទី១០
## អគ្គាធិការដ្ឋាន

**មាត្រា២៨.-**

អគ្គាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិក្នុងបេសកកម្មធ្វើអធិការកិច្ចជាប្រចាំលើការងាររដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងបុគ្គលិក និងមន្ត្រីរាជការក្នុង និងក្រៅប្រទេស។

**មាត្រា២៩.-**

អគ្គាធិការដ្ឋាន មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការយុទ្ធសាស្ត្រ និងថវិកាសម្រាប់ការងារអធិការកិច្ច
- ធ្វើអធិការកិច្ចទូទៅលើកិច្ចដំណើរការរដ្ឋបាល ហិរញ្ញវត្ថុ ការគ្រប់គ្រងបុគ្គលិក មន្ត្រីរាជការរបស់ក្រសួង អង្គភាពក្រោមឱវាទ និងស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- ចុះត្រួតពិនិត្យពាក្យបណ្តឹងតវ៉ានិងបណ្តឹងបរិហាររបស់ប្រជាពលរដ្ឋ សង្គមស៊ីវិល ដែលទាក់ទងនឹងវិស័យការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- ធ្វើរបាយការណ៍សកម្មភាពការងារជូនក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ជូន។

**មាត្រា៣០.-**

អគ្គាធិការដ្ឋានមាននាយកដ្ឋានចំណុះចំនួន ០២(ពីរ) ជាសេនាធិការ៖

- នាយកដ្ឋានអធិការកិច្ចរដ្ឋបាលកណ្តាល: មានមុខងារសម្របសម្រួលកិច្ចការពាក់ព័ន្ធនឹងអធិការកិច្ចរដ្ឋបាលកណ្តាល
- នាយកដ្ឋានអធិការកិច្ចស្ថានតំណាងក្រៅប្រទេស: មានមុខងារសម្របសម្រួលកិច្ចការពាក់ព័ន្ធនឹងអធិការកិច្ចស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស។

## ជំពូកទី១១
## វិទ្យាស្ថានជាតិទំនាក់ទំនងការទូត និងសិក្សាអន្តរជាតិ

**មាត្រា៣១.-**

វិទ្យាស្ថានជាតិទំនាក់ទំនងការទូត និងសិក្សាអន្តរជាតិ បំពេញមុខងារជាសេនាធិការឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិលើការងារអប់រំ បណ្តុះបណ្តាល និងស្រាវជ្រាវលើវិស័យការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា៣២.-**

វិទ្យាស្ថានជាតិទំនាក់ទំនងការទូត និងសិក្សាអន្តរជាតិ មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការយុទ្ធសាស្ត្រ និងថវិកា
- រៀបចំកម្មវិធីអប់រំ និងបណ្តុះបណ្តាលលើវិស័យការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ
- ចូលរួមចំណែកសិក្សាស្រាវជ្រាវ វាយតម្លៃស្ថានការណ៍ជាតិ និងពិភពលោក វិភាគយុទ្ធសាស្ត្រ និងផ្តល់យោបល់ក្នុងការរៀបចំគោលនយោបាយការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- រៀបចំកម្មវិធី បាឋកថា វេទិកាពិភាក្សា និងសិក្ខាសាលាពាក់ព័ន្ធនឹងកិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ចូលរួមចំណែករៀបចំឱ្យមានការប្រឡងវាស់កម្រិតសមត្ថភាពជំនាញការទូត និងការសិក្សាអន្តរជាតិ
- សហការជាមួយស្ថាប័នជាតិ និងអន្តរជាតិនានា ដើម្បីពង្រឹងការអប់រំ បណ្តុះបណ្តាល ស្រាវជ្រាវ និងផ្ទេរចំណេះដឹងលើវិស័យការទូត និងការសិក្សាអន្តរជាតិ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារជូនក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ឱ្យ។

**មាត្រា៣៣.-**

វិទ្យាស្ថានជាតិទំនាក់ទំនងការទូត និងសិក្សាអន្តរជាតិមាននាយកដ្ឋានចំណុះចំនួន ០២(ពីរ) ជាសេនាធិការ ៖

- នាយកដ្ឋានទំនាក់ទំនងការទូត : មានមុខងារសម្របសម្រួលការសិក្សាស្រាវជ្រាវកិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សំដៅបណ្តុះបណ្តាលជំនាញការទូត
- នាយកដ្ឋានសិក្សាអន្តរជាតិ : មានមុខងារសម្របសម្រួលការសិក្សាស្រាវជ្រាវកិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សំដៅបណ្តុះបណ្តាលជំនាញការសិក្សាអន្តរជាតិ។

## ជំពូកទី១២

## នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

**មាត្រា ៣៤.-**

នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានជាសេនាធិការឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការ

អន្តរជាតិ លើការងារគ្រប់គ្រង និងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ព្រមទាំងការគ្រប់គ្រង និងផ្សព្វផ្សាយព័ត៌មាន និងឯកសារ ។

## ជំពូកទី១៣
## នាយកដ្ឋានគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ

**មាត្រា ៣៥.-**

នាយកដ្ឋានគោលនយោបាយនិងផែនការយុទ្ធសាស្ត្រ ជាសេនាធិការឱ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លើការងារសម្របសម្រួលរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

## ជំពូកទី១៤
## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា៣៦.-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បំពេញមុខងារជាសេនាធិការឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ លើការងារពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ តាមស្មារតីខ្លឹមសារនៃអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួងស្ថាប័ន និងសហគ្រាសសាធារណៈ។

## ជំពូកទី១៥
## ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស

**មាត្រា៣៧.-**

ស្ថានឯកអគ្គរាជទូត ស្ថានតំណាង ឬ ស្ថានបេសកកម្មអចិន្ត្រៃយ៍នានាប្រចាំអង្គការតំបន់ និងអង្គការអន្តរជាតិ ត្រូវដឹកនាំដោយឯកអគ្គរាជទូតជាប្រធានបេសកកម្ម។

ការតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់បេសកកម្មឯកអគ្គរាជទូត ត្រូវស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីទូលថ្វាយព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា។

ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព គឺតំណាងឱ្យរាជរដ្ឋាភិបាលលើគ្រប់វិស័យ។

**មាត្រា៣៨.-**

ស្ថានអគ្គកុងស៊ុល ត្រូវដឹកនាំដោយអគ្គកុងស៊ុលជាប្រធានបេសកកម្ម។

ស្ថានកុងស៊ុល ត្រូវដឹកនាំដោយកុងស៊ុលជាប្រធានបេសកកម្ម។

អគ្គកុងស៊ុល ត្រូវជ្រើសរើសនិងស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិជូនប្រមុខរាជរដ្ឋាភិបាល។

កុងស៊ុល និងកុងស៊ុលកិត្តិយស ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

## ជំពូកទី១៦
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា៣៩.-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុបង្កើតឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមលក្ខខណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ៨១អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង។

## ជំពូកទី១៧
## អវសានប្បញ្ញត្តិ

**មាត្រា៤០.-**

អនុក្រឹត្យនេះ ត្រូវជំនួសអនុក្រឹត្យដូចខាងក្រោម៖

- អនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- អនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ស្តីពីការបង្កើតនាយកដ្ឋានសហប្រតិបត្តិការមេគង្គ
- អនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- អនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០១ ស្តីពីការបំបែកនាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក ជានាយកដ្ឋានអាស៊ីទី១ និងនាយកដ្ឋានអាស៊ីទី២។

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារៈកិច្ច រៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**

**ប្រាក់ សុខុន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ[illegible] អនក្រ.បក
ចុះថ្ងៃទី[illegible]ខែ [illegible] ឆ្នាំ២០១៦

# អង្គការលេខរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ



# ព្រះរាជក្រម

នស/រកម/០៦០៥/០១៦

## យើង

## ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់ យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គរបស់រដ្ឋសភាលើកទី ២ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងអាវុធ

# គ្រឿងផ្ទុះ និង គ្រាប់រំសេវ

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

វិសាលភាពនៃច្បាប់នេះគ្របដណ្តប់លើការបំពាក់ ការកាន់កាប់ ការយកតាមខ្លួន ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការឱ្យខ្ចី ការផ្ទេរ ការចែកចាយ ការជួល ការផលិត ការកែច្នៃតម្លើង ការជួសជុល ការដឹកជញ្ជូន ការនាំឆ្លងកាត់ ការនាំចូល ការនាំចេញ ការស្តុកអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ ។

**មាត្រា ៣.-**

វាក្យសព្ទ ដូចចែងក្នុងច្បាប់នេះ មាននិយមន័យដូចខាងក្រោម :

ក-អាវុធសំដៅដល់កាំភ្លើងគ្រប់ប្រភេទដែលផលិត ឬ កែច្នៃតម្លើង ដែលអាច ប្រើប្រាស់សម្លាប់ ឬ ធ្វើឱ្យរបួស ឬ ធ្វើឱ្យប៉ះពាល់ខូចខាតដល់ទ្រព្យសម្បត្តិ ។

ខ-គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ សំដៅដល់ឧបករណ៍ សម្ភារៈដែលគេផលិត ឬ កែច្នៃតម្លើង ដែលអាចប្រើប្រាស់សម្លាប់ ឬ ធ្វើឱ្យរបួស ឬ ធ្វើឱ្យប៉ះពាល់ដល់ ទ្រព្យសម្បត្តិ ។

គ-អាវុធគីមី អាវុធជីវសាស្រ្តគ្រប់ប្រភេទ ឬគ្រាប់ដ៏ទៃទៀត ដែលផ្ទុកជាតិគីមីផ្ទុកជីវសាស្រ្ត សំដៅដល់សារធាតុ ដែលគេផលិត ឬ កែច្នៃតម្លើង អាចបង្កគ្រោះថ្នាក់ដល់ សុខភាព អាយុជីវិត ឬ ទ្រព្យសម្បត្តិ និង បរិស្ថាន ។

ឃ-កងកម្លាំងឯកសណ្ឋាន សំដៅដល់កងកម្លាំងនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ។

ង-មន្ត្រី សំដៅដល់អ្នករាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈទាំងឡាយ និង មន្ត្រីតុលាការ មន្ត្រីនៃស្ថាប័នកំពូលរបស់ជាតិ ។

ច-ជនស៊ីវិលសំដៅដល់ជនទាំងឡាយ ដែលមិនស្ថិតនៅក្នុងកថាខណ្ឌ ឃ និង ង ។

## ជំពូកទី ២

## ការគ្រប់គ្រង ការផ្គត់ផ្គង់

## ការដឹកជញ្ជូន អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

**មាត្រា ៤.-**

ត្រូវហាមឃាត់ ការបំពាក់ ការកាន់កាប់ ការយកតាមខ្លួន ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការឱ្យខ្ចី ការផ្ទេរ ការចែកចាយ ការជួល ការផលិត ការកែច្នៃតម្លើង ការជួសជុល ការដឹកជញ្ជូន ការនាំឆ្លងកាត់ ការនាំចូល ការនាំចេញ ការស្តុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទចំពោះជនស៊ីវិលក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥.-**

ត្រូវបានអនុញ្ញាតឱ្យជនស៊ីវិលប្រើប្រាស់កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះ ដែលមិនស្ថិតនៅក្នុងកថាខណ្ឌ ក , ខ , គ នៃមាត្រា ៣ ក្នុងច្បាប់នេះ :

- កាំភ្លើង និង គ្រាប់បាញ់កំណាត់សញ្ញា
- កាំភ្លើង និង គ្រាប់បាញ់សម្រាប់សកម្មភាពកីឡា
- កាំភ្លើងដែលបាញ់ មិនមានបញ្ចូនក្បាលគ្រាប់ ឬ គ្រាប់ប្រាយ ។ កាំភ្លើងបាញ់បញ្ចូ ;កាំជ្រួចលំអ ឬ កាំភ្លើងផ្ទុះស្នូរគ្មានក្បាលគ្រាប់សម្រាប់សំដែងសិល្ប: ។
- គ្រឿងផ្ទុះសម្រាប់បម្រើសេវាកម្មសាធារណៈ និងវិស្វកម្មស៊ីវិល ឬ សម្រាប់ផ្ទុះលំអ ។

ល័ក្ខខ័ណ្ឌ និង នីតិវិធី សម្រាប់អនុវត្តន៍មាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ៦.-**

ត្រូវបានអនុញ្ញាតឱ្យតែក្រសួងមហាផ្ទៃ និង ក្រសួងការពារជាតិមានក្លឹប និង ទីលានសម្រាប់ហាត់បាញ់ដើម្បីហ្វឹកហ្វឺន ។

**មាត្រា ៧.-**

ការបំពាក់ ការកាន់កាប់ ការយកតាមខ្លួន ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើ ពាណិជ្ជកម្ម ការឱ្យខ្ចី ការផ្ទេរ ការចែកចាយ ការជួល ការផលិត ការកែច្នៃតម្លើង ការជួសជុល ការដឹកជញ្ជូន ការនាំឆ្លង

កាត់ ការនាំចូល ការនាំចេញ ការស្តុកអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទដល់កងកម្លាំងឯកសណ្ឋាន និង មន្ត្រី ត្រូវស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៨.-**

ជនបរទេស មិនត្រូវបានអនុញ្ញាតឱ្យកាន់កាប់ ឬ ប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

តាមសំណើសុំជាផ្លូវការ រាជរដ្ឋាភិបាលអាចផ្តល់ការលើកលែងចំពោះអង្គរក្សបរទេសមាន : អង្គរក្សរបស់ព្រះមហាក្សត្រ ឬ ព្រះមហាក្សត្រីយានី ប្រធានាធិបតី ប្រមុខរដ្ឋ នាយក- រដ្ឋមន្ត្រី ឥស្សរជនជាន់ខ្ពស់ ដែលយាង ឬ អញ្ជើញមកធ្វើទស្សនៈកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៩.-**

ការចុះបញ្ជីគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ។

**មាត្រា ១០.-**

ក្រសួងការពារជាតិ ទទួលខុសត្រូវលើការផ្គត់ផ្គង់ ការត្រួតពិនិត្យ ការគ្រប់គ្រងអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទរបស់កងយោធពលខេមរភូមិន្ទ ។

ក្រសួងមហាផ្ទៃ ទទួលខុសត្រូវលើការផ្គត់ផ្គង់ ការត្រួតពិនិត្យ ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ របស់កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ មន្ត្រី និង ជនស៊ីវិល ។

**មាត្រា ១១.-**

ក្រសួងការពារជាតិ មានសមត្ថកិច្ចចេញប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទដល់កងយោធពលខេមរភូមិន្ទ ។

ក្រសួងមហាផ្ទៃ មានសមត្ថកិច្ចចេញប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទដល់កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ មន្ត្រី និង ជនស៊ីវិល ។

ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ត្រូវមានបញ្ជាក់អំពីប្រភេទអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ នឹងល័ក្ខខ័ណ្ឌដែលត្រូវគោរព។

ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវរបស់អង្គភាពត្រូវបានបញ្ជាក់បន្ថែម អំពីកាតព្វកិច្ចតម្រូវឱ្យយកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវមករក្សាទុកក្នុងឃ្លាំងវិញ ។

នីតិវិធី និង ល័ក្ខខ័ណ្ឌ ស្តីពីការសុំប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១២.-**

ក្រសួងការពារជាតិ ទទួលខុសត្រូវលើសុវត្ថិភាព និងសន្តិសុខស្តុកទុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទរបស់កងយោធពលខេមរភូមិន្ទ ។

ក្រសួងមហាផ្ទៃ ទទួលខុសត្រូវលើសុវត្ថិភាព និង សន្តិសុខស្តុកទុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទរបស់កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ មន្ត្រី និង ជន ស៊ីវិល ។

អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវទាំងអស់ត្រូវចុះក្នុងបញ្ជី ហើយអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទត្រូវតែស្តុកទុក និងបញ្ចូលក្នុងឃ្លាំងដែលមានសុវត្ថិភាព ។

**មាត្រា ១៣.-**

ដើម្បីធានា សុវត្ថិភាពសាធារណៈ និង ដើម្បីបង្ការ ទប់ស្កាត់ គ្រោះមហន្តរាយ ដល់អាយុជីវិត ឬ ទ្រព្យសម្បត្តិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិ អាច បញ្ជាឱ្យជន្លៀស សាធារណជន ចេញជាបណ្តោះអាសន្ន ពីលំនៅដ្ឋាន ឬ តំបន់ ក្នុងករណីដឹងថាមានគ្រោះថ្នាក់កើតឡើង ។

បែបបទនៃការអនុវត្តនីមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៤.-**

ការដឹកជញ្ជូនអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទក្នុងប្រទេស ត្រូវស្ថិតនៅក្រោមសមត្ថកិច្ច របស់ក្រសួងការពារជាតិ បើក្នុងគោលដៅការពារជាតិ . ឬ របស់ក្រសួងមហាផ្ទៃ បើក្នុងគោលដៅការពារ សន្តិសុខផ្ទៃក្នុងប្រទេស ។

ការដឹកជញ្ជូនអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា មកពីក្រៅប្រទេសអាចធ្វើទៅបាន លុះត្រាតែបានការយល់ព្រមពីរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ។

**មាត្រា ១៥.-**

ករណីបាត់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ដែលបាននឹងកំពុងកាន់កាប់ ប្រើប្រាស់ ហើយការបាត់នោះកើតឡើងនៅក្រៅអង្គភាព ត្រូវរាយការណ៍មិនលើសពី ២៤ (ម្ភៃបួន)ម៉ោង ក្រោយពេលដឹងថាបាត់ ដល់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ ឬ ប៉ុស្តិ៍កងរាជអាវុធហត្ថ នៅទីកន្លែងដែលបាត់ ហើយត្រូវមានសាក្សីដឹងឮម្នាក់ ឬ ពីរនាក់ទៅជាមួយផងនៅពេលរាយការណ៍ ។ ក្នុងករណីគ្មានសាក្សី សមត្ថកិច្ចនៅកន្លែងកើតហេតុត្រូវចុះត្រួតពិនិត្យ និងធ្វើកំណត់ហេតុដល់ទីកន្លែងដែលបាត់ ។

ករណីបាត់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដែលស្តុកទុកក្នុងឃ្លាំង ឬ ក្នុងអង្គភាព នាយឆ្មាំ ឬ អ្នកទទួលខុសត្រូវថែរក្សាត្រូវរាយការណ៍ដល់មេបញ្ជាការ ឬ ប្រធានអង្គភាព មិនលើសពី ២៤ (ម្ភៃបួន)ម៉ោង ក្រោយដឹងថាបាត់ ។ មេបញ្ជាការ ឬ ប្រធានអង្គភាព ត្រូវចាត់វិធានការត្រួតពិនិត្យស្រាវជ្រាវជាបន្ទាន់ ។

របាយការណ៍ស្តីពីការបាត់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទខាងលើនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់លំអិត ទាក់ទង នឹងប្រភេទអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ លេខចុះបញ្ជី ព្រមទាំងមូលហេតុ និង កាលៈទេសៈនៃការបាត់ ។

**មាត្រា ១៦.-**

ការបំផ្លាញអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ឬការលុបចេញពីបញ្ជី ត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បើអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទនោះ ស្ថិតក្នុងសមត្ថកិច្ច របស់ក្រសួងមហាផ្ទៃ ឬ មានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងការពារជាតិ បើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនោះស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងការពារជាតិ ។

**មាត្រា ១៧.-**

ក្នុងករណីចាំបាច់រាជរដ្ឋាភិបាលអាចបង្កើតគណៈកម្មការជាតិ ដើម្បីត្រួតពិនិត្យដឹកនាំឬ កែទម្រង់ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣
## ការនាំចូល ការនាំចេញ ការជួសជុល
## ការផលិតអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

**មាត្រា ១៨.-**

ការនាំចូល ការនាំចេញ ការជួសជុល ការផលិតអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ត្រូវបានអនុញ្ញាតឱ្យមានរោងជាងជួសជុលនិងទីតាំងសម្រាប់ធ្វើការសាកល្បងគុណភាពអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

ការនាំចូល ការនាំចេញ ការផលិតអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ត្រូវស្របតាមគោលការណ៍ និងវិធានទាំងឡាយរបស់អន្តរជាតិដែលពាក់ព័ន្ធ ។

## ជំពូកទី ៤
## ទោសប្បញ្ញត្តិ

**មាត្រា ១៩.-**

ជនណាដែលប្រព្រឹត្តផ្ទុយនឹងមាត្រា ១៥ និងមាត្រា ១៦ នៃច្បាប់នេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣(បី)ខែ ដល់ ១(មួយ)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០,០០០ (ម្ភៃម៉ឺន)រៀល ដល់ ១.០០០.០០០ (មួយលាន)រៀល ដោយពុំទាន់គិតពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ។

**មាត្រា ២០.-**

ជនណាដែលបំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឱ្យខ្ចី ផ្ទេរ ចែកចាយ ដូលកែច្នៃតម្លើង ជួសជុល នូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោស

ដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ដល់ ២(ពីរ)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០០ (ហាសិបម៉ឺន)រៀល ដល់ ២.០០០.០០០ (ពីរលាន)រៀល ដោយពុំទាន់គិតពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ។

**មាត្រា ២១.-**

ជនណាដែលធ្វេសប្រហែស ឱ្យជនដទៃ យកអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទ ដែលខ្លួនកាន់កាប់ទៅប្រើប្រាស់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ឆ្នាំ ដល់ ២ (ពីរ)ឆ្នាំនិងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៧០០.០០០ (ចិតសិបម៉ឺន)រៀល ដល់ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ២២.-**

មន្ត្រីដែលក្រសួងមានសមត្ថកិច្ច ប្រគល់ឱ្យចេញប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ តែការផ្តល់ប័ណ្ណសម្គាល់សិទ្ធិ ប្រើប្រាស់នោះ ពុំបានត្រឹមត្រូវខុសសមត្ថកិច្ចរបស់ខ្លួនត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ដល់ ៥(ប្រាំ)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៣.០០០.០០០ (បីលាន)រៀល ដល់ ៦.០០០.០០០ (ប្រាំមួយលាន)រៀល ។

ជនណាដែលពុំមែនជាសមត្ថកិច្ច ហើយបានចេញប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទក្រោមរូបភាពណាមួយ ឬ ដោយមូលហេតុណាក៏ដោយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ដល់ ៨(ប្រាំបី)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជា ប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀល ដល់ ១០.០០០.០០០ (ដប់លាន)រៀល ។

ជនណាដែលធ្វើប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយក្លែងបន្លំ ឬ បានប្រើប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយដឹងថាក្លែងបន្លំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ដល់១០(ដប់)ឆ្នាំ ។

**មាត្រា ២៣.-**

ជនណាដែលផលិត ធ្វើពាណិជ្ជកម្ម នាំឆ្លងកាត់ នាំចេញ នាំចូល ឬ ស្តុកនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ)ឆ្នាំ ដល់ ១០ (ដប់)ឆ្នាំ ។

**មាត្រា ២៤.-**

ជនណាដែលបានប្រព្រឹត្តផ្ទុយនឹងមាត្រា ៨ និងមាត្រា ១៤ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ដល់ ១០ (ដប់)ឆ្នាំ ដោយពុំទាន់គិតពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ។

# ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**មាត្រា ២៥.-**

ក្នុងរយៈពេល ៣ (បី)ខែ យ៉ាងយូរ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ជនណាដែលបានកាន់កាប់ អាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ដោយគ្មានការអនុញ្ញាតត្រូវយកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទទាំងនោះ មកប្រគល់ឱ្យអាជ្ញាធរមានសមត្ថកិច្ច ។

# ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ២៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនិងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៧.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៥

ពរស. ០៥០៦.២៦៧ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

- បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ ២២៤ ច.ល

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ដើម្បីចម្លងចែក**

**ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា និងព្រះហស្តលេខា**

**ស ខេង នរោត្តម សិរីវុឌ្ឍ**

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ហត្ថលេខា**

**ឈាង តាន់**